**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ២៧ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការកំណត់និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈសុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៩ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ ស្ដីពីការជ្រើសរើសនិងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីមុខតំណែងនិងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈសុខាភិបាលសម្រាប់មន្ត្រីបម្រើការងារនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២ .-**

មុខតំណែងនិងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈសុខាភិបាល ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១និងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

មុខតំណែងនិងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈសុខាភិបាល ត្រូវប្រើជាមូលដ្ឋានសម្រាប់ការជ្រើសរើសមន្ត្រីបំពេញការងារក្នុងមុខតំណែងវិជ្ជាជីវៈសុខាភិបាល ការរៀបចំលក្ខខណ្ឌការងារឬកិច្ចព្រមព្រៀងការងារ ការអភិវឌ្ឍសមត្ថភាព ការវិវត្តអាជីព និងការរៀបចំផែនការធនធានមនុស្សស្របតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន។

**មាត្រា៣ .-**

ការបង្កើត ការលុប និងការកែសម្រួលមុខតំណែងវិជ្ជាជីវៈសុខាភិបាល ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់ក្រសួងសុខាភិបាល បន្ទាប់ពីទទួលបានការឯកភាពជាមុនពីក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៥កើត ខែ ផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មីនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ២០២៦
ស្ដីពីការកំណត់និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈសុខាភិបាល

## បញ្ជីឈ្មោះមុខតំណែងវិជ្ជាជីវៈសុខាភិបាល

| ល.រ | មុខតំណែងវិជ្ជាជីវៈសុខាភិបាល | លេខកូដ |
|---|---|---|
| ១ | សាស្ត្រាចារ្យមហាបរិញ្ញា | PHE001 |
| ២ | សាស្ត្រាចារ្យរង | PHE002 |
| ៣ | សាស្ត្រាចារ្យជំនួយ | PHE003 |
| ៤ | វេជ្ជបណ្ឌិតឯកទេសឬបណ្ឌិតស្រាវជ្រាវវេជ្ជសាស្ត្រ | PHE004 |
| ៥ | វេជ្ជបណ្ឌិតជំនាញ | PHE005 |
| ៦ | វេជ្ជបណ្ឌិតទូទៅ | PHE006 |
| ៧ | គ្រូពេទ្យមធ្យម | PHE007 |
| ៨ | ឱសថបណ្ឌិតឯកទេស | PHE008 |
| ៩ | ឱសថការីជាន់ខ្ពស់ | PHE009 |
| ១០ | ឱសថការី | PHE010 |
| ១១ | ឱសថការីមធ្យម | PHE011 |
| ១២ | ទន្តបណ្ឌិតឯកទេស | PHE012 |
| ១៣ | ទន្តបណ្ឌិតជំនាញ | PHE013 |
| ១៤ | ទន្តបណ្ឌិតទូទៅ | PHE014 |
| ១៥ | ទន្តពេទ្យមធ្យម | PHE015 |
| ១៦ | ទន្តគិលានុបដ្ឋាកមធ្យម | PHE016 |
| ១៧ | បណ្ឌិតសុខភាពសាធារណៈ | PHE017 |
| ១៨ | មន្ត្រីជំនាញសុខភាពសាធារណៈជាន់ខ្ពស់ | PHE018 |
| ១៩ | មន្ត្រីជំនាញសុខភាពសាធារណៈ | PHE019 |
| ២០ | មន្ត្រីបច្ចេកទេសសុខភាពសាធារណៈ | PHE020 |
| ២១ | គិលានុបដ្ឋាកបណ្ឌិត | PHE021 |
| ២២ | គិលានុបដ្ឋាកជាន់ខ្ពស់ | PHE022 |
| ២៣ | គិលានុបដ្ឋាកបរិញ្ញាបត្រ | PHE023 |
| ២៤ | គិលានុបដ្ឋាកមធ្យម | PHE024 |
| ២៥ | គិលានុបដ្ឋាកបឋម | PHE025 |
| ២៦ | មន្ត្រីបច្ចេកទេសថែទាំ និងអមវេជ្ជសាស្ត្របឋម | PHE026 |
| ២៧ | ឆ្មបបណ្ឌិត | PHE027 |
| ២៨ | ឆ្មបជាន់ខ្ពស់ | PHE028 |

| ល.រ | មុខតំណែងវិជ្ជាជីវៈសុខាភិបាល | លេខកូដ |
|---|---|---|
| ២៩ | ឆ្មបបរិញ្ញាបត្រ | PHE029 |
| ៣០ | ឆ្មបមធ្យម | PHE030 |
| ៣១ | ឆ្មបបឋម | PHE031 |
| ៣២ | មន្ត្រីជំនាញព្យាបាលដោយចលនា | PHE032 |
| ៣៣ | មន្ត្រីបច្ចេកទេសព្យាបាលដោយចលនា | PHE033 |
| ៣៤ | បណ្ឌិតមន្ទីរពិសោធន៍ | PHE034 |
| ៣៥ | មន្ត្រីជំនាញមន្ទីរពិសោធន៍ជាន់ខ្ពស់ | PHE035 |
| ៣៦ | មន្ត្រីជំនាញមន្ទីរពិសោធន៍ | PHE036 |
| ៣៧ | មន្ត្រីបច្ចេកទេសមន្ទីរពិសោធន៍ | PHE037 |
| ៣៨ | មន្ត្រីជំនាញវិទ្យុសាស្ត្រ | PHE038 |
| ៣៩ | មន្ត្រីបច្ចេកទេសវិទ្យុសាស្ត្រ | PHE039 |
| ៤០ | វិស្វករឧបករណ៍ជីវៈវេជ្ជសាស្ត្រ | PHE040 |
| ៤១ | មន្ត្រីបច្ចេកទេសឧបករណ៍ជីវៈវេជ្ជសាស្ត្រ | PHE041 |
| ៤២ | មន្ត្រីជំនាញរូបវិទ្យាវេជ្ជសាស្ត្រ | PHE042 |

លេខកូដ PHE001 មានន័យថា P = មុខតំណែងវិជ្ជាជីវៈ, HE = សុខាភិបាល, 001 = លេខរៀងលំដាប់មុខតំណែងវិជ្ជាជីវៈ។

# ការពិពណ៌នាមុខតំណែងវិជ្ជាជីវៈសុខាភិបាល

## ១- ការពិពណ៌នាមុខតំណែងសាស្ត្រាចារ្យមហាបរិញ្ញា (លេខកូដ : PHE001)

<table>
<tr><td>១- ឈ្មោះមុខតំណែង</td><td>សាស្ត្រាចារ្យមហាបរិញ្ញា</td></tr>
<tr><td>២- ឈ្មោះអង្គភាព</td><td>(ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី)</td></tr>
<tr><td>៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់</td><td>(ត្រូវបំពេញដោយអង្គភាព)</td></tr>
<tr><td>៤- គណនេយ្យភាព</td><td>រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព)</td></tr>
<tr><td colspan="2">៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ<br>-ផ្តល់ការបណ្តុះបណ្តាលដល់និស្សិតនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ការសិក្សាស្រាវជ្រាវ និងសរសេរអត្ថបទសិក្សាសម្រាប់ផ្សព្វផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រជាតិ និង/ឬអន្តរជាតិ<br>-រៀបចំកម្មវិធីសិក្សា និងសម្ភារៈសិក្សាសម្រាប់ការបណ្តុះបណ្តាលជំនាញផ្សេងៗក្នុងកម្មវិធីអប់រំ មុនពេលនិង/ឬក្នុងពេលបម្រើការងារសម្រាប់ប្រើប្រាស់នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល<br>-ដឹកនាំការសរសេរនិក្ខេបបទរបស់និស្សិតនៅក្នុងជំនាញ<br>-លើកគម្រោងនិងដឹកនាំគម្រោងស្រាវជ្រាវដែលរួមចំណែកដល់ការពង្រីកចំណេះដឹងនៅក្នុងមុខជំនាញវិជ្ជាជីវៈ<br>-ដឹកនាំនិងធ្វើការបោះពុម្ពផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រជាតិ និង/ឬអន្តរជាតិ<br>-រៀបចំបង្កើតប្រព័ន្ធធានាគុណភាពនៃការបង្រៀន ការរៀន ការស្រាវជ្រាវ និងការតម្រង់ទិសយុទ្ធសាស្ត្ររបស់ស្ថាប័ន<br>-ត្រួតពិនិត្យការសិក្សារបស់និស្សិត ការណែនាំអំពីផែនការ និងគោលដៅអាជីព<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។</td></tr>
<tr><td colspan="2">៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង)</td></tr>
<tr><td colspan="2">៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន)</td></tr>
</table>

| | | |
|---|---|---|
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្របណ្ឌិត ឬសញ្ញាបត្រឯកទេស ឬសញ្ញាបត្រសមមូលតាមជំនាញ |
| | ជំនាញឯកទេស៖ ជំនាញវិជ្ជាជីវៈសុខាភិបាលផ្សេងៗ និងមានព្រះរាជក្រឹត្យតែងតាំងជាសាស្ត្រាចារ្យមហាបរិញ្ញា |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងក្នុងការបំពេញការងារ<br>-មានសមត្ថភាពប្រើប្រាស់ភាសា អង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត យ៉ាងស្ទាត់ជំនាញ<br>-មានចំណេះដឹងផ្នែកគោលនយោបាយយុទ្ធសាស្ត្រសុខាភិបាល និងក្រមសីលធម៌វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងាររបស់អង្គភាព<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>-គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រនិងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>-មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>-ចូលរួមជាមួយអ្នកឯកទេសស្រាវជ្រាវផ្នែកគ្លីនិក<br>-ចូលរួមផ្តល់ប្រឹក្សានៃការថែទាំនិងព្យាបាល។ |

## ២- ការពិពណ៌នាមុខតំណែងសាស្ត្រាចារ្យរង (លេខកូដ : PHE002)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | សាស្ត្រាចារ្យរង |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖ (ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖<br>-ផ្តល់ការបណ្តុះបណ្តាលដល់និស្សិតនៅគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ធ្វើការសិក្សា ស្រាវជ្រាវ និងការសរសេរអត្ថបទសិក្សាសម្រាប់ផ្សព្វផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រជាតិ និង/ឬអន្តរជាតិ<br>-រៀបចំកម្មវិធីសិក្សា និងសម្ភារៈសិក្សាសម្រាប់ការបណ្តុះបណ្តាលជំនាញផ្សេងៗក្នុងកម្មវិធីអប់រំមុនពេល និង/ឬក្នុងពេលបម្រើការងារសម្រាប់ប្រើប្រាស់នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល<br>-ដឹកនាំការសរសេរនិក្ខេបបទរបស់និស្សិតនៅក្នុងជំនាញ<br>-លើកគម្រោងស្រាវជ្រាវ និងដឹកនាំគម្រោងស្រាវជ្រាវដែលរួមចំណែកដល់ការពង្រីកចំណេះដឹងនៅក្នុងមុខជំនាញវិជ្ជាជីវៈ<br>-ដឹកនាំនិងធ្វើការបោះពុម្ពផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រជាតិ និង/ឬអន្តរជាតិ<br>-រៀបចំបង្កើតប្រព័ន្ធធានាគុណភាពនៃការបង្រៀន ការរៀន ការស្រាវជ្រាវ និងការតម្រង់ទិសយុទ្ធសាស្ត្ររបស់ស្ថាប័ន<br>-ត្រួតពិនិត្យការសិក្សារបស់និស្សិត និងណែនាំនិស្សិតអំពីផែនការនិងគោលដៅអាជីព<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្របណ្ឌិត ឬសញ្ញាបត្រឯកទេស ឬសញ្ញាបត្រសមមូលតាមជំនាញ |
| | ជំនាញឯកទេស៖ ជំនាញឯកទេសវិជ្ជាជីវៈសុខាភិបាលផ្សេងៗ និងមានអនុក្រឹត្យតែងតាំងជាសាស្ត្រាចារ្យរង |

| | |
|---|---|
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ (អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត យ៉ាងស្ទាត់ជំនាញ<br>-យល់ដឹងគោលនយោបាយយុទ្ធសាស្ត្រសុខាភិបាល ក្រមសីលធម៌វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងាររបស់អង្គភាព<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>-គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>-មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>-ចូលរួមជាមួយអ្នកឯកទេសស្រាវជ្រាវផ្នែកគ្លីនិក<br>-ចូលរួមផ្តល់ប្រឹក្សានៃការថែទាំនិងព្យាបាល។ |

## ៣- ការពិពណ៌នាមុខតំណែងសាស្ត្រាចារ្យជំនួយ (លេខកូដ : PHE003)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | សាស្ត្រាចារ្យជំនួយ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ<br>-ផ្តល់ការបណ្តុះបណ្តាលដល់និស្សិតនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ធ្វើការសិក្សាស្រាវជ្រាវនិងសរសេរអត្ថបទសិក្សាសម្រាប់ផ្សព្វផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រជាតិ និង/ឬអន្តរជាតិ<br>-រៀបចំកម្មវិធីសិក្សា និងសម្ភារៈសិក្សាសម្រាប់ការបណ្តុះបណ្តាលជំនាញផ្សេងៗក្នុងកម្មវិធីអប់រំមុនពេល ឬក្នុងពេលបម្រើការងារសម្រាប់ប្រើប្រាស់នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល<br>-ដឹកនាំការសរសេរនិក្ខេបបទរបស់និស្សិតនៅក្នុងជំនាញ<br>-រៀបចំនិងដឹកនាំគម្រោងស្រាវជ្រាវដែលរួមចំណែកដល់ការពង្រីកចំណេះដឹងនៅក្នុងមុខជំនាញវិជ្ជាជីវៈ<br>-ដឹកនាំនិងធ្វើការបោះពុម្ពផ្សាយលទ្ធផលនៃការស្រាវជ្រាវនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រក្នុងប្រទេសនិងតំបន់<br>-រៀបចំបង្កើតប្រព័ន្ធធានាគុណភាពនៃការបង្រៀន ការរៀន ការស្រាវជ្រាវ និងការតម្រង់ទិសយុទ្ធសាស្ត្ររបស់ស្ថាប័ន<br>-ត្រួតពិនិត្យការសិក្សារបស់និស្សិត និងណែនាំនិស្សិតអំពីផែនការនិងគោលដៅអាជីព<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រៈ បរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្របណ្ឌិត ឬសញ្ញាបត្រឯកទេសឬសញ្ញាបត្រសមមូលតាមជំនាញ |
| | ជំនាញឯកទេសៈ ជំនាញវិជ្ជាជីវៈសុខាភិបាលផ្សេងៗ និងមានប្រកាសតែងតាំងជាសាស្ត្រាចារ្យជំនួយ |

| | |
|---|---|
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង/ឬភាសាផ្សេងទៀត យ៉ាងស្ទាត់ជំនាញ<br>-មានចំណេះដឹងផ្នែកគោលនយោបាយយុទ្ធសាស្ត្រសុខាភិបាល ក្រមសីលធម៌វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងាររបស់អង្គភាព<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>-គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្ដីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រ ចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>-មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>-ចូលរួមជាមួយអ្នកឯកទេសស្រាវជ្រាវផ្នែកគ្លីនិក<br>-ចូលរួមផ្ដល់ប្រឹក្សានៃការថែទាំ និងព្យាបាល។ |

## ៤- ការពិពណ៌នាមុខតំណែងវេជ្ជបណ្ឌិតឯកទេស ឬបណ្ឌិតស្រាវជ្រាវវេជ្ជសាស្ត្រ (លេខកូដ : PHE004)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | វេជ្ជបណ្ឌិតឯកទេសឬបណ្ឌិតស្រាវជ្រាវវេជ្ជសាស្ត្រ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- រៀបចំ ដឹកនាំ និង/ឬចូលរួមសរសេរអត្ថបទស្រាវជ្រាវ និងសិក្សាស្រាវជ្រាវវេជ្ជសាស្ត្រ
- រៀបចំ ដឹកនាំ និង/ឬចូលរួមប្រតិបត្តិគម្រោង/កម្មវិធីសុខភាព
- រៀបចំ ដឹកនាំ និង/ឬចូលរួមតាក់តែងពិធីសារ និងគោលការណ៍ណែនាំទាក់ទងនឹងសុខភាព
- ដឹកនាំនិង/ឬចូលរួមពិនិត្យនិងកែសម្រួលឯកសារអប់រំពាក់ព័ន្ធនឹងសុខភាព និងនិពន្ធចុះផ្សាយឯកសារឬរបាយការណ៍
- ផ្តល់សេវាពិនិត្យសុខភាព សេវាបង្ការជំងឺ សេវាអប់រំលើកកម្ពស់សុខភាព និងចូលរួមផ្សព្វផ្សាយកម្មវិធីជាតិទាក់ទងនឹងសុខភាព
- ផ្តល់សេវាពិគ្រោះជំងឺ ធ្វើរោគវិនិច្ឆ័យ ព្យាបាល និងរៀបចំផែនការព្យាបាលនិងថែទាំ
- គ្រប់គ្រង តាមដាន វាយតម្លៃ គ្រប់គ្រងហានិភ័យ បង្ការ និងការត្រួតពិនិត្យការចម្លងរោគ
- ផ្តល់ការសង្គ្រោះបឋម និងសង្គ្រោះបន្ទាន់ក្នុងឯកទេសរបស់ខ្លួន
- បញ្ជូនអ្នកជំងឺទៅវេជ្ជបណ្ឌិតឯកទេសដែលពាក់ព័ន្ធករណីបញ្ហាសុខភាពរបស់អ្នកជំងឺដែលមិនទាក់ទងនឹងឯកទេសរបស់ខ្លួន
- ចូលរួមត្រៀមរៀបចំ និងឆ្លើយតបបញ្ហាសុខភាពសាធារណៈ ឬគ្រោះអាសន្នសុខភាពនានា
- ដឹកនាំនិង/ឬចូលរួមសកម្មភាពបង្រៀនដល់កម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សាក្នុងមូលដ្ឋានសុខាភិបាលដែលខ្លួនកំពុងបម្រើការងារ
- ចូលរួមក្នុងសកម្មភាពបណ្តុះបណ្តាលវិជ្ជាជីវៈបន្តដើម្បីលើកកម្ពស់គុណភាពសេវាពិនិត្យព្យាបាល និងថែទាំ និងបំពេញឱ្យបាននូវលក្ខខណ្ឌដែលតម្រូវដោយគណៈគ្រូពេទ្យកម្ពុជា
- ប្រកាន់ខ្ជាប់នូវសុវត្ថិភាពនិងសុខភាពការងារ

| | |
|---|---|
| -គោរពសិទ្ធិអតិថិជន ឯកជនភាព រក្សាការសម្ងាត់ និងមិនរើសអើងគ្រប់ប្រភេទអតិថិជន<br>-ចូលរួមថែទាំសម្ភារៈបរិក្ខារពេទ្យឱ្យបានល្អដើម្បីធានាដំណើរការល្អ និងប្រើប្រាស់បានយូរ<br>-សហការល្អជាមួយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតប្រសិនបើពាក់ព័ន្ធ<br>-ធានាថាអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រនៅមានសុពលភាព<br>-ចូលរួមរក្សាទុកនូវកំណត់ត្រានិងឯកសារអ្នកជំងឺ ឬអតិថិជនឱ្យបានត្រឹមត្រូវតាមនីតិវិធីជាធរមាន<br>-បំពេញការកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ វេជ្ជបណ្ឌិតឯកទេសវេជ្ជសាស្ត្រ ឬបណ្ឌិតវិទ្យាសាស្ត្រផ្នែកវេជ្ជសាស្ត្រ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ វេជ្ជបណ្ឌិតឯកទេស ឬបណ្ឌិតវិទ្យាសាស្ត្រផ្នែកវេជ្ជសាស្ត្រ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-យល់ដឹងពីច្បាប់ ក្រមសីលធម៌គ្រូពេទ្យ និយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈ វេជ្ជសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ និងនីតិវិធីប្រតិបត្តិនានាទាក់ទងការប្រតិបត្តិផ្នែកសុខាភិបាលនៅកម្ពុជា<br>-មានជំនាញទំនាក់ទំនង និងសហការល្អជាមួយសហភាគីៈ និងអ្នកវិជ្ជាជីវៈសុខាភិបាលផ្សេងៗទៀត<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទង<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត បានយ៉ាងស្ទាត់ជំនាញ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |

| | |
|---|---|
| | ឥរិយាបថបំពេញការងារ៖<br>-គោរពវិន័យ និងទំនួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

## ៥- ការពិពណ៌នាមុខតំណែងវេជ្ជបណ្ឌិតជំនាញ (លេខកូដ : PHE005)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | វេជ្ជបណ្ឌិតជំនាញ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង ៖

- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រ ផែនការប្រតិបត្តិ និងផែនការសកម្មភាព
- ចូលរួមសកម្មភាពរៀបចំ ប្រតិបត្តិ និងដឹកនាំគម្រោងឬកម្មវិធីនានា
- ផ្តល់សេវាពិនិត្យសុខភាព សេវាបង្ការជំងឺ សេវាអប់រំលើកកម្ពស់សុខភាព និងចូលរួមផ្សព្វផ្សាយកម្មវិធីជាតិទាក់ទងនឹងសុខភាព
- ផ្តល់សេវាពិគ្រោះជំងឺ ធ្វើរោគវិនិច្ឆ័យ ព្យាបាល និងរៀបចំផែនការព្យាបាលនិងថែទាំ
- គ្រប់គ្រង តាមដាន វាយតម្លៃ គ្រប់គ្រងហានិភ័យ បង្ការ និងការត្រួតពិនិត្យការចម្លងរោគ
- ផ្តល់ការសង្គ្រោះបឋមនិងវះកាត់តូច ឬបញ្ជូនក្នុងករណីចាំបាច់ដែលហួសដែនកំណត់សម្រាប់វេជ្ជបណ្ឌិត
- ចូលរួមត្រៀមរៀបចំ និងឆ្លើយតបបញ្ហាសុខភាពសាធារណៈ ឬគ្រោះអាសន្នសុខភាពនានា
- ចូលរួមសកម្មភាពបង្រៀនដល់កម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សាក្នុងមូលដ្ឋានសុខាភិបាលដែលខ្លួនកំពុងបម្រើការងារ
- ចូលរួមក្នុងសកម្មភាពបណ្តុះបណ្តាលវិជ្ជាជីវៈបន្តដើម្បីលើកកម្ពស់គុណភាពសេវាពិនិត្យព្យាបាល ថែទាំ និងបំពេញឱ្យបាននូវលក្ខខណ្ឌដែលតម្រូវដោយគណៈគ្រូពេទ្យកម្ពុជា
- ប្រកាន់ខ្ជាប់នូវសុវត្ថិភាព និងសុខភាពការងារ
- បញ្ជូនអតិថិជន ឬអ្នកជំងឺទៅវេជ្ជបណ្ឌិតឯកទេស ពេលមានតម្រូវការពិនិត្យព្យាបាល និងថែទាំ
- ចូលរួមសហការនិងសម្របសម្រួលបញ្ជូនអ្នកជំងឺដែលមានសភាពធ្ងន់ធ្ងរ ស្មុគស្មាញទៅផ្នែកជំនាញ ឬឯកទេសខ្ពស់ជាង
- គោរពសិទ្ធិអតិថិជន ឯកជនភាព រក្សាការសម្ងាត់ និងមិនរើសអើងគ្រប់ប្រភេទអតិថិជន
- ចូលរួមថែទាំសម្ភារៈបរិក្ខារពេទ្យឱ្យបានល្អដើម្បីធានាដំណើរការល្អនិងប្រើប្រាស់បានយូរ

| | |
|---|---|
| -សហការល្អជាមួយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតប្រសិនបើពាក់ព័ន្ធ<br>-ធានាថាអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រនៅមានសុពលភាព<br>-ចូលរួមរក្សាទុកនូវកំណត់ត្រា ឯកសារអ្នកជំងឺ និងអតិថិជនឱ្យបានត្រឹមត្រូវតាមនីតិវិធីជាធរមាន<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ សញ្ញាបត្រវេជ្ជបណ្ឌិត និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវេជ្ជសាស្ត្រ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ វេជ្ជបណ្ឌិតទូទៅ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវេជ្ជសាស្ត្រ ឬវេជ្ជបណ្ឌិតជំនាញ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានចំណេះដឹងពីច្បាប់ ក្រមសីលធម៌គ្រូពេទ្យ និយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈវេជ្ជសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ និងនីតិវិធីប្រតិបត្តិនានាទាក់ទងនឹងការប្រតិបត្តិផ្នែកសុខាភិបាលនៅកម្ពុជា<br>-គោរពឱ្យបានខ្ជាប់ខ្ជួននូវបទប្បញ្ញត្តិ ពិធីសារ គោលការណ៍ណែនាំផ្សេងៗ និងក្រមសីលធម៌គ្រូពេទ្យ<br>-មានជំនាញទំនាក់ទំនង និងសហការល្អជាមួយសហភាតរៈ និងអ្នកវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទង<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត បានយ៉ាងស្ទាត់ជំនាញ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |

| | |
|---|---|
| | ឥរិយាបថបំពេញការងារ៖<br>-គោរពវិន័យនិងទំនួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>-មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

## ៦- ការពិពណ៌នាមុខតំណែងវេជ្ជបណ្ឌិតទូទៅ ( លេខកូដ : PHE006 )

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | វេជ្ជបណ្ឌិតទូទៅ |
| ២- ឈ្មោះអង្គភាព | ( ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី ) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | ( ត្រូវបំពេញដោយអង្គភាព ) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ ( ត្រូវបំពេញដោយអង្គភាព ) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង ៖

- ផ្តល់សេវាពិនិត្យសុខភាព សេវាបង្ការជំងឺ សេវាអប់រំលើកកម្ពស់សុខភាព និងចូលរួមផ្សព្វផ្សាយកម្មវិធីជាតិនានាទាក់ទងនឹងសុខភាព
- ផ្តល់សេវាពិគ្រោះជំងឺ ធ្វើរោគវិនិច្ឆ័យ ព្យាបាល និងរៀបចំផែនការព្យាបាល និងថែទាំ
- គ្រប់គ្រង តាមដាន វាយតម្លៃ គ្រប់គ្រងហានិភ័យ បង្ការ និងការត្រួតពិនិត្យការចម្លងរោគ
- ផ្តល់ការសង្គ្រោះបឋម និងវះកាត់តូច ឬបញ្ជូនក្នុងករណីចាំបាច់ដែលហួសដែនកំណត់សម្រាប់វេជ្ជបណ្ឌិតទូទៅ
- គោរពឱ្យបានខ្ជាប់ខ្ជួននូវបទប្បញ្ញត្តិ ពិធីសារ គោលការណ៍ណែនាំផ្សេងៗ និងក្រមសីលធម៌គ្រូពេទ្យ
- ចូលរួមរៀបចំ និងឆ្លើយតបបញ្ហាសុខភាពសាធារណៈ ឬគ្រោះអាសន្នសុខភាពនានា
- ចូលរួមសកម្មភាពបង្រៀនដល់កម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សា ក្នុងមូលដ្ឋានសុខាភិបាលដែលខ្លួនកំពុងបម្រើការងារ
- ចូលរួមក្នុងសកម្មភាពបណ្តុះបណ្តាលវិជ្ជាជីវៈបន្តដើម្បីលើកកម្ពស់គុណភាពសេវាពិនិត្យព្យាបាល ថែទាំ និងបំពេញឱ្យបាននូវលក្ខខណ្ឌដែលតម្រូវដោយគណៈគ្រូពេទ្យកម្ពុជា
- ប្រកាន់ខ្ជាប់នូវសុវត្ថិភាព និងសុខភាពការងារ
- បញ្ជូនអតិថិជន ឬអ្នកជំងឺទៅវេជ្ជបណ្ឌិតឯកទេសពេលមានតម្រូវការពិនិត្យព្យាបាល និងថែទាំដោយអ្នកឯកទេស
- ចូលរួមសហការនិងសម្របសម្រួលបញ្ជូនអ្នកជំងឺដែលមានសភាពធ្ងន់ធ្ងរ ឬស្មុគស្មាញទៅផ្នែកជំនាញ ឬឯកទេសខ្ពស់ជាង
- គោរពសិទ្ធិអតិថិជន ឯកជនភាព រក្សាការសម្ងាត់ និងមិនរើសអើងគ្រប់ប្រភេទអតិថិជន
- ចូលរួមថែទាំសម្ភារៈបរិក្ខារពេទ្យឱ្យបានល្អដើម្បីដំណើរការល្អ និងប្រើប្រាស់បានយូរ

| | |
|---|---|
| -សហការល្អជាមួយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតប្រសិនបើពាក់ព័ន្ធ<br>-ធានាថាអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រនៅមានសុពលភាព<br>-ចូលរួមរក្សាទុកនូវកំណត់ត្រា ឯកសារអ្នកជំងឺ និងអតិថិជនឱ្យបានត្រឹមត្រូវតាមនីតិវិធីជាធរមាន<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង( គុណសម្បត្តិស័ក្តិសម/លក្ខណៈសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង ) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ( ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ សញ្ញាបត្រវេជ្ជបណ្ឌិត ឬសញ្ញាបត្រសមមូលផ្នែកវេជ្ជសាស្ត្រ |
| | ជំនាញឯកទេស៖ វេជ្ជបណ្ឌិតទូទៅ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ( អាចបំពេញបន្ថែមដោយអង្គភាព ) | ចំណេះដឹងនិងជំនាញ<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-យល់ដឹងពីច្បាប់ ក្រមសីលធម៌គ្រូពេទ្យ និយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈវេជ្ជសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ និងនីតិវិធីប្រតិបត្តិនានាទាក់ទងការប្រតិបត្តិផ្នែកសុខាភិបាលនៅកម្ពុជា<br>-មានជំនាញទំនាក់ទំនង និងសហការល្អជាមួយសហភាតរៈនិងអ្នកវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទង<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត បានយ៉ាងស្ទាត់ជំនាញ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |

| | |
|---|---|
| | ឥរិយាបថបំពេញការងារ៖<br>-គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>-មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

**៧- ការពិពណ៌នាមុខតំណែងគ្រូពេទ្យមធ្យម** (**លេខកូដ** : PHE007)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គ្រូពេទ្យមធ្យម |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង ៖

- ផ្តល់សេវាពិនិត្យសុខភាព សេវាបង្ការជំងឺ សេវាអប់រំលើកកម្ពស់សុខភាព និងចូលរួមផ្សព្វផ្សាយកម្មវិធីជាតិនានាទាក់ទងនឹងសុខភាព
- ផ្តល់សេវាពិគ្រោះជំងឺ ធ្វើរោគវិនិច្ឆ័យ ព្យាបាល និងរៀបចំផែនការព្យាបាល និងថែទាំ
- គ្រប់គ្រង តាមដាន វាយតម្លៃ គ្រប់គ្រងហានិភ័យ បង្ការ និងការត្រួតពិនិត្យការចម្លងរោគ
- ផ្តល់ការសង្គ្រោះបឋម និងវះកាត់តូច ឬបញ្ជូនក្នុងករណីចាំបាច់ដែលហួសពីដែនកំណត់សម្រាប់គ្រូពេទ្យមធ្យម
- គោរពឱ្យបានខ្ជាប់ខ្ជួននូវបទប្បញ្ញត្តិ ពិធីសារ គោលការណ៍ណែនាំ និងក្រមសីលធម៌គ្រូពេទ្យ
- ចូលរួមត្រៀមរៀបចំ និងឆ្លើយតបបញ្ហាសុខភាពសាធារណៈ ឬគ្រោះអាសន្នសុខភាពនានា
- ចូលរួមសកម្មភាពបង្រៀនដល់កម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សាក្នុងមូលដ្ឋានសុខាភិបាលដែលខ្លួនកំពុងបម្រើការងារ
- ចូលរួមក្នុងសកម្មភាពបណ្តុះបណ្តាលវិជ្ជាជីវៈបន្ត ដើម្បីលើកកម្ពស់គុណភាពសេវាពិនិត្យព្យាបាល ថែទាំ និងបំពេញឱ្យបាននូវលក្ខខណ្ឌដែលតម្រូវដោយគណៈគ្រូពេទ្យកម្ពុជា
- ប្រកាន់ខ្ជាប់នូវសុវត្ថិភាព និងសុខភាពការងារ
- ចូលរួមសហការ និងសម្របសម្រួលបញ្ជូនអ្នកជំងឺដែលមានសភាពធ្ងន់ធ្ងរ ស្មុគស្មាញទៅផ្នែកដែលមានជំនាញឬឯកទេសខ្ពស់ជាង
- គោរពសិទ្ធិអតិថិជន ឯកជនភាព រក្សាការសម្ងាត់ និងមិនរើសអើងគ្រប់ប្រភេទអតិថិជន
- ចូលរួមថែទាំសម្ភារៈបរិក្ខារពេទ្យឱ្យបានល្អដើម្បីធានាដំណើរការល្អ និងប្រើប្រាស់បានយូរ
- សហការល្អជាមួយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតប្រសិនបើពាក់ព័ន្ធ
- ធានាថាអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រនៅមានសុពលភាព
- ចូលរួមរក្សាទុកនូវកំណត់ត្រា និងឯកសារអ្នកជំងឺ/អតិថិជនឱ្យបានត្រឹមត្រូវតាមនីតិវិធីជាធរមាន
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

| | |
|---|---|
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ សញ្ញាបត្រគ្រូពេទ្យមធ្យម ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ វេជ្ជសាស្ត្រទូទៅ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-យល់ដឹងពីច្បាប់ ក្រមសីលធម៌គ្រូពេទ្យ និយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈវេជ្ជសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ និងនីតិវិធីប្រតិបត្តិនានាទាក់ទងការប្រតិបត្តិផ្នែកសុខាភិបាលនៅកម្ពុជា<br>-មានជំនាញទំនាក់ទំនង និងសហការល្អជាមួយសហភាគៈ និងអ្នកវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទង<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>-គោរពវិន័យ និងទំនួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>-មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

## ៨- ការពិពណ៌នាមុខតំណែងឱសថបណ្ឌិតឯកទេស (លេខកូដ : PHE008)

<table>
<tr><td>១- ឈ្មោះមុខតំណែង</td><td>ឱសថបណ្ឌិតឯកទេស</td></tr>
<tr><td>២- ឈ្មោះអង្គភាព</td><td>(ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី)</td></tr>
<tr><td>៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់</td><td>(ត្រូវបំពេញដោយអង្គភាព)</td></tr>
<tr><td>៤- គណនេយ្យភាព</td><td>រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព)</td></tr>
<tr><td colspan="2">៥. តួនាទី ភារកិច្ចនិងការទទួលខុសត្រូវសម្រាប់មុខតំណែង(អាចប្រែប្រួលទៅតាមជំនាញលម្អិតនីមួយៗ)<br>-ធ្វើការស្រាវជ្រាវប្រកបដោយនវានុវត្តន៍ពាក់ព័ន្ធនឹងជំនាញឯកទេសវិទ្យាសាស្ត្រសុខាភិបាលទាំងបែបបរិមាណវិស័យ និងបែបគុណវិស័យ<br>-រៀបចំគម្រោងស្រាវជ្រាវសម្រាប់ដាក់ស្នើសុំមូលនិធិដើម្បីអនុវត្ត<br>-គ្រប់គ្រងបច្ចេកទេសពាក់ព័ន្ធនឹងជំនាញឯកទេសរបស់ខ្លួន<br>-គ្រប់គ្រងការទុកដាក់ឱ្យមានសុវត្ថិភាពនូវឱសថគ្រោះថ្នាក់រួមទាំងឱសថធ្វើឱ្យញៀន ឱសថព្យាបាលដោយគីមី ឬវិទ្យុសកម្ម និងសារធាតុគ្រោះថ្នាក់ផ្សេងៗ<br>-រៀបចំនិងដឹកនាំបង្រៀនទ្រឹស្តីអនុវត្តបង្ហាញគ្រាប់ ដឹកនាំកម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សា<br>-ដឹកនាំនិស្សិតធ្វើនិក្ខេបបទស្រាវជ្រាវ និងគម្រោងស្រាវជ្រាវផ្សេងៗ<br>-ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានឱ្យបានសមស្របក្នុងការគ្រប់គ្រងទិន្នន័យ វិភាគ និងបង្ហាញលទ្ធផល<br>-ចូលរួមបង្កើតគោលនយោបាយសុខាភិបាលដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រ<br>-ចូលរួមរៀបចំបង្កើតបទប្បញ្ញត្តិ បទដ្ឋានគតិយុត្ត គោលនយោបាយ និងនីតិវិធីដែលពាក់ព័ន្ធនឹងការអនុវត្តក្នុងវិស័យឱសថសាស្ត្រ<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។</td></tr>
<tr><td colspan="2">៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង)</td></tr>
<tr><td colspan="2">៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន)</td></tr>
<tr><td rowspan="2">៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ</td><td>កម្រិតសញ្ញាបត្រៈ សញ្ញាបត្រឱសថបណ្ឌិតឯកទេស ឬសញ្ញាបត្រសមមូល</td></tr>
<tr><td>ជំនាញឯកទេសៈ ឱសថបណ្ឌិតឯកទេស ឬបណ្ឌិតវិទ្យាសាស្ត្រផ្នែកឱសថសាស្ត្រ</td></tr>
</table>

| | |
|---|---|
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញដឹកនាំ និងក្រមសីលធម៌វិជ្ជាជីវៈ<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងៗបានស្ទាត់ជំនាញ<br>-មានចំណេះដឹង និងគោរពច្បាប់ លិខិតបទដ្ឋានគតិយុត្ត ក្រមសីលធម៌ឱសថការី និយាមវិជ្ជាជីវៈឱសថការី និងដែនកំណត់វិជ្ជាជីវៈឱសថការី<br>-មានជំនាញទំនាក់ទំនង និងសហការល្អជាមួយសហភាគីៈនិងអ្នកវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈបន្ត<br>- មានសីលធម៌ ភាពសុចរិត យុត្តិធម៌ ភក្ដីភាពក្នុងការប្រកបវិជ្ជាជីវៈនិងវប្បធម៌សេវាសាធារណៈ<br>- មានការសហការ និងចែករំលែកបទពិសោធដល់សហភាគីៈ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ចូលរួមផ្ដល់ប្រឹក្សានៃការថែទាំ និងសេវាឱសថសាស្ត្រដោយផ្ដោតលើអ្នកជំងឺអតិថិជន<br>- ចូលរួមអភិបាល តាមដាន និងវាយតម្លៃការគ្រប់គ្រងនិងការប្រើប្រាស់ឱសថ។ |

## ៩- ការពិពណ៌នាមុខតំណែងឱសថការីជាន់ខ្ពស់ (លេខកូដ : PHE009)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | ឱសថការីជាន់ខ្ពស់ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖ (ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖<br>-ស្រាវជ្រាវក្នុងជំនាញផ្នែកវិទ្យាសាស្ត្រឱសថ និងជីវវេជ្ជសាស្ត្រ<br>-គ្រប់គ្រងឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាង<br>-គ្រប់គ្រងបច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រ និងមន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពសុខាភិបាល<br>-គ្រប់គ្រងការទុកដាក់ឱ្យមានសុវត្ថិភាពនូវឱសថគ្រោះថ្នាក់រួមទាំងឱសថធ្វើឱ្យញៀន ឱសថព្យាបាលដោយគីមីឬវិទ្យុសកម្ម និងសារធាតុគ្រោះថ្នាក់ផ្សេងៗ<br>-រៀបចំនិងដឹកនាំបង្រៀនទ្រឹស្តី អនុវត្តបង្ហាញគ្រាប់ ដឹកនាំកម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សានៅតាមអង្គភាពរបស់ខ្លួន<br>-ចូលរួមរៀបចំបទប្បញ្ញត្តិ បទដ្ឋានគតិយុត្ត គោលនយោបាយ និងនីតិវិធីដែលពាក់ព័ន្ធនឹងការអនុវត្តក្នុងវិស័យឱសថសាស្ត្រ<br>-ផ្តល់ការណែនាំដល់អតិថិជន ឬអ្នកជំងឺអំពីការប្រើប្រាស់ឱសថ ឬផលិតផលសុខាភិបាលក្នុងការព្យាបាលប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព<br>-ចូលរួមក្នុងកម្មវិធីសុខភាពសហគមន៍ ទាក់ទងទៅនឹងការប្រើប្រាស់ឱសថប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព<br>-ចូលរួមក្នុងការសិក្សាស្រាវជ្រាវនិងការសាកល្បងបែបគ្លីនិកសម្រាប់ឱសថ ឬសម្ភារៈបរិក្ខារថ្មីៗ និងការអភិវឌ្ឍ ការផលិត ការធ្វើតេស្ត ការវិភាគ និងការធ្វើទីផ្សារឱសថ និងផលិតផលវេជ្ជសាស្ត្រ<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |

| | |
|---|---|
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ ឱសថសាស្ត្រ/វេជ្ជជីវសាស្ត្រ/ស្បែក និងគ្រឿងសម្អាង |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងៗបានយ៉ាងស្ទាត់ជំនាញ<br>-មានចំណេះដឹង គោរពច្បាប់ លិខិតបទដ្ឋានគតិយុត្ត ក្រមសីលធម៌ឱសថការី និយាមវិជ្ជាជីវៈឱសថការី និងដែនកំណត់វិជ្ជាជីវៈឱសថការី<br>-មានជំនាញទំនាក់ទំនង និងសហការល្អជាមួយសហភាតរៈនិងអ្នកវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈបន្ត<br>- មានសីលធម៌ ភាពសុចរិត យុត្តិធម៌ ភក្ដីភាពក្នុងការប្រកបវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានការសហការ និងចែករំលែកបទពិសោធដល់សហភាតរៈ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ចូលរួមផ្តល់ប្រឹក្សានៃការថែទាំ និងសេវាឱសថសាស្ត្រដោយផ្តោតលើអ្នកជំងឺនិងអតិថិជន<br>- ចូលរួមអភិបាល តាមដាន និងវាយតម្លៃការគ្រប់គ្រងនិងការប្រើប្រាស់ឱសថ។ |

## ១០- ការពិពណ៌នាមុខតំណែងឱសថការី (លេខកូដ : PHE010)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | ឱសថការី |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- គ្រប់គ្រងឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាង
- ចូលរួមរៀបចំក្នុងការបង្កើតបទប្បញ្ញត្តិ បទដ្ឋានគតិយុត្ត គោលនយោបាយ និងនីតិវិធីដែលពាក់ព័ន្ធនឹងការអនុវត្តក្នុងវិស័យឱសថសាស្ត្រ
- គ្រប់គ្រងការផលិតឱសថនៅរោងចក្រផលិតឱសថ
- គ្រប់គ្រងបច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រ និងមន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពផលិតផលសុខាភិបាល
- គ្រប់គ្រងសេវាប្រព័ន្ធត្រជាក់សម្រាប់ការទុកដាក់ឱសថ ប្រតិករ និងវ៉ាក់សាំង
- ទុកដាក់ឱ្យមានសុវត្ថិភាពនូវឱសថគ្រោះថ្នាក់ រួមទាំងឱសថធ្វើឱ្យញៀន ឱសថសម្រាប់ការព្យាបាល ដោយគីមី និងសារធាតុវិទ្យុសកម្ម ឬសារធាតុគ្រោះថ្នាក់ផ្សេងទៀត
- ផ្តល់ព័ត៌មាន ដំបូន្មាន និងការអប់រំផ្តល់យោបល់អំពីការជ្រើសរើសឱសថ និងការប្រើប្រាស់ផលិតផលសុខាភិបាលដល់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត
- ចូលរួមរៀបចំកម្មវិធីបណ្តុះបណ្តាលដល់ឱសថការី និងបង្រៀនដល់ការបណ្តុះបណ្តាលផ្សេងទៀតទាក់ទងនឹងវិស័យឱសថសាស្ត្រ
- ត្រួតពិនិត្យផ្ទៀងផ្ទាត់ ផ្តល់ឱសថ និងឧបករណ៍បរិក្ខារពេទ្យតាមវេជ្ជបញ្ជាដោយធានាថាឱសថកម្រិតប្រើប្រាស់ រយៈពេលប្រើប្រាស់ និងរបៀបប្រើប្រាស់បានត្រឹមត្រូវ
- ផ្តល់ការណែនាំ និងផ្តល់ឱសថដែលមិនចាំបាច់ត្រូវការវេជ្ជបញ្ជា រួមទាំងឱសថបុរាណ
- លាយផ្សំឱសថ (Compounding Medicine) ទៅតាមរូបមន្ត ហើយស្របទៅតាមវេជ្ជបញ្ជារបស់គ្រូពេទ្យដើម្បីបំពេញលក្ខខណ្ឌតម្រូវការព្យាបាលរបស់អតិថិជន ឬអ្នកជំងឺម្នាក់ៗ (ឱសថដែលលាយនេះមិនអាចយកទៅឱ្យអតិថិជន ឬអ្នកជំងឺផ្សេងទៀតប្រើបានទេ)
- ផ្តល់ប្រឹក្សា និងអប់រំអតិថិជន ឬអ្នកជំងឺអំពីការប្រើប្រាស់ឱសថប្រកបដោយសុវត្ថិភាព និងសមស្រប រួមទាំងផលរំខានដែលអាចកើតមានពីអន្តរកម្មរវាងឱសថ និងឱសថដែលបង្កគ្រោះថ្នាក់
- ផ្តល់ការណែនាំដល់អតិថិជន ឬអ្នកជំងឺអំពីការប្រើប្រាស់ផលិតផលសុខាភិបាល ឬការព្យាបាលប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព

| | |
|---|---|
| -ផ្តល់ការណែនាំអំពីរបៀបរបបរស់នៅ ដើម្បីឱ្យមានផាសុកភាព និងផ្គត់ផ្គង់ឱសថ សម្ភារៈបរិក្ខារពេទ្យ ផលិតផលចំណីអាហារ ផលិតផលបំប៉នសុខភាព ផលិតផលអនាម័យ និងគ្រឿងសម្អាងដល់អ្នកជំងឺ ឬអតិថិជន<br>-តាមដាន និងពិនិត្យឱសថដែលអតិថិជន ឬអ្នកជំងឺប្រើប្រាស់ដើម្បីធានាប្រសិទ្ធភាព និងការប្រើប្រាស់សមស្រប<br>-ចូលរួមក្នុងកម្មវិធីសុខភាពសហគមន៍ទាក់ទងទៅនឹងការប្រើប្រាស់ឱសថប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព<br>-ចូលរួមក្នុងការសិក្សាស្រាវជ្រាវ និងការសាកល្បងបែបគ្លីនិកសម្រាប់ឱសថ ឬសម្ភារៈបរិក្ខារថ្មីៗ និងការអភិវឌ្ឍ ការផលិត ការធ្វើតេស្ត ការវិភាគ និងការធ្វើទីផ្សារឱសថនិងផលិតផលវេជ្ជសាស្ត្រ<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង( គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង ) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ( ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ សញ្ញាបត្រឱសថការី ឬសញ្ញាបត្រសមមូល ផ្នែកឱសថសាស្ត្រ |
| | ជំនាញឯកទេស៖ ឱសថសាស្ត្រ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព ) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-ចេះប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានចំណេះដឹង គោរពច្បាប់ លិខិតបទដ្ឋានគតិយុត្ត ក្រមសីលធម៌ឱសថការី និយាមវិជ្ជាជីវៈឱសថការី និងដែនកំណត់វិជ្ជាជីវៈឱសថការី<br>-មានជំនាញទំនាក់ទំនង និងសហការល្អជាមួយសហភាតរៈនិងអ្នកវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត<br>-មានសុខភាពល្អ<br>-មានចំណេះដឹងនិងជំនាញផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |

| | |
|---|---|
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈបន្ត<br>- មានសីលធម៌ ភាពសុចរិត យុត្តិធម៌ និងភក្តីភាពក្នុងការប្រកបវិជ្ជាជីវៈ<br>- មានការសហការ និងចែករំលែកបទពិសោធដល់សហភាតរៈ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ចូលរួមផ្តល់ប្រឹក្សានៃការថែទាំ និងសេវាឱសថសាស្ត្រដោយផ្តោតលើអ្នកជំងឺ ឬអតិថិជន<br>- ចូលរួម អភិបាល តាមដាន និងវាយតម្លៃការគ្រប់គ្រងនិងការប្រើប្រាស់ឱសថ។ |

## ១១- ការពិពណ៌នាមុខតំណែងឱសថការីមធ្យម (លេខកូដ : PHE011)

<table>
<tr><td>១- ឈ្មោះមុខតំណែង</td><td>ឱសថការីមធ្យម</td></tr>
<tr><td>២- ឈ្មោះអង្គភាព</td><td>(ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី)</td></tr>
<tr><td>៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់</td><td>(ត្រូវបំពេញដោយអង្គភាព)</td></tr>
<tr><td>៤- គណនេយ្យភាព</td><td>រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព)</td></tr>
<tr><td colspan="2">៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ<br>-ផ្តល់ឱសថតាមវេជ្ជបញ្ជាដោយធានាថាកម្រិតការប្រើប្រាស់ ពេលវេលាប្រើប្រាស់ និងរយៈពេលប្រើប្រាស់បានត្រឹមត្រូវ<br>-ផ្តល់ដំបូន្មានដល់អតិថិជន ឬអ្នកជំងឺ និងផ្តល់ឱសថមិនចាំបាច់ត្រូវការវេជ្ជបញ្ជា រួមទាំងឱសថបុរាណ<br>-ផ្តល់ការពិគ្រោះជំងឺនិងអប់រំអតិថិជន ឬអ្នកជំងឺអំពីការប្រើប្រាស់ឱសថប្រកបដោយគុណភាពសុវត្ថិភាពនិងប្រសិទ្ធភាព រួមទាំងមានផលរំខានដែលអាចកើតមាន ឬមានប្រតិកម្មឱសថដែលបង្កគ្រោះថ្នាក់<br>-ណែនាំអតិថិជន ឬអ្នកជំងឺអំពីការព្យាបាល និងថែទាំរបួសដែលមានកម្រិតស្រាលប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព<br>-តាមដាននិងពិនិត្យមើលការប្រើឱសថរបស់អតិថិជន ឬអ្នកជំងឺដើម្បីធានាការប្រើប្រាស់ដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព<br>-ផ្គត់ផ្គង់ឱសថ ឧបករណ៍ បរិក្ខារពេទ្យ ដូចជាៈ ផលិតផលចំណីអាហារ ផលិតផលបំប៉នសុខភាព ផលិតផលអនាម័យ និងគ្រឿងសម្អាងដល់អតិថិជន ឬអ្នកជំងឺ<br>-គ្រប់គ្រងការផលិតឱសថនៅរោងចក្រផលិតឱសថ<br>-គ្រប់គ្រងមន្ទីរពិសោធន៍វេជ្ជសាស្ត្រ និងមន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពផលិតផលសុខាភិបាល<br>-ចូលរួមក្នុងកម្មវិធីលើកកម្ពស់សុខភាពសហគមន៍អំពីការប្រើប្រាស់ឱសថប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។</td></tr>
<tr><td colspan="2">៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង)</td></tr>
<tr><td colspan="2">៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន)</td></tr>
<tr><td rowspan="2">៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ</td><td>កម្រិតសញ្ញាបត្រៈ សញ្ញាបត្រឱសថការីមធ្យមឬសញ្ញាបត្រសមមូល</td></tr>
<tr><td>ជំនាញឯកទេសៈ ឱសថសាស្ត្រ</td></tr>
</table>

| | |
|---|---|
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-ចេះប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានចំណេះដឹង គោរពច្បាប់ លិខិតបទដ្ឋានគតិយុត្ត ក្រមសីលធម៌ឱសថការី និយាមវិជ្ជាជីវៈឱសថការី និងដែនកំណត់វិជ្ជាជីវៈឱសថការី<br>-មានជំនាញទំនាក់ទំនង និងសហការល្អជាមួយសហភាគរៈនិងអ្នកវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត<br>-មានចំណេះដឹងនិងជំនាញផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានសីលធម៌ ភាពសុចរិត យុត្តិធម៌ និងភក្តីភាពចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈឱសថសាស្ត្រអមវេជ្ជសាស្ត្រ<br>- មានការសហការ និងចែករំលែកបទពិសោធន៍ដល់សហភាគរៈ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ចូលរួមការតាមដាន ឬស្រាវជ្រាវផលរំខានរបស់ឱសថ និងការរាយការណ៍<br>- ចូលរួមរៀបចំបង្កើតលិខិតបទដ្ឋានគតិយុត្ត និងការចងក្រងរក្សាទុកឯកសារ<br>- មានការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈបន្ត<br>- ចូលរួមផ្តល់ប្រឹក្សានៃការថែទាំ និងសេវាឱសថសាស្ត្រដោយផ្តោតលើអ្នកជំងឺ និងអតិថិជន<br>- ចូលរួមការងារអភិបាល តាមដាន និងវាយតម្លៃការគ្រប់គ្រងនិងការប្រើប្រាស់ឱសថ។ |

## ១២- ការពិពណ៌នាមុខតំណែងទន្តបណ្ឌិតឯកទេស (លេខកូដ : PHE012)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | ទន្តបណ្ឌិតឯកទេស |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- ធ្វើការពិនិត្យវាយតម្លៃអតិថិជន ឬអ្នកជំងឺដែលមានបញ្ហាសុខភាពមាត់ធ្មេញស្មុគស្មាញ ឬអ្នកដែលមានបញ្ហាសុខភាពទូទៅ
- ពិនិត្យសិក្សាពីរោគវិនិច្ឆ័យមាត់ធ្មេញឱ្យបានលម្អិតដែលធ្វើឡើងដោយបុគ្គលិកប្រតិបត្តិក្នុងគ្លីនិក និងបញ្ជាក់ ឬកែតម្រូវរោគវិនិច្ឆ័យនៃករណីដែលបានបញ្ជូនមកដោយផ្អែកលើការវាយតម្លៃរបស់ខ្លួន
- ដឹកនាំនិងចាត់ចែងក្នុងស្ថានភាពសង្គ្រោះបន្ទាន់ដើម្បីការពារសុវត្ថិភាពរបស់អតិថិជន ឬអ្នកជំងឺ គ្រួសាររបស់ពួកគាត់ និងបុគ្គលិក
- គោរពបទប្បញ្ញត្តិ ក្រមសីលធម៌ និងវិជ្ជាជីវៈទន្តពេទ្យឱ្យបានខ្ជាប់ខ្ជួន និងតាមដានអ្នកប្រកបវិជ្ជាជីវៈ ទន្តសាស្ត្រផ្សេងទៀតអំពីការគោរពតាមបទប្បញ្ញត្តិ ក្រមសីលធម៌ និងវិជ្ជាជីវៈទន្តពេទ្យ
- ធ្វើជាគំរូគ្លីនិក និងគាំទ្រសម្រាប់អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ និស្សិតអន្តេវាសិក និងផ្តល់ការណែនាំតាមតម្រូវការ
- គ្រប់គ្រងកន្លែងប្រកបវិជ្ជាជីវៈទន្តសាស្ត្រឱ្យមានធនធានទន្តសាស្ត្រទូទៅគ្រប់គ្រាន់ក្នុងការផ្តល់សេវាប្រកបដោយគុណភាព និងសុវត្ថិភាព
- ផ្តល់ការត្រួតពិនិត្យនិងគាំទ្រជាវិជ្ជមានដល់បុគ្គលិកដែលបម្រើការងារនៅក្នុងកន្លែងប្រកបវិជ្ជាជីវៈទន្តសាស្ត្រ និងបង្កើតប្រព័ន្ធសុវត្ថិភាពនិងសុខភាពការងារ
- ផ្តួចផ្តើម អនុវត្ត និងវាយតម្លៃលើសកម្មភាពកែលម្អគុណភាពនៅកន្លែងប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ព្រមទាំងការស្ទាបស្ទង់មតិរបស់អតិថិជន ឬអ្នកជំងឺអំពីការផ្តល់សេវា
- ផ្តួចផ្តើមធ្វើការសិក្សាស្រាវជ្រាវដើម្បីរួមចំណែកបង្កើនប្រភពចំណេះដឹងទាក់ទងនឹងឯកទេសរបស់ខ្លួន និងប្រើប្រាស់លទ្ធផលចេញពីការសិក្សាស្រាវជ្រាវក្នុងការប្រតិបត្តិ
- ដឹកនាំ គ្រប់គ្រង និងរៀបចំគោលការណ៍ណែនាំគ្លីនិកពាក់ព័ន្ធ
- ផ្តល់ការណែនាំ បង្វឹក និងអភិវឌ្ឍឯកទេសនៅនឹងកន្លែងដល់ទន្តពេទ្យ ជំនួយការផ្នែកទន្តសាស្ត្រ និងនិស្សិតអន្តេវាសិកទន្តសាស្ត្រ

| | |
|---|---|
| -រៀបចំនិងដឹកនាំបង្រៀនទ្រឹស្តី អនុវត្តបង្ហាញគ្រាប់ ដឹកនាំកម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សានៅអង្គភាពរបស់ខ្លួន<br>-ចូលរួមជ្រើសរើសបុគ្គលិកដែលមានគុណវុឌ្ឍិនិងជំនាញដើម្បីបំពេញតម្រូវការពិនិត្យ ព្យាបាល និងថែទាំសុខភាពមាត់ធ្មេញរបស់អតិថិជន ឬអ្នកជំងឺ<br>-ផ្តល់ការអប់រំនិងបណ្តុះបណ្តាលជាទៀងទាត់អំពីការបង្ការ និងការគ្រប់គ្រងការចម្លងមេរោគដល់បុគ្គលិកទាំងអស់និងកំណត់បញ្ហាគ្រោះថ្នាក់នៃការចម្លងរោគទៅអតិថិជន ឬបុគ្គលិកក្នុងកន្លែងប្រកបវិជ្ជាជីវៈទន្តសាស្ត្រនិងចាត់វិធានការកែលម្អ<br>-ត្រួតពិនិត្យនិងវាយតម្លៃរាល់ឯកសារដែលបានកត់ត្រាទុកជាទម្រង់ក្រដាស ឬទម្រង់អេឡិចត្រូនិក ដើម្បីធានាឱ្យបាននូវឯកជនភាពទិន្នន័យ សុវត្ថិភាព និងការសម្ងាត់<br>-បង្កើតគម្រោង ពិនិត្យព្យាបាល ថែទាំសុខភាពមាត់ធ្មេញក្នុងផ្នែកឯកទេសរបស់ខ្លួនដោយផ្អែកលើលទ្ធផលវិទ្យាសាស្ត្រ<br>-ប្រាស្រ័យទាក់ទងជាមួយអតិថិជន ឬអ្នកជំងឺដែលត្រូវការពិនិត្យព្យាបាល និងថែទាំសុខភាពមាត់ធ្មេញ និងសហប្រតិបត្តិការជាមួយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦. គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ សញ្ញាបត្រទន្តបណ្ឌិតឯកទេស ឬសញ្ញាបត្របណ្ឌិតស្រាវជ្រាវផ្នែកទន្តវេទនសាស្ត្រ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ ទន្តវេទនសាស្ត្រ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-ចេះធ្វើការសិក្សាស្រាវជ្រាវក្នុងផ្នែកឯកទេសរបស់ខ្លួន<br>-មានសមត្ថភាពគ្រប់គ្រង និងដឹកនាំអង្គភាព<br>-មានគរុកោសល្យបង្ហាត់បង្រៀនក្នុងវិជ្ជាជីវៈសុខាភិបាល |

| | |
|---|---|
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | -ពិនិត្យព្យាបាលសុខភាពមាត់ធ្មេញដែលមានភាពស្មុគស្មាញប្រកបដោយគុណភាពនិងសុវត្ថិភាព<br>-ប្រើប្រាស់អនុវត្តវិធីសាស្ត្រកែលម្អគុណភាព<br>-ប្រតិបត្តិវិជ្ជាជីវៈផ្អែកលើលទ្ធផលស្រាវជ្រាវ<br>-មានសមត្ថភាពក្នុងការសម្រេចចិត្តលើការពិនិត្យព្យាបាល ថែទាំសុខភាព មាត់ធ្មេញ និងសេរីភាពក្នុងការប្រតិបត្តិវិជ្ជាជីវៈ ប្រកបដោយស្វ័យភាព<br>-ចេះសហការជាមួយអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រផ្សេងទៀត និងអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ<br>-មានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់ការប្រាស្រ័យទាក់ទងនានាក្នុងការប្រកបវិជ្ជាជីវៈ<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសឬបារាំង ឬភាសាផ្សេងទៀត បានយ៉ាងស្ទាត់ជំនាញ<br>-មានចំណេះដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌ទន្តពេទ្យ បទដ្ឋាននិងនិយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារ អង្គភាព និងជំនាញ<br>-ចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាថែទាំសុខាភិបាល និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-ចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារៈ<br>- ការពារសុចរិតភាពវិជ្ជាជីវៈ ឯករាជ្យភាពនិងសេចក្តីថ្លៃថ្នូរដោយរក្សាទំនុកចិត្ត និងភាពជឿជាក់លើវិជ្ជាជីវៈរបស់សាធារណជន<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ចូលរួមសកម្មភាពលើកកម្ពស់វិស័យទន្តសាស្ត្រទៅតាមការស្នើសុំរបស់ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ |

**១៣- ការពិពណ៌នាមុខតំណែងទន្តបណ្ឌិតជំនាញ** (**លេខកូដ** : PHE013)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | ទន្តបណ្ឌិតជំនាញ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

-ប្រមូលទិន្នន័យ ដែលទាក់ទងនឹងសេវាថែទាំសុខភាពមាត់ធ្មេញក្នុងសហគមន៍

-រៀបចំ និងគាំទ្រអនុវត្តកម្មវិធីអប់រំសុខភាពមាត់ធ្មេញក្នុងសហគមន៍

-ផ្តួចផ្តើម អនុវត្ត និងវាយតម្លៃលើសកម្មភាពកែលម្អគុណភាពនៅកន្លែងប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ព្រមទាំងការស្ទាបស្ទង់មតិរបស់អតិថិជន ឬអ្នកជំងឺអំពីការផ្តល់សេវាសុខភាពមាត់ធ្មេញ

-ផ្តួចផ្តើមធ្វើការសិក្សាស្រាវជ្រាវដើម្បីរួមចំណែកបង្កើនប្រកពចំណេះដឹងទាក់ទងនឹងការពិនិត្យ ព្យាបាលថែទាំសុខភាពមាត់ធ្មេញ និងប្រើប្រាស់លទ្ធផលចេញពីការសិក្សាស្រាវជ្រាវក្នុងការប្រតិបត្តិ

-រៀបចំនិងដឹកនាំបង្រៀនទ្រឹស្តី អនុវត្តបង្ហាញគ្រាប់ ដឹកនាំកម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សានៅអង្គភាពរបស់ខ្លួន

-ផ្តល់ការណែនាំ បង្វឹក និងអភិវឌ្ឍជំនាញនៅនឹងកន្លែងដល់ទន្តពេទ្យ ជំនួយការផ្នែកទន្តសាស្ត្រ និងនិស្សិតអន្តេវាសិកទន្តសាស្ត្រ

-ផ្តល់ការត្រួតពិនិត្យ និងគាំទ្រជាវិជ្ជមានដល់បុគ្គលិកដែលបម្រើការងារនៅក្នុងកន្លែងប្រកបវិជ្ជាជីវៈទន្តសាស្ត្រ និងបង្កើតប្រព័ន្ធសុវត្ថិភាពនិងសុខភាពការងារ

-គ្រប់គ្រងចាត់ចែងអង្គភាពឱ្យមានធនធានគ្រប់គ្រាន់ក្នុងការផ្តល់សេវាប្រកបដោយគុណភាព និងសុវត្ថិភាព និងជ្រើសរើសបុគ្គលិកដែលមានគុណវុឌ្ឍិនិងជំនាញដើម្បីបំពេញតម្រូវការក្នុងអង្គភាព

-ចាត់ចែងគ្រប់គ្រងស្ថានភាពសង្គ្រោះបន្ទាន់ដើម្បីការពារសុវត្ថិភាពរបស់អតិថិជន ឬអ្នកជំងឺ គ្រួសាររបស់ពួកគាត់ និងបុគ្គលិក

-ផ្តល់ការអប់រំនិងបណ្តុះបណ្តាលជាទៀងទាត់អំពីការបង្ការ និងការគ្រប់គ្រងការចម្លងមេរោគដល់បុគ្គលិកទាំងអស់ និងកំណត់បញ្ហាគ្រោះថ្នាក់នៃការចម្លងរោគទៅអតិថិជន ឬបុគ្គលិកក្នុងកន្លែងប្រកបវិជ្ជាជីវៈទន្តសាស្ត្រ និងចាត់វិធានការកែលម្អ

| | |
|---|---|
| -ត្រួតពិនិត្យនិងវាយតម្លៃរាល់ឯកសារដែលបានកត់ត្រាទុកជាទម្រង់ក្រដាស ឬទម្រង់អេឡិចត្រូនិក ដើម្បីធានាឱ្យបាននូវឯកជនភាពទិន្នន័យ សុវត្ថិភាព និងការសម្ងាត់<br>-រៀបចំនិងផ្តល់ព័ត៌មានជាក់លាក់អំពីសកម្មភាពបង្ការជំងឺមាត់ធ្មេញដល់អតិថិជន ឬអ្នកជំងឺដែលមានកត្តាប្រឈម<br>-ធ្វើការពិនិត្យ វាយតម្លៃអតិថិជន ឬអ្នកជំងឺដែលមានបញ្ហាសុខភាពមាត់ធ្មេញ<br>-ធ្វើរោគវិនិច្ឆ័យមាត់ធ្មេញដោយផ្អែកលើការវិភាគនិងបកស្រាយរបកគំហើញអមវេជ្ជសាស្ត្រ មន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ<br>-បង្កើតគម្រោង ពិនិត្យព្យាបាល និងថែទាំសុខភាពមាត់ធ្មេញដោយផ្អែកលើលទ្ធផលវិទ្យាសាស្ត្រ<br>-គោរពបទប្បញ្ញត្តិ ក្រមសីលធម៌ និងវិជ្ជាជីវៈទន្តពេទ្យឱ្យបានខ្ជាប់ខ្ជួន និងតាមដានអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រផ្សេងទៀតអំពីការគោរពតាមបទប្បញ្ញត្តិ ក្រមសីលធម៌ និងវិជ្ជាជីវៈទន្តពេទ្យ<br>-ប្រាស្រ័យទាក់ទងជាមួយអតិថិជន ឬអ្នកជំងឺដែលត្រូវការពិនិត្យព្យាបាល ថែទាំសុខភាពមាត់ធ្មេញ និងសហប្រតិបត្តិការជាមួយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង( គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង ) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ( ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ សញ្ញាបត្រទន្តបណ្ឌិតទូទៅ និងបរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ ទន្តវេទនសាស្ត្រ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ( អាចបំពេញបន្ថែមដោយអង្គភាព ) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពគ្រប់គ្រង និងដឹកនាំអង្គភាព<br>-ពិនិត្យព្យាបាលសុខភាពមាត់ធ្មេញប្រកបដោយគុណភាព និងសុវត្ថិភាព<br>-ប្រើប្រាស់អនុវត្តវិធីសាស្ត្រកែលម្អគុណភាព |

| | |
|---|---|
| | -ប្រតិបត្តិវិជ្ជាជីវៈផ្អែកលើលទ្ធផលស្រាវជ្រាវ<br>-មានសមត្ថភាពក្នុងការសម្រេចចិត្តលើការពិនិត្យព្យាបាល ថែទាំសុខភាពមាត់ធ្មេញ និងសេរីភាពក្នុងការប្រតិបត្តិវិជ្ជាជីវៈ ប្រកបដោយស្វ័យភាព<br>-សហការជាមួយអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រផ្សេងទៀត និងអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ<br>-មានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាឌីជីថល សម្រាប់ការប្រាស្រ័យទាក់ទងនានាក្នុងការប្រកបវិជ្ជាជីវៈ<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬភាសាបារាំង ឬភាសាផ្សេងទៀត បានយ៉ាងស្ទាត់ជំនាញ<br>-មានចំណេះដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌ទន្តពេទ្យ បទដ្ឋាននិងនិយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាពនិងជំនាញ<br>-ចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាថែទាំសុខាភិបាល និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-ចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារៈ<br>- ការពារសុចរិតភាពវិជ្ជាជីវៈ ឯករាជ្យភាពនិងសេចក្តីថ្លៃថ្នូរដោយរក្សាទំនុកចិត្ត និងភាពជឿជាក់លើវិជ្ជាជីវៈរបស់សាធារណជន<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ចូលរួមសកម្មភាពលើកកម្ពស់វិស័យទន្តសាស្ត្រទៅតាមការស្នើសុំរបស់ស្ថាប័នឬអង្គភាពពាក់ព័ន្ធ។ |

**១៤- ការពិពណ៌នាមុខតំណែងទន្តបណ្ឌិតទូទៅ** ( **លេខកូដ** : PHE014 )

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | ទន្តបណ្ឌិតទូទៅ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- ផ្តល់ការពិនិត្យព្យាបាល ថែទាំសុខភាពមាត់ធ្មេញ និងវាយតម្លៃអតិថិជន ឬអ្នកជំងឺដែលមានបញ្ហាសុខភាពមាត់ធ្មេញ
- ធ្វើរោគវិនិច្ឆ័យមាត់ធ្មេញដោយផ្អែកលើការវិភាគ និងបកស្រាយរបកគំហើញអមវេជ្ជសាស្ត្រ មន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ
- បង្កើតគម្រោង ពិនិត្យព្យាបាលថែទាំសុខភាពមាត់ធ្មេញដោយផ្អែកលើលទ្ធផលវិទ្យាសាស្ត្រ
- វាយតម្លៃកត្តាហានិភ័យរបស់អតិថិជន ឬអ្នកជំងឺអំពីជំងឺមាត់ធ្មេញ និងផ្តល់ព័ត៌មានអំពីវិធីបង្ការជាក់លាក់
- កត់ត្រាឯកសារអំពីសេវាកម្មព្យាបាលនិងថែទាំឱ្យបានលម្អិតដោយរក្សាឯកជនភាពទិន្នន័យ និងការសម្ងាត់
- ប្រកាន់ខ្ជាប់នូវបទប្បញ្ញត្តិនិងវិធានប្រតិបត្តិស្តីពីការបង្ការ និងគ្រប់គ្រងការចម្លងរោគនៅពេលផ្តល់ការពិនិត្យព្យាបាលនិងថែទាំសុខភាពមាត់ធ្មេញ
- សម្គាល់តម្រូវការសង្គ្រោះបន្ទាន់ដែលប៉ះពាល់ដល់អតិថិជន ឬអ្នកជំងឺ ឬសហសេវិក និងចាត់វិធានការឆ្លើយតបបន្ទាន់និងត្រូវបញ្ជូនទៅទន្តពេទ្យមានបទពិសោធ ឬអ្នកវិជ្ជាជីវៈសុខាភិបាលផ្សេង
- គោរពបទប្បញ្ញត្តិ ក្រមសីលធម៌ និងវិជ្ជាជីវៈទន្តពេទ្យឱ្យបានខ្ជាប់ខ្ជួន និងតាមដានអ្នកប្រកបវិជ្ជាជីវៈ ទន្តសាស្ត្រផ្សេងទៀតអំពីការគោរពតាមបទប្បញ្ញត្តិ ក្រមសីលធម៌ និងវិជ្ជាជីវៈទន្តពេទ្យ
- ប្រាស្រ័យទាក់ទងជាមួយអតិថិជន ឬអ្នកជំងឺដែលត្រូវការពិនិត្យព្យាបាល ថែទាំសុខភាពមាត់ធ្មេញ និងសហប្រតិបត្តិការជាមួយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត
- ចូលរួមជ្រោមជ្រែងសិក្សាស្រាវជ្រាវទាក់ទងនឹងការផ្តល់ការពិនិត្យ ព្យាបាល ថែទាំសុខភាពមាត់ធ្មេញ និងប្រើប្រាស់លទ្ធផលចេញពីការសិក្សាស្រាវជ្រាវក្នុងការប្រកបវិជ្ជាជីវៈទន្តសាស្ត្រ

| | |
|---|---|
| -រៀបចំ ដឹកនាំ បង្រៀនទ្រឹស្តី អនុវត្តបង្ហាញគ្រាប់ ដឹកនាំកម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សានៅអង្គភាពរបស់ខ្លួន<br>-ចូលរួមអភិវឌ្ឍនិងអនុវត្តសកម្មភាពដើម្បីកែលម្អគុណភាពផ្តល់សេវា<br>-បំពេញមុខងារគ្រប់គ្រងដឹកនាំក្នុងអង្គភាព<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ សញ្ញាបត្រទន្តបណ្ឌិតទូទៅ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ ទន្តវេទនសាស្ត្រ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-ពិនិត្យព្យាបាលសុខភាពមាត់ធ្មេញប្រកបដោយគុណភាព និងសុវត្ថិភាព<br>-ប្រើប្រាស់អនុវត្តវិធីសាស្ត្រកែលម្អគុណភាព<br>-ប្រតិបត្តិវិជ្ជាជីវៈផ្អែកលើលទ្ធផលស្រាវជ្រាវ<br>-មានសមត្ថភាពក្នុងការសម្រេចចិត្តលើការពិនិត្យព្យាបាល ថែទាំសុខភាពមាត់ធ្មេញ និងសេរីភាពក្នុងការប្រតិបត្តិវិជ្ជាជីវៈ ប្រកបដោយស្វ័យភាព<br>-សហការជាមួយអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រផ្សេងទៀត និងអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ<br>-មានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់ការប្រាស្រ័យទាក់ទងនានាក្នុងការប្រកបវិជ្ជាជីវៈ<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត បានយ៉ាងស្ទាត់ជំនាញ |

| | |
|---|---|
| | -មានចំណេះដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌ទន្តពេទ្យ បទដ្ឋាននិងនិយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាព និងជំនាញ<br>-ចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាថែទាំសុខាភិបាល និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-ចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- ការពារសុចរិតភាពវិជ្ជាជីវៈ ឯករាជ្យភាព និងសេចក្តីថ្លៃថ្នូរដោយរក្សាទំនុកចិត្តនិងភាពជឿជាក់លើវិជ្ជាជីវៈរបស់សាធារណជន<br>- គោរពវិន័យនិងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ចូលរួមសកម្មភាពលើកកម្ពស់វិស័យទន្តសាស្ត្រទៅតាមការស្នើសុំរបស់ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ។ |

## ១៥- ការពិពណ៌នាមុខតំណែងទន្តពេទ្យមធ្យម (លេខកូដ : PHE015)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | ទន្តពេទ្យមធ្យម |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- ចូលរួម ពិនិត្យព្យាបាល ថែទាំសុខភាពមាត់ធ្មេញ និងវាយតម្លៃអតិថិជន ឬអ្នកជំងឺដែលមានបញ្ហាសុខភាពមាត់ធ្មេញ
- ធ្វើរោគវិនិច្ឆ័យមាត់ធ្មេញដោយផ្អែកលើការវិភាគ និងបកស្រាយរបកគំហើញអមវេជ្ជសាស្ត្រ មន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ
- បង្កើតគម្រោង ពិនិត្យព្យាបាល និងថែទាំសុខភាពមាត់ធ្មេញដោយផ្អែកលើលទ្ធផលវិទ្យាសាស្ត្រ
- វាយតម្លៃកត្តាហានិភ័យរបស់អតិថិជន ឬអ្នកជំងឺ អំពីជំងឺមាត់ធ្មេញ និងផ្តល់ព័ត៌មានអំពីវិធីបង្ការជាក់លាក់
- កត់ត្រាឯកសារអំពីសេវាកម្មព្យាបាលនិងថែទាំឱ្យបានលម្អិតដោយរក្សាឯកជនភាពទិន្នន័យ និងការសម្ងាត់
- ប្រកាន់ខ្ជាប់នូវបទប្បញ្ញត្តិ និងវិធានប្រតិបត្តិស្តីពីការបង្ការ និងគ្រប់គ្រងការចម្លងរោគនៅពេលផ្តល់ការពិនិត្យព្យាបាលថែទាំសុខភាពមាត់ធ្មេញ
- សម្គាល់តម្រូវការសង្គ្រោះបន្ទាន់ដែលប៉ះពាល់ដល់អតិថិជន ឬអ្នកជំងឺ ឬសហសេវិក និងចាត់វិធានការឆ្លើយតបបន្ទាន់ និងត្រូវបញ្ជូនទៅទន្តពេទ្យមានបទពិសោធ ឬអ្នកវិជ្ជាជីវៈសុខាភិបាលផ្សេង
- គោរពបទប្បញ្ញត្តិ ក្រមសីលធម៌ និងវិជ្ជាជីវៈទន្តពេទ្យឱ្យបានខ្ជាប់ខ្ជួននិងតាមដានអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រផ្សេងទៀតអំពីការគោរពតាមបទប្បញ្ញត្តិ ក្រមសីលធម៌ និងវិជ្ជាជីវៈទន្តពេទ្យ
- ប្រាស្រ័យទាក់ទងជាមួយអតិថិជន ឬអ្នកជំងឺដែលត្រូវការពិនិត្យព្យាបាល ថែទាំសុខភាពមាត់ធ្មេញ និងសហប្រតិបត្តិការជាមួយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត
- ចូលរួមជ្រោមជ្រែងសិក្សាស្រាវជ្រាវទាក់ទងនឹងការផ្តល់ការពិនិត្យ ព្យាបាល ថែទាំសុខភាពមាត់ធ្មេញ និងប្រើប្រាស់លទ្ធផលចេញពីការសិក្សាស្រាវជ្រាវក្នុងការប្រកបវិជ្ជាជីវៈទន្តសាស្ត្រ
- ចូលរួមអភិវឌ្ឍនិងអនុវត្តសកម្មភាពដើម្បីកែលម្អគុណភាពផ្តល់សេវា
- អាចបំពេញមុខងារគ្រប់គ្រងដឹកនាំក្នុងអង្គភាព
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

| | |
|---|---|
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ សញ្ញាបត្រទន្តពេទ្យមធ្យម ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ ទន្តវេទនសាស្ត្រ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-ពិនិត្យព្យាបាលសុខភាពមាត់ធ្មេញប្រកបដោយគុណភាព និងសុវត្ថិភាព<br>-ប្រើប្រាស់អនុវត្តវិធីសាស្ត្រកែលម្អគុណភាព<br>-ប្រតិបត្តិវិជ្ជាជីវៈផ្អែកលើលទ្ធផលស្រាវជ្រាវ<br>-មានសមត្ថភាពក្នុងការសម្រេចចិត្តលើការពិនិត្យព្យាបាល ថែទាំសុខភាពមាត់ធ្មេញ និងសេរីភាពក្នុងការប្រតិបត្តិវិជ្ជាជីវៈ ប្រកបដោយស្វ័យភាព<br>-ចេះសហការជាមួយអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រផ្សេងទៀត និងអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ<br>-មានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាឌីជីថល សម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានចំណេះដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌ទន្តពេទ្យ បទដ្ឋាននិងនិយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារ អង្គភាព និងជំនាញ<br>-ចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាថែទាំសុខាភិបាល និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |

| | |
|---|---|
| | ឥរិយាបថបំពេញការងារ៖<br>- ការពារសុចរិតភាពវិជ្ជាជីវៈ ឯករាជ្យភាព និងសេចក្ដីថ្លៃថ្នូរដោយរក្សាទំនុកចិត្តនិងភាពជឿជាក់លើវិជ្ជាជីវៈរបស់សាធារណជន<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្ដីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ចូលរួមសកម្មភាពលើកកម្ពស់វិស័យទន្តសាស្ត្រទៅតាមការស្នើសុំរបស់ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ។ |

**១៦- ការពិពណ៌នាមុខតំណែងទន្តគិលានុបដ្ឋាកមធ្យម (លេខកូដ : PHE016)**

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | ទន្តគិលានុបដ្ឋាកមធ្យម |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- អនុវត្តបច្ចេកទេសនៃការផ្តល់សេវាថែទាំសុខភាពមាត់ធ្មេញជាមូលដ្ឋាន (BPOC) រួមមាន អនាម័យមាត់ធ្មេញ ការព្យាបាលបន្ទាន់ជំងឺមាត់ធ្មេញ (OUT) និងការប៉ះធ្មេញដោយដៃ (ART) ជូនដល់អ្នកជំងឺ និងសហគមន៍ដោយប្រើវិធីសាស្ត្រដោះស្រាយតាមស្ថានភាពជាក់ស្តែងជាមូលដ្ឋាន
- ពិគ្រោះយោបល់ជាមួយទន្តបណ្ឌិត ឬអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងៗទៀតនៅពេលដែលការថែទាំផ្នែកសុខភាពមាត់ធ្មេញតម្រូវឱ្យមានអ្នកជំនាញបច្ចេកទេសបន្ថែម
- អនុវត្តគោលការណ៍នៃការថែទាំសុខភាពមាត់ធ្មេញបឋមដើម្បីឆ្លើយតបទៅនឹងតម្រូវការសុខភាពមាត់ធ្មេញជាមូលដ្ឋាននៅសហគមន៍
- ធ្វើការប៉ាន់ប្រមាណដោយប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ស៊ីជម្រៅសមស្របទៅនឹងសុខភាពមាត់ធ្មេញអ្នកជំងឺ ឬស្ថានភាពរបស់អ្នកជំងឺ
- ធ្វើរោគវិនិច្ឆ័យនិងវិភាគទិន្នន័យដែលបានមកពីការប៉ាន់ប្រមាណដើម្បីកំណត់រករោគវិនិច្ឆ័យ ឬបញ្ហារបស់អ្នកជំងឺ និងកត់ត្រាភាពមិនប្រក្រតីរបស់អ្នកជំងឺ
- បង្កើតផែនការដោយកំណត់យុទ្ធសាស្ត្រថែទាំសុខភាពមាត់ធ្មេញជូនអ្នកជំងឺ និងកត់ត្រាផែនការដោយប្រើភាសាស្តង់ដារឬដោយប្រើពាក្យបច្ចេកទេស
- ធ្វើការអន្តរាគមន៍ដើម្បីថែទាំសុខភាពមាត់ធ្មេញដល់អ្នកជំងឺតាមផែនការដែលបានកំណត់ និងអនុវត្តផែនការថែទាំអ្នកជំងឺដែលបានកំណត់
- ធ្វើការវាយតម្លៃអំពីវឌ្ឍនភាពនៃលទ្ធផលការថែទាំដែលសម្រេចបានពីការអនុវត្តផែនការថែទាំដែលបានកំណត់
- អនុវត្តការងារប្រកបដោយសីលធម៌ និងផ្តល់ការថែទាំប្រាកដប្រជាដោយរក្សា ការបង្ការ ការគោរពសេចក្តីថ្លៃថ្នូរ សិទ្ធិ តម្លៃ ជំនឿ ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ និងសាសនារបស់អ្នកជំងឺ
- ចូលរួមក្នុងការងារបណ្តុះបណ្តាលបន្តដើម្បីបង្កើនសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនឱ្យបានជាប្រចាំសម្រាប់ អភិវឌ្ឍ និងរក្សាសមត្ថភាពរបស់ខ្លួនជានិច្ច
- ចូលរួមធ្វើការស្រាវជ្រាវនិងយកលទ្ធផលនៃការស្រាវជ្រាវដើម្បីធ្វើការផ្លាស់ប្តូរការអនុវត្តឱ្យបានសមស្រប
- ចូលរួមលើកកម្ពស់គុណភាពនៃការអនុវត្តការងារថែទាំអ្នកជំងឺជាប្រចាំ ការច្នៃប្រឌិត និងការបង្កើតវិធីសាស្ត្រថ្មីដើម្បីលើកកម្ពស់គុណភាពការថែទាំសុខភាពមាត់ធ្មេញអ្នកជំងឺ

| | |
|---|---|
| -ធ្វើទំនាក់ទំនងជាមួយអ្នកជំងឺ ក្រុមគ្រួសារ និងមន្ត្រីសុខាភិបាលដទៃទៀតដើម្បីធ្វើការប៉ាន់ប្រមាណពីជំនាញទំនាក់ទំនងរបស់ខ្លួនក្នុងពេលជួបសម្ភាសន៍អ្នកជំងឺ ក្រុមគ្រួសារ និងមន្ត្រីសុខាភិបាលដទៃទៀត<br>-កត់ត្រាពីសកម្មភាពថែទាំអ្នកជំងឺ<br>-បង្កើតផែនការស្តីពីការអប់រំនិងការលើកកម្ពស់សុខភាពមាត់ធ្មេញដោយកំណត់សកម្មភាពអន្តរាគមន៍ ដើម្បីសម្រេចលទ្ធផលរំពឹងទុក<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្ររង ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ ទន្តគិលានុបដ្ឋាក |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ (អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-ប្រើប្រាស់ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងទៅតាមស្ថានភាពឱ្យបានសមរម្យ<br>-ចេះប្រើប្រាស់ធនធានឱ្យបានសមរម្យក្នុងបំណងសម្រេចលទ្ធផលល្អនៃការថែទាំអ្នកជំងឺ<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រនិងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-ចូលរួមសហការជាមួយក្រុមការងារ និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌ទន្តគិលានុបដ្ឋាក និយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារ អង្គភាព និងជំនាញ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-ចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាថែទាំសុខាភិបាល និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |

| | |
|---|---|
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្ដីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

**១៧- ការពិពណ៌នាមុខតំណែងបណ្ឌិតសុខភាពសាធារណៈ (លេខកូដ : PHE017)**

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | បណ្ឌិតសុខភាពសាធារណៈ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង (អាចប្រែប្រួលទៅតាមជំនាញលម្អិតនីមួយៗ)

- កំណត់បញ្ហាសម្រាប់ស្រាវជ្រាវ( ទាំងបែបបរិមាណវិស័យ និងបែបគុណវិស័យ) និងបង្កើតកម្រងសំណួរស្រាវជ្រាវសមស្រប និងត្រឹមត្រូវទៅតាមបញ្ហាស្រាវជ្រាវ
- ប្រើប្រាស់ទ្រឹស្តី និងការយល់ឃើញដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រក្នុងការតាក់តែង និងអនុវត្តគម្រោងស្រាវជ្រាវសុខភាពសាធារណៈ
- ដឹកនាំ និងអនុវត្តជំនាញគ្រប់គ្រងការស្រាវជ្រាវឱ្យបានសមស្របទៅតាមបរិបទ
- ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានឱ្យបានសមស្របក្នុងការគ្រប់គ្រងទិន្នន័យ វិភាគ និងបង្ហាញលទ្ធផល
- សំយោគព័ត៌មានទាក់ទងនឹងការស្រាវជ្រាវ និងការអនុវត្តចេញពីប្រភពច្រើន ហើយវិភាគ និងវាយតម្លៃ របកគំហើញរបស់ខ្លួននិងរបស់អ្នកដទៃដោយការពិចារណាល្អិតល្អន់
- វិភាគ បកស្រាយទិន្នន័យបែបបរិមាណវិស័យ និងគុណវិស័យតាមស្តង់ដាវិទ្យាសាស្ត្រថ្មីៗ
- បង្កើតយុទ្ធសាស្ត្រកសាងសមត្ថភាពសម្រាប់បុគ្គល អង្គភាព និងសហគមន៍
- សរសេរគម្រោងស្រាវជ្រាវសម្រាប់ដាក់ស្នើសុំមូលនិធិ
- បង្កើតគោលនយោបាយសុខាភិបាលដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រ
- កំណត់យន្តការ និងបញ្ជ្រាបឥទ្ធិពលលើការសម្រេចចិត្តលើគោលនយោបាយ និងកម្មវិធីសុខាភិបាលដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រ
- រៀបចំបទអន្តរាគមន៍សុខាភិបាលដើម្បីផលប្រយោជន៍សហគមន៍ដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រ និងការយល់ដឹងពីវប្បធម៌របស់សហគមន៍
- វាយតម្លៃបញ្ហាទាក់ទងនឹងសុខភាពសហគមន៍ រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការលើកកម្ពស់សហគមន៍ និងសុខុមាលភាពប្រជាជនប្រកបដោយចីរភាព
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

| | |
|---|---|
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ សញ្ញាបត្របណ្ឌិត ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ សុខភាពសាធារណៈ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>- មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត បានយ៉ាងស្ទាត់ជំនាញ<br>-សហការជាមួយសហសេវិកនិងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹង និងប្រតិបត្តិច្បាប់ ក្រមសីលធម៌សុខភាពសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាពនិងជំនាញ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-ចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យនិងទំនួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ចូលរួមការងារជាមួយមន្ត្រី ឬអ្នកជំនាញសុខភាពសាធារណៈនៅក្នុងការអនុវត្តគម្រោងសុខភាពសាធារណៈ។ |

## ១៨- ការពិពណ៌នាមុខតំណែងមន្ត្រីជំនាញសុខភាពសាធារណៈជាន់ខ្ពស់ (លេខកូដ : PHE018)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | មន្ត្រីជំនាញសុខភាពសាធារណៈជាន់ខ្ពស់ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង(អាចប្រែប្រួលទៅតាមជំនាញលម្អិតនីមួយៗ)<br>-រៀបចំគោលគំនិតសុខភាពសាធារណៈ និងការអនុវត្តក្នុងបរិបទកម្ពុជា<br>-កំណត់វិធីសាស្ត្រផ្សេងៗនៃការកៀរគរធនធានសម្រាប់ការថែទាំសុខភាពបឋម<br>-បង្កើតផែនការកម្មវិធីវាយតម្លៃសុខភាព សំយោគលទ្ធផល និងសរសេររបាយការណ៍<br>-បង្កើតផែនការកម្មវិធីលើកកម្ពស់សុខភាព(សម្ភារៈអប់រំសុខភាពនានា) និងយុទ្ធសាស្ត្រក្នុងការវាយតម្លៃ<br>-កំណត់គោលការណ៍នៃការកសាងប្រព័ន្ធសុខាភិបាល និងដំណើរការនៃការអភិវឌ្ឍគោលនយោបាយសុខាភិបាល<br>-វាយតម្លៃប្រព័ន្ធសុខាភិបាលកម្ពុជា រួមទាំងសមធម៌សុខាភិបាល<br>-សិក្សាពីរបៀបដែលកត្តាសង្គម វប្បធម៌ ឥរិយាបថ និងបរិស្ថានមានឥទ្ធិពលដល់សុខភាពរបស់បុគ្គល សហគមន៍ និងប្រជាជន<br>-រៀបចំគម្រោងអភិវឌ្ឍសហគមន៍និងស្វែងរកភាពជាដៃគូសម្រាប់សុខភាពនិងការអភិវឌ្ឍសហគមន៍<br>-ធ្វើការស្រាវជ្រាវដើម្បីកំណត់បញ្ហាសហគមន៍<br>-ប្រើប្រាស់បច្ចេកវិទ្យាសុខាភិបាលឌីជីថល សុខាភិបាលព័ត៌មានវិទ្យា ការគ្រប់គ្រង និងការវិភាគទិន្នន័យ<br>-ដឹកនាំ និងគ្រប់គ្រងការធ្វើផែនការ និងអនុវត្តកម្មវិធីសុខាភិបាល<br>-ចូលរួមរៀបចំប្រព័ន្ធសុខាភិបាល និងយុទ្ធសាស្ត្រទប់ស្កាត់និងបង្ការជំងឺ<br>-បង្កើត និងអនុវត្តគម្រោងគ្រប់គ្រងគុណភាពសេវា<br>-ធ្វើការគ្រប់គ្រងសេដ្ឋកិច្ចសុខាភិបាល និងហិរញ្ញប្បទានសុខាភិបាល | |

- វាយតម្លៃបច្ចេកវិទ្យាសុខាភិបាលក្នុងការកំណត់តម្លៃ ឬផលប៉ះពាល់នៃបច្ចេកវិទ្យាសុខាភិបាល ឧបករណ៍និងបទអន្តរាគមន៍សុខាភិបាលដែលអាចប្រើប្រាស់ក្នុងប្រព័ន្ធសុខាភិបាល
- តាក់តែងនិងបង្កើតពិធីសារនៃការស្រាវជ្រាវឱ្យបានសមស្រប និងត្រឹមត្រូវសម្រាប់ការសិក្សាតាមបែបអេពីដេមីសាស្ត្រតាមរយៈការប្រើប្រាស់ទិន្នន័យជាបរិមាណ និង/ឬទិន្នន័យជាគុណវិស័យ
- សិក្សាស្រាវជ្រាវតាមបែបអេពីដេមីសាស្ត្ររាប់បញ្ចូលទាំងការបង្កើតកម្រងសំណួរ វិធីសាស្ត្រស្រាវជ្រាវ ការអនុវត្ត ការគ្រប់គ្រង ការវិភាគទិន្នន័យ និងការបកស្រាយលទ្ធផល
- ដឹកនាំការអង្កេតស្រាវជ្រាវការផ្ទុះជំងឺឡើងវិញ និងរៀបចំផែនការឆ្លើយតបទៅនឹងការរាតត្បាតនៃជំងឺឆ្លង
- រៀបចំគោលការណ៍អាហារូបត្ថម្ភភ្ជាប់ជាមួយនឹងយន្តការ ការផ្លាស់ប្តូរ តួនាទីនៅក្នុងរាងកាយ និងរបៀបដែលសារជាតុចិញ្ចឹមសំខាន់ៗមានឥទ្ធិពលដល់សុខភាព ជំងឺ តុល្យភាពនៃថាមពល និងតម្រូវការអាហារូបត្ថម្ភ
- រៀបចំគោលគំនិតយុទ្ធសាស្ត្រ និងវិធីសាស្ត្រសំខាន់ៗក្នុងការគ្រប់គ្រងគ្រឹះស្ថានសុខាភិបាល រួមមានមណ្ឌលសុខភាពនិងមន្ទីរពេទ្យ
- តាក់តែង អនុវត្ត និងវាយតម្លៃលើទិដ្ឋភាពផ្សេងៗនៃការគ្រប់គ្រងរដ្ឋបាលគ្រឹះស្ថានសុខាភិបាល រួមមាន មណ្ឌលសុខភាព និងមន្ទីរពេទ្យ
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

៦- គុណវុឌ្ឍិសម្រាប់មុខតំណែង( គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង)

៦.១. ក្របខ័ណ្ឌ ឋាននន្តរសក្តិ( ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន)

| | |
|---|---|
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ សុខភាពសាធារណៈ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រនិងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា |

| | |
|---|---|
| | -មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត បានយ៉ាងស្ទាត់ជំនាញ<br>-ចេះសហការជាមួយសហសេវិកនិងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌សុខភាពសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាពនិងជំនាញ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទំនួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ ចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- មានសុខភាពល្អ<br>- ចូលរួមការងារជាមួយមន្ត្រី ឬអ្នកជំនាញសុខភាពសាធារណៈនៅក្នុងការអនុវត្តគម្រោងសុខភាពសាធារណៈ។ |

## ១៩- ការពិពណ៌នាមុខតំណែងមន្ត្រីជំនាញសុខភាពសាធារណៈ (លេខកូដ : PHE019)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | មន្ត្រីជំនាញសុខភាពសាធារណៈ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖ (ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង(អាចប្រែប្រួលទៅតាមជំនាញលម្អិតនីមួយៗ)<br>-រៀបចំកម្មវិធី និងប្រធានបទអប់រំពីវិទ្យាសាស្ត្រសុខាភិបាលរួមមានសុខភាពមនុស្ស និងស្ថានភាពជំងឺ<br>-កំណត់បាននូវលក្ខខណ្ឌទាក់ទងនឹងសុខភាព និងបទអន្តរាគមន៍ដែលអាចធ្វើទៅបានសម្រាប់បញ្ហាសុខភាព<br>-រៀបចំអនុវត្តបទអន្តរាគមន៍សុខភាពសាធារណៈ និងស្រាវជ្រាវផ្សេងៗដោយសហការជាមួយអ្នកជំនាញសុខាភិបាលផ្សេងទៀត<br>-ធ្វើការងារគ្រប់គ្រងនិងការងាររដ្ឋបាលឱ្យមានប្រសិទ្ធភាព<br>-ចូលរួមផ្ដល់យោបល់លើគន្លឹះនៃការគ្រប់គ្រងមុខងារដូចជា ការគ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រងហិរញ្ញវត្ថុនិងទីផ្សារ ការគ្រប់គ្រងប្រព័ន្ធព័ត៌មានសុខាភិបាល ការគ្រប់គ្រងសេវាសុខាភិបាល ការសិក្សាស្រាវជ្រាវ និងអង្កេតតាមដានជំងឺ<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រសុខភាពសាធារណៈ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ សុខភាពសាធារណៈ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |

| | |
|---|---|
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត បានយ៉ាងស្ទាត់ជំនាញ<br>-ចេះសហការជាមួយក្រុមការងារ និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹង និងប្រតិបត្តិច្បាប់ ក្រមសីលធម៌សុខភាពសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាពនិងជំនាញ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ ចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ចូលរួមការងារជាមួយមន្ត្រី ឬអ្នកជំនាញសុខភាពសាធារណៈនៅក្នុងការអនុវត្តគម្រោងសុខភាពសាធារណៈ។ |

## ២០- ការពិពណ៌នាមុខតំណែងមន្ត្រីបច្ចេកទេសសុខភាពសាធារណៈ (លេខកូដ : PHE020)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | មន្ត្រីបច្ចេកទេសសុខភាពសាធារណៈ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ<br>-អប់រំសុខភាពតាមសហគមន៍ និងអនុវត្តគម្រោងសុខភាពសាធារណៈផ្សេងៗ<br>-ប្រមូលទិន្នន័យសុខាភិបាលនៅតាមសហគមន៍ និងនៅតាមគ្រឹះស្ថានផ្ដល់សេវាសុខភាព<br>-ធ្វើរបាយការណ៍សកម្មភាពប្រចាំថ្ងៃដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានសុខាភិបាល<br>-ធ្វើជាជនបង្គោលសុខភាពនៅក្នុងសហគមន៍<br>-សម្របសម្រួលការងារជាមួយអាជ្ញាធរសម្រាប់ការងារអប់រំសុខភាព បង្ការជំងឺ និងលើកកម្ពស់សុខភាព<br>-ចូលរួមរាយការណ៍ពីករណីជំងឺឆ្លងនិងអនុវត្តការឆ្លើយតបទៅនឹងជំងឺឆ្លង ឬគ្រោះមហន្តរាយសុខភាពសាធារណៈ ឬធម្មជាតិ<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណៈសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រៈ បរិញ្ញាបត្ររងសុខភាពសាធារណៈ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេសៈ សុខភាពសាធារណៈ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |

| | |
|---|---|
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-ចេះសហការជាមួយក្រុមការងារ និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹងគោលនយោបាយសុខាភិបាល ក្រមសីលធម៌សុខភាពសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាព និងជំនាញ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- ចូលរួមការងារជាមួយមន្ត្រី ឬអ្នកជំនាញសុខភាពសាធារណៈនៅក្នុងការអនុវត្តគម្រោងសុខភាពសាធារណៈ។ |

## ២១- ការពិពណ៌នាមុខតំណែងគិលានុបដ្ឋាកបណ្ឌិត (លេខកូដ : PHE021)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គិលានុបដ្ឋាកបណ្ឌិត |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ<br>- ផ្តល់ការថែទាំអ្នកជំងឺកម្រិតខ្ពស់ ជាពិសេសជំនាញឯកទេសប្រកបដោយគុណភាព និងសុវត្ថិភាពខ្ពស់<br>- ធ្វើការស្រាវជ្រាវដើម្បីកែលម្អការអនុវត្តនិងលទ្ធផលនៃការថែទាំសុខភាព<br>- ចូលរួមក្នុងការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ និងរួមចំណែកផ្តល់ចំណេះដឹងផ្នែកមូលដ្ឋានគ្រឹះនៃវិទ្យាសាស្ត្រថែទាំ<br>- ធ្វើការកែលម្អការអនុវត្តការងារថែទាំឱ្យបានប្រសើរឡើងដោយប្រើប្រាស់លទ្ធផលនៃការស្រាវជ្រាវ<br>- ចូលរួមរៀបចំកម្មវិធីសិក្សា និងធ្វើការអប់រំបណ្តុះបណ្តាលដល់និស្សិតនៅតាមគ្រឹះស្ថានបណ្តុះបណ្តាល វិស័យសុខាភិបាល<br>- ចូលរួមសកម្មភាពបង្រៀនដល់កម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សាក្នុងមូលដ្ឋានសុខាភិបាលដែលខ្លួនកំពុងបម្រើការងារ<br>- ចូលរួមរៀបចំ និងផ្តល់យោបល់លើគោលនយោបាយថែទាំសុខភាព<br>- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់អង្គភាព<br>- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រៈ សញ្ញាបត្របណ្ឌិត ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេសៈ បណ្ឌិតទស្សនៈវិជ្ជា ឬបណ្ឌិតគ្លីនិក |

| | |
|---|---|
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>- មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>- មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត បានយ៉ាងស្ទាត់ជំនាញ<br>- មានចំណេះដឹងការងារគ្រប់គ្រងទិន្នន័យនិងព័ត៌មាន<br>- ចេះរៀបចំវិធីសាស្ត្រស្រាវជ្រាវ និងរៀបចំឯកសារវិទ្យាសាស្ត្រសម្រាប់ធ្វើការបោះពុម្ព<br>- មានសមត្ថភាពរៀបចំគម្រោងស្រាវជ្រាវ និងស្វែងរកថវិកា<br>- មានសមត្ថភាពធ្វើការវិភាគ និងបង្កើតគំនិតច្នៃប្រឌិតប្រកបដោយនវានុវត្តន៍<br>- មានសមត្ថភាពបង្កើតទ្រឹស្តីថ្មី ឬគំរូសម្រាប់អនុវត្តដើម្បីធ្វើឱ្យប្រសើរឡើងលើការងារថែទាំ<br>- មានសមត្ថភាពធ្វើការឆ្លើយតបទៅនឹងការផ្លាស់ប្តូរ<br>- មានសមត្ថភាពបង្កើតវិធីសាស្ត្រតាមដាន និងត្រួតពិនិត្យវឌ្ឍនភាព ព្រមទាំងធ្វើការកែតម្រូវនៅពេលចាំបាច់<br>- មានសមត្ថភាពបង្កើតផែនការសម្រាប់អនុវត្ត<br>- មានសមត្ថភាពធ្វើការវាយតម្លៃគុណភាព<br>- មានសមត្ថភាពវិភាគដើម្បីស្វែងយល់ដឹងពីភាគីពាក់ព័ន្ធ<br>- មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ ចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

## ២២- ការពិពណ៌នាមុខតំណែងគិលានុបដ្ឋាកជាន់ខ្ពស់ (លេខកូដ : PHE022)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គិលានុបដ្ឋាកជាន់ខ្ពស់ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖

- ផ្តល់សេវាថែទាំបឋម និងឯកទេសកម្រិតខ្ពស់(ប្រើថ្នាំសន្លប់មុនពេល អំឡុងពេល និងក្រោយពេលវះកាត់) ពិនិត្យរាងកាយ ធ្វើរោគវិនិច្ឆ័យថែទាំ និងធ្វើអន្តរាគមន៍ថែទាំសម្រាប់អ្នកជំងឺក្នុងស្ថានភាពសុខភាពស្មុគស្មាញនិងរ៉ាំរ៉ៃ
- ផ្តល់ប្រឹក្សានិងណែនាំដល់គិលានុបដ្ឋាកដោយប្រើប្រាស់ទ្រឹស្តីនៃការថែទាំក្នុងការធ្វើការប៉ាន់ប្រមាណដោយប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ស៊ីជម្រៅសមស្របទៅនឹងសុខភាពអ្នកជំងឺ ឬស្ថានភាពរបស់អ្នកជំងឺ សុខភាពផ្លូវកាយ ផ្លូវចិត្ត សង្គម និងជំនឿសាសនា
- ជួយបកស្រាយដល់គិលានុបដ្ឋាកក្នុងការវិភាគទិន្នន័យដែលបានមកពីការប៉ាន់ប្រមាណដើម្បីកំណត់រករោគវិនិច្ឆ័យ ឬបញ្ហារបស់អ្នកជំងឺក្នុងករណីគិលានុបដ្ឋាកមិនអាចធ្វើបាន
- ជួយពិនិត្យមើលការបង្កើតផែនការដោយកំណត់សកម្មភាពអន្តរាគមន៍ថែទាំអ្នកជំងឺនិងកត់ត្រាផែនការដោយប្រើភាសាស្តង់ដា ឬដោយប្រើពាក្យបច្ចេកទេសក្នុងករណីគិលានុបដ្ឋាកមិនអាចធ្វើបាន
- ជួយផ្តល់ប្រឹក្សា ឬកែសម្រួលសកម្មភាពអន្តរាគមន៍ថែទាំអ្នកជំងឺតាមផែនការថែទាំអ្នកជំងឺដែលបានកំណត់ក្នុងករណីគិលានុបដ្ឋាកមិនអាចធ្វើបាន
- ជួយដល់គិលានុបដ្ឋាកធ្វើការវាយតម្លៃអំពីវឌ្ឍនភាពនៃលទ្ធផលការថែទាំដែលសម្រេចបានពីការអនុវត្តផែនការថែទាំក្នុងករណីធ្ងន់ធ្ងរ
- ចូលរួមក្នុងក្រុមអន្តរវិជ្ជាជីវៈសុខាភិបាលដើម្បីដោះស្រាយការប្រឈមផ្នែកបច្ចេកទេស និងក្រុមសីលធម៌វិជ្ជាជីវៈ
- ចូលរួមរៀបចំកម្មវិធីសិក្សា ការបណ្តុះបណ្តាលបន្ត និងធ្វើការវាយតម្លៃពីតម្រូវការបណ្តុះបណ្តាលបន្តដើម្បីបង្កើនសមត្ថភាពវិជ្ជាជីវៈគិលានុបដ្ឋាក
- ចូលរួមសកម្មភាពបង្រៀនដល់កម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សាក្នុងមូលដ្ឋានសុខាភិបាលដែលខ្លួនកំពុងបម្រើការងារ
- ចូលរួមនិងដឹកនាំធ្វើការស្រាវជ្រាវ និងយកលទ្ធផលនៃការស្រាវជ្រាវដើម្បីធ្វើការផ្លាស់ប្តូរការអនុវត្តឱ្យបានសមស្រប

| | |
|---|---|
| -ចូលរួមនិងដឹកនាំការបង្កើនគុណភាពនៃការអនុវត្ត និងការវិភាគទិន្នន័យគុណភាពដើម្បីកំណត់ពីកាលានុវត្តភាពក្នុងការលើកកម្ពស់ការអនុវត្តការថែទាំ<br>-ច្នៃប្រឌិតគំរូទំនាក់ទំនងជាមួយអ្នកជំងឺ ក្រុមគ្រួសារ និងមន្ត្រីសុខាភិបាលដទៃទៀតឱ្យមានប្រសិទ្ធភាព<br>-ជួយសម្របសម្រួលក្នុងការថែទាំ រួមបញ្ចូលចំណេះដឹងវិទ្យាសាស្ត្រ ភស្តុតាងល្អៗ និងការវិនិច្ឆ័យរបស់អ្នកជំនាញដើម្បីណែនាំការអនុវត្តឱ្យមានប្រសិទ្ធភាព<br>-បង្កើតផែនការស្តីពីការអប់រំ និងការលើកកម្ពស់សុខភាពដោយកំណត់សកម្មភាពអន្តរាគមន៍ដើម្បីសម្រេចលទ្ធផលរំពឹងទុក<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្លីនិកថែទាំ ឬបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកថែទាំផ្សេងទៀត |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត បានយ៉ាងស្ទាត់ជំនាញ<br>-មានសមត្ថភាពប្រើប្រាស់ភាពជាអ្នកដឹកនាំគ្រប់គ្រង និងបំពេញមុខងារក្នុងដែនត្រួតពិនិត្យ ដើម្បីបង្កើតបរិស្ថានការងារវិជ្ជមាន<br>-មានសមត្ថភាពប្រើប្រាស់ធនធានប៉ាន់ប្រមាណតម្រូវការនៃការថែទាំរបស់អ្នកទទួលសេវាជាលក្ខណៈបុគ្គល និងប៉ាន់ប្រមាណធនធានដែលមានស្រាប់ដើម្បី សម្រេចលទ្ធផលរំពឹងទុក<br>-ចេះប្រើប្រាស់កុំព្យូទ័រនិងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានសមត្ថភាពដឹកនាំប្រើកម្មវិធីវិភាគទិន្នន័យវិទ្យាសាស្ត្រកម្រិតមូលដ្ឋាន |

| | |
|---|---|
| | -ចេះសហការជាមួយក្រុមការងារ និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌គិលានុបដ្ឋាក និយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាព និងជំនាញ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-ចូលរួមជាមួយសហគមន៍ក្នុងការផ្ដល់សេវាថែទាំសុខាភិបាល និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្ដីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

## ២៣- ការពិពណ៌នាមុខតំណែងគិលានុបដ្ឋាកបរិញ្ញាបត្រ (លេខកូដ : PHE023)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖

-ប្រើប្រាស់កស្តុតាងបច្ចេកទេសនៃការប៉ាន់ប្រមាណសម្ភារៈ និងឧបករណ៍ផ្សេងៗទៀតឱ្យបានសមរម្យ

-ធ្វើរោគវិនិច្ឆ័យ ជួយបុគ្គលិកក្នុងការអភិវឌ្ឍ និងរក្សាសមត្ថភាពក្នុងដំណើរការធ្វើរោគវិនិច្ឆ័យ

-ធ្វើផែនការជ្រើសរើស ឬរៀបចំយុទ្ធសាស្ត្រដើម្បីបំពេញតម្រូវការជាច្រើននៃភាពស្មុគស្មាញរបស់អ្នកជំងឺ

-អន្តរាគមន៍ ប្រើប្រាស់អន្តរាគមន៍ផ្អែកលើស្តុតាង និងព្យាបាលជាក់លាក់ រោគវិនិច្ឆ័យ ឬបញ្ហារបស់អ្នកជំងឺ

-ធ្វើការវាយតម្លៃ ធ្វើការសំយោគលើលទ្ធផលនៃការវាយតម្លៃដើម្បីកំណត់ប្រសិទ្ធភាពផែនការចំពោះ អ្នកជំងឺ ក្រុមគ្រួសារ ក្រុមសហគមន៍ និងស្ថាប័នផ្សេងៗ

-ចូលរួមក្នុងក្រុមអន្តរវិជ្ជាជីវៈសុខាភិបាល ដើម្បីដោះស្រាយការប្រឈមផ្អែកបច្ចេកទេស និងក្រមសីលធម៌វិជ្ជាជីវៈ

-ចូលរួមធ្វើការស្រាវជ្រាវ និងយកលទ្ធផលនៃការស្រាវជ្រាវដើម្បីធ្វើការផ្លាស់ប្តូរការអនុវត្តឱ្យបានសមស្រប

-ចូលរួមបង្កើនគុណភាពនៃការអនុវត្ត និងវិភាគទិន្នន័យគុណភាពដើម្បីកំណត់ពីឱកាសក្នុងការលើកកម្ពស់ការអនុវត្តការថែទាំ

-ផ្តួចផ្តើមបង្កើតនិងបញ្ចប់ការទំនាក់ទំនងការព្យាបាល និងអន្តរជំនាញទំនាក់ទំនងមានប្រសិទ្ធភាពខ្ពស់

-សម្របសម្រួលក្នុងការថែទាំនិងកត់ត្រាអំពីការសម្របសម្រួលការថែទាំអ្នកជំងឺ

-បង្កើតផែនការស្តីពីការអប់រំនិងការលើកកម្ពស់សុខភាពដោយកំណត់សកម្មភាពអន្តរាគមន៍ ដើម្បីសម្រេចលទ្ធផលរំពឹងទុក

-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង)

៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន)

| | |
|---|---|
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រគិលានុបដ្ឋាក ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ គិលានុបដ្ឋាកទូទៅ ឬចក្ខុគិលានុបដ្ឋាក ឬគិលានុបដ្ឋាកដាក់ថ្នាំសណ្តំ ឬជំនាញគិលានុបដ្ឋាកផ្សេងៗទៀត |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៣. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានសមត្ថភាពប្រើប្រាស់ភាពជាអ្នកដឹកនាំគ្រប់គ្រងនិងបំពេញមុខងារក្នុងដែនត្រួតពិនិត្យដើម្បីបង្កើតបរិស្ថានការងារវិជ្ជមាន<br>-មានសមត្ថភាពប្រើប្រាស់ធនធានប៉ាន់ប្រមាណតម្រូវការនៃការថែទាំរបស់អ្នកទទួលសេវាជាលក្ខណៈបុគ្គល និងប៉ាន់ប្រមាណធនធានដែលមានស្រាប់ដើម្បីសម្រេចលទ្ធផលរំពឹងទុក<br>-មានសមត្ថភាពដឹកនាំប្រើកម្មវិធីវិភាគទិន្នន័យវិទ្យាសាស្ត្រកម្រិតមូលដ្ឋាន<br>-ចូលរួមសហការជាមួយក្រុមការងារ និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌គិលានុបដ្ឋាក និយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាព និងជំនាញ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-ចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាថែទាំសុខាភិបាល និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ<br>-មានចំណេះដឹងនិងជំនាញផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |

| | |
|---|---|
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

## ២៤- ការពិពណ៌នាមុខតំណែងគិលានុបដ្ឋាកមធ្យម (លេខកូដ : PHE024)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គិលានុបដ្ឋាកមធ្យម |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- ធ្វើការប៉ាន់ប្រមាណដោយប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ស៊ីជម្រៅសមស្របទៅនឹងសុខភាពអ្នកជំងឺឬស្ថានភាពរបស់អ្នកជំងឺ សុខភាពផ្លូវកាយ ផ្លូវចិត្ត សង្គម និងជំនឿសាសនា
- ធ្វើរោគវិនិច្ឆ័យ វិភាគទិន្នន័យដែលបានមកពីការប៉ាន់ប្រមាណដើម្បីកំណត់រករោគវិនិច្ឆ័យ ឬបញ្ហារបស់អ្នកជំងឺ និងកត់ត្រាភាពមិនប្រក្រតីរបស់អ្នកជំងឺ
- បង្កើតផែនការដោយកំណត់យុទ្ធសាស្ត្រថែទាំអ្នកជំងឺ និងកត់ត្រាផែនការដោយប្រើភាសាស្តង់ដាឬដោយប្រើពាក្យបច្ចេកទេស
- ធ្វើអន្តរាគមន៍ដើម្បីថែទាំអ្នកជំងឺតាមផែនការដែលបានកំណត់ និងការអនុវត្តផែនការថែទាំអ្នកជំងឺដែលបានកំណត់
- ធ្វើការវាយតម្លៃអំពីវឌ្ឍនភាពនៃលទ្ធផលការថែទាំដែលសម្រេចបានពីការអនុវត្តផែនការថែទាំដែលបានកំណត់
- អនុវត្តការងារប្រកបដោយសីលធម៌ ត្រូវផ្តល់ការថែទាំប្រាកដប្រជាដោយរក្សា ការបង្ការ ការគោរពសេចក្តីថ្លៃថ្នូរ សិទ្ធិ តម្លៃ ជំនឿ ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ និងសាសនារបស់អ្នកជំងឺ
- ចូលរួមបណ្តុះបណ្តាលបន្តដើម្បីបង្កើនសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនជាប្រចាំដើម្បីអភិវឌ្ឍនិងរក្សាសមត្ថភាពរបស់ខ្លួនជានិច្ច
- ចូលរួមធ្វើការស្រាវជ្រាវនិងយកលទ្ធផលនៃការស្រាវជ្រាវដើម្បីធ្វើការផ្លាស់ប្តូរការអនុវត្តឱ្យបានសមស្រប
- ចូលរួមលើកកម្ពស់គុណភាពនៃការអនុវត្តការងារថែទាំអ្នកជំងឺជាប្រចាំ ការច្នៃប្រឌិត និង បង្កើតវិធីសាស្ត្រថ្មីដើម្បីលើកកម្ពស់គុណភាពការថែទាំអ្នកជំងឺ
- ធ្វើទំនាក់ទំនងជាមួយអ្នកជំងឺ ក្រុមគ្រួសារ និងមន្ត្រីសុខាភិបាលដទៃទៀតដើម្បីធ្វើការប៉ាន់ប្រមាណពីជំនាញទំនាក់ទំនងរបស់ខ្លួនក្នុងពេលជួបសម្ភាសន៍ជាមួយអ្នកជំងឺ ក្រុមគ្រួសារ និងមន្ត្រីសុខាភិបាលដទៃទៀត
- កត់ត្រាពីសកម្មភាពថែទាំអ្នកជំងឺ
- បង្កើតផែនការស្តីពីការអប់រំនិងការលើកកម្ពស់សុខភាពដោយកំណត់សកម្មភាពអន្តរាគមន៍ដើម្បីសម្រេចលទ្ធផលរំពឹងទុក
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

| | |
|---|---|
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្ររងគិលានុបដ្ឋាក ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ គិលានុបដ្ឋាកទូទៅ ឬចក្ខុគិលានុបដ្ឋាក ឬជំនាញគិលានុបដ្ឋាកផ្សេងៗទៀត |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងទៅតាមស្ថានភាពឱ្យបានសមរម្យ<br>-មានសមត្ថភាពប្រើប្រាស់ធនធានឱ្យបានសមរម្យក្នុងបំណងសម្រេចលទ្ធផលល្អនៃការថែទាំអ្នកជំងឺ<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានសមត្ថភាពចូលរួមសហការជាមួយក្រុមការងារ និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-មានសមត្ថភាពយល់ដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌គិលានុបដ្ឋាក និយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារ អង្គភាព និង ជំនាញ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានសមត្ថភាពចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាថែទាំសុខាភិបាល និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |

| | |
|---|---|
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្ដីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រនិងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ននិងសមធម៌សង្គម។ |

## ២៥- ការពិពណ៌នាមុខតំណែងគិលានុបដ្ឋាកបឋម (លេខកូដ : PHE025)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | គិលានុបដ្ឋាកបឋម |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖ (ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖<br>-ជួយធ្វើការប៉ាន់ប្រមាណដោយប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ស៊ីជម្រៅសមស្របទៅនឹងសុខភាពអ្នកជំងឺឬស្ថានភាពរបស់អ្នកជំងឺ សុខភាពផ្លូវកាយ ផ្លូវចិត្ត សង្គម និងជំនឿសាសនា<br>-ជួយធ្វើរោគវិនិច្ឆ័យ វិភាគទិន្នន័យដែលបានមកពីការប៉ាន់ប្រមាណដើម្បីកំណត់រករោគវិនិច្ឆ័យ ឬបញ្ហារបស់អ្នកជំងឺ និងកត់ត្រាភាពមិនប្រក្រតីរបស់អ្នកជំងឺ<br>-ជួយបង្កើតផែនការដោយកំណត់យុទ្ធសាស្ត្រថែទាំអ្នកជំងឺ និងកត់ត្រាផែនការដោយប្រើភាសាស្តង់ដាឬដោយប្រើពាក្យបច្ចេកទេស<br>-ជួយធ្វើការអន្តរាគមន៍ដើម្បីថែទាំអ្នកជំងឺតាមផែនការដែលបានកំណត់ ការអនុវត្តផែនការថែទាំអ្នកជំងឺដែលបានកំណត់<br>-ជួយធ្វើការវាយតម្លៃអំពីវឌ្ឍនភាពនៃលទ្ធផលការថែទាំដែលសម្រេចបានពីការអនុវត្តផែនការថែទាំដែលបានកំណត់<br>-ចូលរួមអនុវត្តការងារប្រកបដោយសីលធម៌ ត្រូវផ្តល់ការថែទាំប្រាកដប្រជាដោយរក្សា ការបង្ការ ការគោរព សេចក្តីថ្លៃថ្នូរ សិទ្ធិ តម្លៃ ជំនឿ ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ និងសាសនារបស់អ្នកជំងឺ<br>-ចូលរួមបណ្តុះបណ្តាលបន្តដើម្បីបង្កើនសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនឱ្យបានជាប្រចាំ ដើម្បីអភិវឌ្ឍនិងរក្សាសមត្ថភាពរបស់ខ្លួនជានិច្ច<br>-ចូលរួមលើកកម្ពស់គុណភាពនៃការអនុវត្តការងារថែទាំអ្នកជំងឺជាប្រចាំ ការច្នៃប្រឌិត និងបង្កើតវិធីសាស្ត្រថ្មីដើម្បីលើកកម្ពស់គុណភាពការថែទាំអ្នកជំងឺ<br>-ជួយធ្វើទំនាក់ទំនងជាមួយអ្នកជំងឺ ក្រុមគ្រួសារ និងមន្ត្រីសុខាភិបាលដទៃទៀតដើម្បីធ្វើការប៉ាន់ប្រមាណពីជំនាញទំនាក់ទំនងរបស់ខ្លួនក្នុងពេលជួបសម្ភាសន៍អ្នកជំងឺ ក្រុមគ្រួសារ និងមន្ត្រីសុខាភិបាលដទៃទៀត<br>-ជួយកត់ត្រាពីសកម្មភាពថែទាំអ្នកជំងឺ<br>-ជួយបង្កើតផែនការស្តីពីការអប់រំនិងការលើកកម្ពស់សុខភាពដោយកំណត់សកម្មភាពអន្តរាគមន៍ដើម្បីសម្រេចលទ្ធផលរំពឹងទុក<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង (គុណសម្បត្តិស័ក្តិសម/លក្ខណៈសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |

| | |
|---|---|
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ( ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ សញ្ញាបត្រគិលានុបដ្ឋាកបឋម ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ ថែទាំវេជ្ជសាស្ត្រ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ( អាចបំពេញបន្ថែមដោយអង្គភាព ) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់ធនធានឱ្យបានសមរម្យក្នុងបំណងសម្រេចលទ្ធផលល្អនៃការថែទាំអ្នកជំងឺ<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានសមត្ថភាពចូលរួមសហការជាមួយក្រុមការងារ និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-មានសមត្ថភាពយល់ដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌គិលានុបដ្ឋាក និយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាព និងជំនាញ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានសមត្ថភាពចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាថែទាំសុខាភិបាល និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម |

## ២៦- ការពិពណ៌នាមុខតំណែងមន្ត្រីបច្ចេកទេសថែទាំនិងអមវេជ្ជសាស្ត្របឋម (លេខកូដ : PHE026)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | មន្ត្រីបច្ចេកទេសថែទាំនិងអមវេជ្ជសាស្ត្របឋម |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖

- ជួយធ្វើការប៉ាន់ប្រមាណដោយប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ស៊ីជម្រៅសមស្របទៅនឹងសុខភាពអ្នកជំងឺឬស្ថានភាពរបស់អ្នកជំងឺ សុខភាពផ្លូវកាយ ផ្លូវចិត្ត សង្គម និងជំនឿសាសនា
- ជួយប្រមូលទិន្នន័យ ដែលបានមកពីការប៉ាន់ប្រមាណដើម្បីកំណត់រករោគវិនិច្ឆ័យ ឬបញ្ហារបស់អ្នកជំងឺ និងកត់ត្រាភាពមិនប្រក្រតីរបស់អ្នកជំងឺ
- ជួយបង្កើតផែនការដោយកំណត់យុទ្ធសាស្ត្រថែទាំអ្នកជំងឺ និងកត់ត្រាផែនការដោយប្រើភាសាស្តង់ដាឬដោយប្រើពាក្យបច្ចេកទេស
- ជួយធ្វើការអន្តរាគមន៍ដើម្បីថែទាំអ្នកជំងឺតាមផែនការដែលបានកំណត់ និងអនុវត្តផែនការថែទាំអ្នកជំងឺដែលបានកំណត់
- ជួយធ្វើការវាយតម្លៃអំពីវឌ្ឍនភាពនៃលទ្ធផលការថែទាំដែលសម្រេចបានពីការអនុវត្តផែនការថែទាំដែលបានកំណត់
- ចូលរួមអនុវត្តការងារប្រកបដោយសីលធម៌ ត្រូវផ្ដល់ការថែទាំប្រាកដប្រជាដោយរក្សា ការបង្ការ ការគោរព សេចក្តីថ្លៃថ្នូរ សិទ្ធិ តម្លៃ ជំនឿ ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ និងសាសនារបស់អ្នកជំងឺ
- ចូលរួមបណ្ដុះបណ្ដាលបន្តដើម្បីបង្កើនសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនឱ្យបានជាប្រចាំដើម្បីអភិវឌ្ឍ និងរក្សាសមត្ថភាពរបស់ខ្លួនជានិច្ច
- ចូលរួមលើកកម្ពស់គុណភាពនៃការអនុវត្តការងារថែទាំអ្នកជំងឺជាប្រចាំ ការច្នៃប្រឌិត និងការបង្កើតវិធីសាស្ត្រថ្មីដើម្បីលើកកម្ពស់គុណភាពការថែទាំអ្នកជំងឺ
- ជួយធ្វើទំនាក់ទំនងជាមួយអ្នកជំងឺ ក្រុមគ្រួសារ និងមន្ត្រីសុខាភិបាលដទៃទៀតដើម្បីធ្វើការប៉ាន់ប្រមាណពីជំនាញទំនាក់ទំនងរបស់ខ្លួនក្នុងពេលជួបសម្ភាសន៍អ្នកជំងឺ ក្រុមគ្រួសារ និងមន្ត្រីសុខាភិបាលដទៃទៀត
- ជួយកត់ត្រាពីសកម្មភាពថែទាំអ្នកជំងឺ
- ជួយបង្កើតផែនការស្តីពីការអប់រំ និងការលើកកម្ពស់សុខភាពដោយកំណត់សកម្មភាពអន្តរាគមន៍ដើម្បីសម្រេចលទ្ធផលរំពឹងទុក
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

| | |
|---|---|
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង( គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង ) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ( ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ សញ្ញាបត្របឋម ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ បច្ចេកទេសថែទាំនិងអមវេជ្ជសាស្ត្របឋម |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ( អាចបំពេញបន្ថែមដោយអង្គភាព ) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់ចំណេះដឹងនិងបទពិសោធដើម្បីគ្រប់គ្រងទៅតាមស្ថានភាពរបស់អ្នកជំងឺឱ្យបានសមរម្យ<br>-មានសមត្ថភាពប្រើប្រាស់ធនធានឱ្យបានសមរម្យក្នុងបំណងសម្រេចលទ្ធផលល្អនៃការថែទាំអ្នកជំងឺ<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានសមត្ថភាពចូលរួមសហការជាមួយក្រុមការងារនិងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌បច្ចេកទេសថែទាំនិងអមវេជ្ជសាស្ត្រ និយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាព និងជំនាញ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-ចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាថែទាំសុខាភិបាល និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |

| | |
|---|---|
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

## ២៧- ការពិពណ៌នាមុខតំណែងឆ្មបបណ្ឌិត (លេខកូដ : PHE027)

| | | |
|---|---|---|
| ១- ឈ្មោះមុខតំណែង | ឆ្មបបណ្ឌិត | |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) | |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) | |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖ (ត្រូវបំពេញដោយអង្គភាព) | |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖<br>- ផ្តល់ការថែទាំអ្នកជំងឺកម្រិតខ្ពស់ ជាពិសេសជំនាញឯកទេសប្រកបដោយគុណភាព និងសុវត្ថិភាពខ្ពស់សុខភាពមាតាទារក<br>- ធ្វើការស្រាវជ្រាវដើម្បីកែលម្អការអនុវត្ត និងលទ្ធផលនៃការថែទាំសុខភាពមាតាទារក<br>- ចូលរួមក្នុងការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ និងរួមចំណែកដល់មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រនៃការអនុវត្តឆ្មប<br>- ប្រើប្រាស់លទ្ធផលនៃការស្រាវជ្រាវមកកែលម្អការអនុវត្តឱ្យបានប្រសើរឡើង<br>- ដឹកនាំលើកកម្ពស់គុណភាពនៃការអនុវត្តការងារថែទាំអ្នកជំងឺជាប្រចាំ ការច្នៃប្រឌិត និងបង្កើតវិធីសាស្ត្រថ្មីដើម្បីលើកកម្ពស់គុណភាពការថែទាំអ្នកជំងឺ<br>- ចូលរួមរៀបចំកម្មវិធីសិក្សា បង្រៀននិងណែនាំអ្នកជំនាញផ្នែកឆ្មប និងនិស្សិតឆ្មបនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល<br>- ចូលរួមសកម្មភាពបង្រៀនដល់កម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សាក្នុងមូលដ្ឋានសុខាភិបាលដែលខ្លួនកំពុងបម្រើការងារ<br>- ផ្តល់ប្រឹក្សាគោលនយោបាយថែទាំសុខភាព និងផ្តល់យោបល់លើគោលនយោបាយថែទាំសុខភាព<br>- រៀបចំផែនការយុទ្ធសាស្ត្ររបស់អង្គភាពនិងបង្កើតផែនការប្រតិបត្តិប្រចាំឆ្នាំ<br>- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ សញ្ញាបត្របណ្ឌិត ឬសញ្ញាបត្រសមមូល | |
| | ជំនាញឯកទេស៖ បណ្ឌិតទស្សនវិជ្ជា ឬបណ្ឌិតគ្លីនិកផ្នែកឆ្មប | |

| | |
|---|---|
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>- មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>- មានចំណេះដឹងការងារគ្រប់គ្រងទិន្នន័យនិងព័ត៌មាន<br>- មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត បានយ៉ាងស្ទាត់ជំនាញ<br>- មានសមត្ថភាពរៀបចំវិធីសាស្ត្រស្រាវជ្រាវ និងរៀបចំឯកសារវិទ្យាសាស្ត្រសម្រាប់ធ្វើការបោះពុម្ព<br>- មានសមត្ថភាពរៀបចំគម្រោងស្រាវជ្រាវ និងស្វែងរកថវិកា<br>- មានសមត្ថភាពធ្វើការវិភាគ និងបង្កើតគំនិតច្នៃប្រឌិតប្រកបដោយនវានុវត្តន៍<br>- មានសមត្ថភាពបង្កើតទ្រឹស្តីថ្មី ឬគំរូសម្រាប់អនុវត្តដើម្បីធ្វើឱ្យប្រសើរឡើងលើការងារថែទាំ<br>- មានសមត្ថភាពធ្វើការឆ្លើយតបទៅនឹងការផ្លាស់ប្តូរ<br>- មានសមត្ថភាពបង្កើតវិធីសាស្ត្រតាមដាន និងត្រួតពិនិត្យវឌ្ឍនភាព ព្រមទាំងធ្វើការកែតម្រូវនៅពេលចាំបាច់<br>- មានសមត្ថភាពបង្កើតផែនការសម្រាប់អនុវត្ត<br>- មានសមត្ថភាពធ្វើការវាយតម្លៃគុណភាព<br>- មានសមត្ថភាពវិភាគដើម្បីស្វែងយល់ដឹងពីភាគីពាក់ព័ន្ធ<br>- មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>-គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>-មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម |

## ២៨- ការពិពណ៌នាមុខតំណែងឆ្មបជាន់ខ្ពស់ (លេខកូដ : PHE028)

<table>
<tr><td>១- ឈ្មោះមុខតំណែង</td><td>ឆ្មបជាន់ខ្ពស់</td></tr>
<tr><td>២- ឈ្មោះអង្គភាព</td><td>(ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី)</td></tr>
<tr><td>៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់</td><td>(ត្រូវបំពេញដោយអង្គភាព)</td></tr>
<tr><td>៤- គណនេយ្យភាព</td><td>រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព)</td></tr>
<tr><td colspan="2">៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ<br>-ផ្ដល់សេវាថែទាំសុខភាពដល់ស្ត្រី រួមទាំងការពិនិត្យរោគស្ត្រី សេវារៀបចំផែនការគ្រួសារ ការថែទាំមុនពេលសម្រាល និងការសម្រាលកូន<br>-ប្រើប្រាស់ទ្រឹស្តីនៃការថែទាំក្នុងការធ្វើការប៉ាន់ប្រមាណដោយប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ ស៊ីជម្រៅសមស្របទៅនឹងសុខភាពអ្នកជំងឺ ឬស្ថានភាពរបស់អ្នកជំងឺ សុខភាពផ្លូវកាយ ផ្លូវចិត្ត សង្គម និងជំនឿសាសនា<br>-ជួយបកស្រាយ វិភាគទិន្នន័យដែលបានមកពីការប៉ាន់ប្រមាណដើម្បីកំណត់រកពេគវិនិច្ឆ័យ ឬបញ្ហា របស់អ្នកជំងឺក្នុងករណីឆ្មបបរិញ្ញាបត្រមិនអាចធ្វើបាន<br>-ជួយពិនិត្យមើលការបង្កើតផែនការដោយកំណត់យុទ្ធសាស្ត្រថែទាំអ្នកជំងឺនិងកត់ត្រាផែនការដោយប្រើភាសាស្តង់ដា ឬដោយប្រើពាក្យបច្ចេកទេសក្នុងករណីឆ្មបមិនអាចធ្វើបាន<br>-ចូលរួមរៀបចំកម្មវិធីសិក្សា បង្រៀននិងណែនាំអ្នកជំនាញផ្នែកឆ្មប និងនិស្សិតឆ្មបនៅតាមគ្រឹះស្ថានបណ្ដុះបណ្ដាលក្នុងវិស័យសុខាភិបាល<br>-ចូលរួមសកម្មភាពបង្រៀនដល់កម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សាក្នុងមូលដ្ឋានសុខាភិបាលដែលខ្លួនកំពុងបម្រើការងារ<br>-ជួយផ្ដល់ប្រឹក្សា ឬកែសម្រួលអន្តរាគមន៍ថែទាំអ្នកជំងឺតាមផែនការដែលបានកំណត់ និងអនុវត្តផែនការ ថែទាំអ្នកជំងឺដើម្បីជួយដល់ឆ្មបក្នុងករណីមិនអាចធ្វើបាន<br>-ជួយដល់ឆ្មបធ្វើការវាយតម្លៃអំពីវឌ្ឍនភាពនៃលទ្ធផលលើការថែទាំដែលសម្រេចបានពីការអនុវត្តផែនការថែទាំក្នុងករណីធ្ងន់ធ្ងរ<br>-ជួយដោះស្រាយដល់ឆ្មបក្នុងការអនុវត្តការងារដែលមានស្ថានភាពស្មុគស្មាញដោយភាពមានសីលធម៌<br>-ជួយបណ្ដុះបណ្ដាលបន្ត និងធ្វើការវាយតម្លៃពីតម្រូវការបណ្ដុះបណ្ដាលបន្តដើម្បីបង្កើនសមត្ថភាពវិជ្ជាជីវៈឆ្មប<br>-ចូលរួមនិងដឹកនាំធ្វើការស្រាវជ្រាវដោយយកលទ្ធផលនៃការស្រាវជ្រាវដើម្បីធ្វើការផ្លាស់ប្ដូរការអនុវត្តឱ្យបានសមស្រប<br>-ចូលរួមនិងដឹកនាំការបង្កើនគុណភាពនៃការអនុវត្ត និងការវិភាគទិន្នន័យគុណភាពដើម្បីកំណត់ពីកាលានុវត្តភាពក្នុងការលើកកម្ពស់ការអនុវត្តការថែទាំ<br>-ច្នៃប្រឌិតគំរូទំនាក់ទំនងជាមួយអ្នកជំងឺ ក្រុមគ្រួសារ និងមន្ត្រីសុខាភិបាលដទៃទៀតឱ្យមានប្រសិទ្ធភាព</td></tr>
</table>

| | |
|---|---|
| -ជួយសម្របសម្រួលក្នុងការថែទាំរួមបញ្ចូលចំណេះដឹងវិទ្យាសាស្ត្រ ភស្តុតាងល្អៗ និងការវិនិច្ឆ័យរបស់អ្នកជំនាញដើម្បីណែនាំការអនុវត្តឱ្យមានប្រសិទ្ធភាព<br>-បង្កើតផែនការស្ដីពីការអប់រំ និងការលើកកម្ពស់សុខភាពដោយកំណត់សកម្មភាពអន្តរាគមន៍ដើម្បីសម្រេចលទ្ធផលរំពឹងទុក<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង( គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង ) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ( ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ ឆ្មប |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ( អាចបំពេញបន្ថែមដោយអង្គភាព ) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់ភាពជាអ្នកដឹកនាំគ្រប់គ្រង និងបំពេញមុខងារក្នុងដែនត្រួតពិនិត្យដើម្បីបង្កើតបរិស្ថានការងារវិជ្ជមាន<br>-មានសមត្ថភាពប្រើប្រាស់ធនធាន ប៉ាន់ប្រមាណតម្រូវការនៃការថែទាំរបស់អ្នកទទួលសេវាជាលក្ខណៈបុគ្គល និងប៉ាន់ប្រមាណធនធានដែលមានស្រាប់ដើម្បីសម្រេចលទ្ធផលរំពឹងទុក<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រនិងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានសមត្ថភាពដឹកនាំប្រើកម្មវិធីវិភាគទិន្នន័យវិទ្យាសាស្ត្រកម្រិតមូលដ្ឋាន<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងៗទៀត បានយ៉ាងស្ទាត់ជំនាញ<br>-មានសមត្ថភាពចូលរួមសហការជាមួយក្រុមការងារ និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-មានសមត្ថភាពយល់ដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌គិលានុបដ្ឋាក និយាមវិជ្ជាជីវៈ [illegible]វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារ អង្គភាព និងជំនាញ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ |

| | |
|---|---|
| | -មានសមត្ថភាពចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាថែទាំសុខាភិបាល និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារៈ<br>-គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>-មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

## ២៩- ការពិពណ៌នាមុខតំណែងឆ្មបបរិញ្ញាបត្រ (លេខកូដ : PHE029)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | ឆ្មបបរិញ្ញាបត្រ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- ប្រើប្រាស់របៀបនៃការថែទាំរបស់ឆ្មប និងអនុវត្តការវិនិច្ឆ័យវិជ្ជាជីវៈមុនពេលមានផ្ទៃពោះ មុនពេលសម្រាល ឈឺពោះសម្រាល និងក្រោយសម្រាល
- ផ្តល់សេវាថែទាំយោងតាមពិធីសារជាតិស្តីពីមាតុភាពគ្មានគ្រោះថ្នាក់បច្ចុប្បន្ន និងគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន
- ផ្តល់ការថែទាំផ្តោតលើអតិថិជននិងជំនឿរបស់អតិថិជន ដោយគោរពសិទ្ធិរបស់អតិថិជនរក្សាការសម្ងាត់នូវព័ត៌មាន
- រក្សាកំណត់ត្រាសុខភាពជាក្រដាស ឬឌីជីថលឱ្យបានពេញលេញនិងត្រឹមត្រូវដោយកត់ត្រាទុករាល់ការថែទាំទាំងអស់ដែលបានផ្តល់ឱ្យ
- ប្រកាន់ខ្ជាប់គ្រប់ពេលតាមគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំស្តីពីការបង្ការនិងការត្រួតពិនិត្យការចម្លងរោគ
- ឆ្លើយតបប្រកបដោយវិជ្ជាជីវៈ និងការទទួលខុសត្រូវក្នុងស្ថានភាពបន្ទាន់ផ្នែកសម្ភព និងគ្រោះអាសន្ន ផ្សេងៗទៀត ឬគ្រោះមហន្តរាយនានា
- ប្រាស្រ័យទាក់ទងប្រកបដោយការគួរសម និងប្រសិទ្ធភាពដោយគោរពសេចក្តីថ្លៃថ្នូរ វប្បធម៌ គុណតម្លៃ និងសិទ្ធិរបស់បុគ្គលម្នាក់ៗ
- សហការនិងពិគ្រោះយោបល់ជាមួយឆ្មប និងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតក្នុងការផ្តល់ការថែទាំដើម្បីលើកកម្ពស់ការថែទាំជាបន្ត
- ស្វែងរកការគាំទ្រដល់សិទ្ធិរបស់អតិថិជនដោយគោរពស្វ័យភាព សេចក្តីថ្លៃថ្នូរ ភាពឯកជន និងសិទ្ធិស្វ័យសម្រេចជាពិសេសស្ត្រីនិងក្មេងស្រីដែលរងការប៉ះពាល់ដោយអំពើហិង្សា
- ចូលរួមរៀបចំកម្មវិធីសិក្សា បង្រៀននិងណែនាំអ្នកជំនាញផ្នែកឆ្មប និងនិស្សិតឆ្មបនៅតាម គ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- ចូលរួមសកម្មភាពបង្រៀនដល់កម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សាក្នុងមូលដ្ឋានសុខាភិបាលដែលខ្លួនកំពុងបម្រើការងារ
- ចូលរួមក្នុងសកម្មភាពស្រាវជ្រាវ រួមទាំងការប្រមូលទិន្នន័យអេពីដេមីសាស្ត្រសុខភាពនិងសង្គម
- រួមចំណែកក្នុងការអភិវឌ្ឍ ការអនុវត្ត និងការវាយតម្លៃសកម្មភាពនិងកម្មវិធីកែលម្អគុណភាពដើម្បីលើកកម្ពស់ការថែទាំរបស់ឆ្មប
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

| | |
|---|---|
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រឆ្មប ឬបរិញ្ញាបត្រគិលានុបដ្ឋាកឆ្មប ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ ឆ្មប |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រនិងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានសមត្ថភាពអនុវត្តគ្លីនិកលើការថែទាំមុនពេលមានផ្ទៃពោះ ការថែទាំនៅក្នុងសហគមន៍ ការថែទាំមុនពេលសម្រាល ការឈឺពោះសម្រាល និងការសម្រាល ការថែទាំក្រោយពេលសម្រាល ការថែទាំទារកទើបនឹងកើត ការថែទាំការរំលូត ការកត់ត្រាទុកជាឯកសារនិងការរក្សាកំណត់ត្រា ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ ការត្រៀមជាមុន និងការឆ្លើយតបបន្ទាន់ការប្រើប្រាស់ព័ត៌មានសុខាភិបាល<br>-មានសមត្ថភាពដឹកនាំគ្រប់គ្រងលើការងាររដ្ឋបាល និងសុវត្ថិភាពការងារ<br>-មានសមត្ថភាពប្រតិបត្តិច្បាប់ ក្រមសីលធម៌ និងវិជ្ជាជីវៈ<br>-មានសមត្ថភាពប្រាស្រ័យទាក់ទង សហប្រតិបត្តិការ និងការស្វែងរកការគាំទ្រ<br>-មានសមត្ថភាពបង្រៀន និងធ្វើការសិក្សាបន្ថែម<br>-មានសមត្ថភាពស្រាវជ្រាវ អេពីដេមីសាស្ត្រ និងការថែទាំប្រកបដោយគុណភាព<br>-មានចំណេះដឹងនិងជំនាញផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |

| | |
|---|---|
| | ឥរិយាបថបំពេញការងារ៖<br>-គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្ដីភាព មនសិការវិជ្ជាជីវៈនិងវប្បធម៌សេវាសាធារណៈ<br>-ផ្ដល់ការថែទាំដោយគាំទ្រ និងយកចិត្តទុកដាក់លើវប្បធម៌ដោយគោរពស្វ័យភាពរបស់ស្ត្រី<br>-ធ្វើការជាក្រុមប្រកបដោយការគោរពក្នុងនាមជាអ្នកប្រកបវិជ្ជាជីវៈឆ្មប<br>-អនុវត្តតាមនិងបង្ហាញពីគោលការណ៍ និងនិយាមក្រមសីលធម៌ឆ្មប<br>-អនុវត្តការងារដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៅក្នុងប្រទេសកម្ពុជា<br>-ប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព សមស្រប និងយកចិត្តទុកដាក់លើវប្បធម៌ជាមួយស្ត្រីនិងគ្រួសាររបស់គាត់និងសហការី<br>-ធ្វើការប្រកបដោយប្រសិទ្ធភាពក្នុងប្រព័ន្ធសុខាភិបាលកម្ពុជា<br>-ស្វ័យភាពនិងមានទំនួលខុសត្រូវដើម្បីជានាគណនេយ្យភាព និងការជឿទុកចិត្តពីសាធារណជន<br>-គ្រប់គ្រងសុវត្ថិភាពផ្ទាល់ខ្លួនជាពិសេសនៅក្នុងកន្លែងការងារឬសហគមន៍។ |

## ៣០- ការពិពណ៌នាមុខតំណែងឆ្មបមធ្យម (លេខកូដ : PHE030)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | ឆ្មបមធ្យម |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- ផ្តល់សេវាថែទាំដោយប្រើប្រាស់របៀបនៃការថែទាំ និងធ្វើការវិនិច្ឆ័យវិជ្ជាជីវៈ មុនពេលមានផ្ទៃពោះ មុនពេលសម្រាល ឈឺពោះសម្រាល និងក្រោយសម្រាល
- ផ្តល់សេវាថែទាំយោងតាមពិធីសារជាតិស្តីពីមាតុភាពគ្មានគ្រោះថ្នាក់បច្ចុប្បន្ន និងគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន
- ប្រកាន់ខ្ជាប់គ្រប់ពេលតាមគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ
- ផ្តល់ការថែទាំផ្តោតលើអតិថិជននូវជំនឿ ការគោរពសិទ្ធិ និងរក្សាការសម្ងាត់
- រក្សាកំណត់ត្រាសុខភាពជាក្រដាស ឬឌីជីថលឱ្យបានពេញលេញនិងត្រឹមត្រូវដោយកត់ត្រាទុករាល់ការថែទាំទាំងអស់ដែលបានផ្តល់ឱ្យ
- ឆ្លើយតបប្រកបដោយវិជ្ជាជីវៈ និងការទទួលខុសត្រូវក្នុងស្ថានភាពបន្ទាន់ផ្នែកសម្ភព និងគ្រោះអាសន្នផ្សេងៗទៀត ឬគ្រោះមហន្តរាយនានា
- ប្រាស្រ័យទាក់ទងប្រកបដោយការគួរសម និងប្រសិទ្ធភាពដោយគោរពសេចក្តីថ្លៃថ្នូរ វប្បធម៌ គុណតម្លៃ និងសិទ្ធិរបស់បុគ្គលម្នាក់ៗ
- សហការនិងពិគ្រោះយោបល់ជាមួយឆ្មប និងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតក្នុងការផ្តល់ការថែទាំដើម្បីលើកកម្ពស់ការថែទាំជាបន្ត
- ស្វែងរកការគាំទ្រដល់សិទ្ធិរបស់អតិថិជនដោយគោរពស្វ័យភាព សេចក្តីថ្លៃថ្នូរ ភាពឯកជន និងសិទ្ធិស្វ័យសម្រេចជាពិសេសស្ត្រីនិងក្មេងស្រីដែលរងប៉ះពាល់ដោយអំពើហិង្សា
- កំណត់ពីតម្រូវការសិក្សាផ្ទាល់ខ្លួននិងចូលរួមក្នុងការអភិវឌ្ឍវិជ្ជាជីវៈបន្ត និងចូលរួមក្នុងការបណ្តុះបណ្តាលដល់ឆ្មប និស្សិត និងអ្នកប្រកបវិជ្ជាជីវៈសុខភាពផ្សេងទៀត
- ចូលរួមក្នុងសកម្មភាពស្រាវជ្រាវ រួមទាំងការប្រមូលទិន្នន័យអេពីដេមីសាស្ត្រសុខភាព និងសង្គម
- រួមចំណែកក្នុងការអភិវឌ្ឍ ការអនុវត្ត និងការវាយតម្លៃសកម្មភាពនិងកម្មវិធីកែលម្អគុណភាពដើម្បីលើកកម្ពស់ការថែទាំរបស់ឆ្មប
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

| | |
|---|---|
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង( គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង ) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ( ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្ររងឆ្មប ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ ឆ្មប |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ( អាចបំពេញបន្ថែមដោយអង្គភាព ) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រនិងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានសមត្ថភាពអនុវត្តគ្លីនិកលើការថែទាំមុនពេលមានផ្ទៃពោះ ការថែទាំនៅក្នុងសហគមន៍ការថែទាំមុនពេលសម្រាល ការឈឺពោះសម្រាល ការសម្រាល ការថែទាំក្រោយពេលសម្រាល ការថែទាំទារកទើបនឹងកើត ការថែទាំ ការរំលូត ការកត់ត្រាទុកជាឯកសារ និងការរក្សាកំណត់ត្រា ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ ការត្រៀមជាមុន និង ការឆ្លើយតបបន្ទាន់ការប្រើប្រាស់ព័ត៌មានសុខាភិបាល<br>-មានសមត្ថភាពប្រាស្រ័យទាក់ទង សហប្រតិបត្តិការ និងការស្វែងរកការគាំទ្រ<br>-មានសមត្ថភាពក្នុងការបង្រៀននិងការសិក្សាបន្ត<br>-មានសមត្ថភាពស្រាវជ្រាវ អេពីដេមីសាស្ត្រ និងការថែទាំប្រកបដោយគុណភាព<br>-មានចំណេះដឹងនិងជំនាញផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>-គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈនិងវប្បធម៌សេវាសាធារណៈ |

| | |
|---|---|
| | -ផ្តល់ការថែទាំដោយគាំទ្រ និងយកចិត្តទុកដាក់លើវប្បធម៌ដោយគោរពស្វ័យភាពរបស់ស្ត្រី<br>-ធ្វើការជាក្រុមប្រកបដោយការគោរព ក្នុងនាមជាអ្នកប្រកបវិជ្ជាជីវៈឆ្មប<br>-អនុវត្តតាម និងបង្ហាញពីគោលការណ៍ និងនិយាមក្រមសីលធម៌ឆ្មប<br>-អនុវត្តការងារដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៅក្នុងប្រទេសកម្ពុជា<br>-ប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព សមស្របនិងយកចិត្តទុកដាក់ លើវប្បធម៌ជាមួយស្ត្រីនិង គ្រួសាររបស់គាត់និងសហការី<br>-ធ្វើការប្រកបដោយប្រសិទ្ធភាពក្នុងប្រព័ន្ធសុខាភិបាលកម្ពុជា<br>-ស្វ័យភាព និងទទួលខុសត្រូវ ដើម្បីជានាគណនេយ្យភាព និងការជឿទុកចិត្តពីសាធារណជន។ |

## ៣១- ការពិពណ៌នាមុខតំណែងឆ្មបបឋម (លេខកូដ : PHE031)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | ឆ្មបបឋម |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- ចូលរួមធ្វើការប៉ាន់ប្រមាណដោយប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ស៊ីជម្រៅសមស្របទៅនឹងសុខភាពអ្នកជំងឺឬស្ថានភាពរបស់អ្នកជំងឺ សុខភាពផ្លូវកាយ ផ្លូវចិត្ត សង្គម និងជំនឿសាសនា
- ចូលរួមធ្វើរោគវិនិច្ឆ័យ វិភាគទិន្នន័យដែលបានមកពីការប៉ាន់ប្រមាណដើម្បីកំណត់រករោគវិនិច្ឆ័យ ឬបញ្ហារបស់អ្នកជំងឺ និងកត់ត្រាភាពមិនប្រក្រតីរបស់អ្នកជំងឺ
- ចូលរួមបង្កើតផែនការដោយកំណត់យុទ្ធសាស្ត្រថែទាំអ្នកជំងឺ និងកត់ត្រាផែនការដោយប្រើភាសាស្តង់ដាឬដោយប្រើពាក្យបច្ចេកទេស
- ចូលរួមធ្វើការអន្តរាគមន៍ដើម្បីថែទាំអ្នកជំងឺតាមផែនការដែលបានកំណត់ ការអនុវត្តផែនការថែទាំអ្នកជំងឺដែលបានកំណត់
- ចូលរួមធ្វើការវាយតម្លៃអំពីវឌ្ឍនភាពនៃលទ្ធផលការថែទាំដែលសម្រេចបានពីការអនុវត្តផែនការថែទាំដែលបានកំណត់
- ចូលរួមអនុវត្តការងារប្រកបដោយសីលធម៌ ត្រូវផ្តល់ការថែទាំប្រាកដប្រជាដោយរក្សា ការបង្ការ ការគោរពសេចក្តីថ្លៃថ្នូរ សិទ្ធិ តម្លៃ ជំនឿ ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ និងសាសនារបស់អ្នកជំងឺ
- ចូលរួមបណ្តុះបណ្តាលបន្តដើម្បីបង្កើនសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនឱ្យបានជាប្រចាំ ដើម្បីអភិវឌ្ឍនិងរក្សាសមត្ថភាពរបស់ខ្លួនជានិច្ច
- ចូលរួមធ្វើការស្រាវជ្រាវនិងយកលទ្ធផលនៃការស្រាវជ្រាវដើម្បីធ្វើការផ្លាស់ប្តូរការអនុវត្តឱ្យបានសមស្រប
- ចូលរួមលើកកម្ពស់គុណភាពនៃការអនុវត្តការងារថែទាំអ្នកជំងឺជាប្រចាំ ការច្នៃប្រឌិត និងបង្កើតវិធីសាស្ត្រថ្មីដើម្បីលើកកម្ពស់គុណភាពការថែទាំអ្នកជំងឺ
- ធ្វើទំនាក់ទំនងជាមួយអ្នកជំងឺ ក្រុមគ្រួសារ និងមន្ត្រីសុខាភិបាលដទៃទៀតដើម្បីធ្វើការប៉ាន់ប្រមាណ ពីជំនាញទំនាក់ទំនងរបស់ខ្លួនក្នុងពេលជួបសម្ភាសន៍អ្នកជំងឺ ក្រុមគ្រួសារ និងមន្ត្រីសុខាភិបាលដទៃទៀត
- ចូលរួមកត់ត្រាពីសកម្មភាពថែទាំអ្នកជំងឺ
- ចូលរួមបង្កើតផែនការស្តីពីការអប់រំ និងការលើកកម្ពស់សុខភាពដោយកំណត់សកម្មភាពអន្តរាគមន៍ដើម្បីសម្រេចលទ្ធផលរំពឹងទុក
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

| | |
|---|---|
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ សញ្ញាបត្រឆ្មបបឋម |
| | ជំនាញឯកទេស៖ ឆ្មប |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់ធនធានឱ្យបានសមរម្យក្នុងបំណងសម្រេចលទ្ធផលល្អនៃការថែទាំអ្នកជំងឺ<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានសមត្ថភាពចូលរួមសហការជាមួយក្រុមការងារ និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌គិលានុបដ្ឋាក និយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាពនិងជំនាញ<br>-មានសមត្ថភាពមានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានសមត្ថភាពចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាថែទាំសុខាភិបាល និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ<br>-មានចំណេះដឹងនិងជំនាញផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |

| | |
|---|---|
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ ចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- អនុវត្តតាម និងបង្ហាញពីគោលការណ៍ និងនិយាមក្រមសីលធម៌ឆ្នប<br>- អនុវត្តការងារដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៅក្នុងប្រទេសកម្ពុជា<br>- បន្តការអភិវឌ្ឍខ្លួនឯងនិងវិជ្ជាជីវៈ<br>- ចូលរួមជាមួយអ្នកឯកទេសស្រាវជ្រាវផ្នែកគ្លីនិក<br>-មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

**៣២- ការពិពណ៌នាមុខតំណែងមន្ត្រីជំនាញព្យាបាលដោយចលនា** ( **លេខកូដ** : PHE032)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | មន្ត្រីជំនាញព្យាបាលដោយចលនា |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖

- ធ្វើការវាយតម្លៃរកបញ្ហាគ្លីនិក "តាមរយៈការវាយតម្លៃបែបសម្ភាសន៍ និងការវាយតម្លៃបែបវាស់វែងលើរាងកាយ"របស់អ្នកជំងឺឱ្យបានគ្រប់ជ្រុងជ្រោយ ឯករាជ្យលើអាការៈ និងស្ថានភាពសុខភាពរបស់អ្នកប្រើប្រាស់សេវា ឬស្ថានភាពរបស់អ្នកជំងឺលើសុខភាពផ្លូវកាយ ផ្លូវចិត្ត សង្គម ជាពិសេសទាក់ទងនឹងចល័តភាព ចលនា និងសមត្ថភាពមុខងារប្រចាំថ្ងៃ
- ធ្វើការវិភាគបញ្ហាជាពិសេសករណីស្មុគស្មាញ និងផ្តល់រោគវិនិច្ឆ័យតាមរយៈលទ្ធផលនៃការវាយតម្លៃ និងផ្តល់នូវលទ្ធផលនៃភាពប្រសើរឡើងរបស់អ្នកជំងឺតាមរយៈការផ្តល់ការព្យាបាលដោយចលនា
- បង្កើតផែនការនៃការព្យាបាលដោយចលនាប្រកបដោយប្រសិទ្ធភាពដោយមានគោលបំណងរយៈពេលខ្លី គោលបំណងរយៈពេលវែង យុទ្ធសាស្ត្រនិងបច្ចេកទេសនៃការព្យាបាល និងការវាស់វែងលទ្ធផលរំពឹងទុកដោយអនុលោមតាមបទដ្ឋានព្យាបាលដោយចលនា
- ផ្តល់ការព្យាបាលដោយចលនាប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងឯករាជ្យដល់អ្នកជំងឺ ឬអ្នកប្រើប្រាស់សេវាទៅតាមផែនការដែលបានកំណត់(ការព្យាបាលរួមបញ្ចូលទាំងម៉ាស៊ីនព្យាបាល និងឧបករណ៍បច្ចេកវិទ្យាទំនើបៗ ឧបករណ៍ជំនួយ និងសម្ភារៈសុខាភិបាលដែលទាក់ទងនឹងការព្យាបាលដោយចលនា)
- ផ្តល់ដំបូន្មាន អប់រំលើលំហាត់ និងបច្ចេកទេសដល់អ្នកប្រើប្រាស់សេវា ឬអ្នកកំដរដើម្បីធ្វើលំហាត់ដោយខ្លួនឯងនៅផ្ទះ
- ធ្វើការវាយតម្លៃលើប្រសិទ្ធភាព និងវឌ្ឍនភាពនៃលទ្ធផលការព្យាបាល រួមទាំងការវាយតម្លៃក្រោយ ការព្យាបាលភ្លាមៗ និងការវាយតម្លៃវាស់វែងលទ្ធផលតាមគោលបំណង
- កត់ត្រានូវព័ត៌មាននៃការព្យាបាលក្នុងឯកសាររបស់អ្នកជំងឺ ដើម្បីងាយស្រួលក្នុងការតាមដាននូវវឌ្ឍនភាព និងលទ្ធផលនៃការព្យាបាលដោយចលនា
- អនុវត្តការងារប្រកបដោយសីលធម៌ ត្រូវផ្តល់សេវាដែលសមស្របជាក់លាក់ដោយរក្សា ការបង្ការ ការគោរព សេចក្តីថ្លៃថ្នូរ សិទ្ធិ តម្លៃ ជំនឿ ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ និងសាសនារបស់អ្នកប្រើប្រាស់សេវា

| | |
|---|---|
| -ចែករំលែកវឌ្ឍនភាពនៃការព្យាបាលដោយចលនា ដល់ក្រុមពហុជំនាញវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធនឹងអ្នកជំងឺ ឬអ្នកប្រើប្រាស់សេវាក្នុងគោលបំណងជំរុញភាពប្រសើរឡើងរបស់អ្នកប្រើប្រាស់សេវា<br>-ធ្វើការតាមដានដោយធ្វើការណាត់ជួប ដើម្បីពិនិត្យលើវឌ្ឍនភាពរបស់អ្នកប្រើប្រាស់សេវា និងការផ្ដល់អន្តរាគមន៍បន្ត<br>-ធ្វើការបញ្ជូនអ្នកប្រើប្រាស់សេវាទៅរកសេវាសុខភាពដែលពាក់ព័ន្ធដូចជាសេវាសម្ព័ន្ធសុខាភិបាល សេវាស្តារលទ្ធភាពពលកម្ម ឬឧបករណ៍ជំនួយជាដើម ឬក៏បញ្ចេញអ្នកប្រើប្រាស់សេវាត្រឡប់ទៅផ្ទះទៅតាមភាពប្រសើរឡើងនៃអាការៈរបស់អ្នកជំងឺ ឬអ្នកប្រើប្រាស់សេវា<br>-ចូលរួមរៀបចំកម្មវិធីសិក្សា បង្រៀន និងណែនាំដល់អ្នកព្យាបាលចលនានិងនិស្សិតនៅតាមគ្រឹះស្ថានបណ្ដុះបណ្ដាលក្នុងវិស័យសុខាភិបាល<br>-ចូលរួមសកម្មភាពបង្រៀនដល់កម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សាក្នុងមូលដ្ឋានសុខាភិបាលដែលខ្លួនកំពុងបម្រើការងារ<br>-ធានានូវការទទួលខុសត្រូវលើការផ្ដល់សេវាព្យាបាលដោយចលនាដល់អ្នកប្រើប្រាស់សេវាដែលមកទទួលសេវាព្យាបាលដោយចលនាប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងភាពឯករាជ្យលើវិជ្ជាជីវៈរបស់ខ្លួន<br>-ចូលរួមវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា ឬសន្និបាតនានាដើម្បីបង្កើនសមត្ថភាពលើវិជ្ជាជីវៈព្យាបាលដោយចលនា និងធានានូវគុណភាពនៃការផ្ដល់សេវាព្យាបាលដោយចលនាលើអ្នកប្រើប្រាស់សេវា<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្ដុះបណ្ដាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រព្យាបាលដោយចលនា ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ ព្យាបាលដោយចលនា |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានក្រមសីលធម៌ ចេះផ្តល់សេវាដែលសមស្របជាក់លាក់ដោយរក្សាការបង្ការ ការគោរពសេចក្តីថ្លៃថ្នូរ សិទ្ធិ តម្លៃ ជំនឿ ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ និងសាសនារបស់អ្នកប្រើប្រាស់សេវា |

| | |
|---|---|
| | -មានសមត្ថភាពក្នុងការវាយតម្លៃ ការវិភាគលើបញ្ហាគ្លីនិក ផែនការព្យាបាល និងផ្តល់សេវាវិជ្ជាជីវៈព្យាបាលដោយចលនា ដោយឯករាជ្យខ្លួនឯងទៅតាមបញ្ហាគ្លីនិកលើអ្នកប្រើប្រាស់សេវាដែលបានរកឃើញដោយគ្មានការអន្តរាគមន៍ពីអ្នកវិជ្ជាជីវៈវេជ្ជសាស្ត្រដទៃឡើយ<br>-មានសមត្ថភាពផ្តល់ភស្តុតាងជាមូលដ្ឋានក្នុងកម្រិតមធ្យម ដែលទាក់ទងនឹងការពិនិត្យវិនិច្ឆ័យ ការធ្វើរោគវិនិច្ឆ័យ ការធ្វើផែនការ ការអន្តរាគមន៍ និងការវាយតម្លៃឡើងវិញទៅលើបច្ចេកទេសព្យាបាលដើម្បីទទួលបាននូវលទ្ធផលនិងគុណភាពនៃការប្រើប្រាស់បច្ចេកទេស ព្រមទាំងចូលរួមដោះស្រាយរាល់បញ្ហានានាស្របតាមបទដ្ឋានបច្ចេកទេសដើម្បីធានាគុណភាព សុវត្ថិភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ក្នុងការផ្តល់សេវា<br>-មានសមត្ថភាពក្នុងសិក្សាស្រាវជ្រាវលើបញ្ហាថ្មីៗ ដែលទាក់ទងនឹងការព្យាបាលដោយចលនា យ៉ាងហោចណាស់ក្នុងកម្រិតការវិភាគពិពណ៌នាលើទិន្នន័យ ឬស្រាវជ្រាវនូវការសិក្សាស្រាវជ្រាវថ្មីៗមកបង្រៀនបន្ត ឬប្រើប្រាស់ក្នុងការព្យាបាលដល់សាធារណជន<br>-មានលទ្ធភាពលើកកម្ពស់គុណភាពនៃការអនុវត្តការផ្តល់សេវាជាប្រចាំ ដោយគោរពគោលការណ៍គ្រឹះបទដ្ឋានជាតិប្រកបដោយការច្នៃប្រឌិត និងបង្កើតវិធីសាស្ត្រថ្មីដើម្បីលើកកម្ពស់គុណភាពជូនសាធារណជន<br>-មានសមត្ថភាពចូលរួមឬធ្វើជាវាគ្មិនក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា ឬសន្និបាតនានា<br>-មានសមត្ថភាពទំនាក់ទំនងល្អជាមួយអ្នកប្រើប្រាស់សេវា ក្រុមគ្រួសារ និងមន្ត្រីសុខាភិបាលដទៃទៀតប្រកបដោយប្រសិទ្ធភាព និងកិច្ចសហប្រតិបត្តិការ ដើម្បីជាជំនួយក្នុងការផ្តល់សេវាជូនសាធារណជន<br>-មានសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រងក្រុមការងារថែទាំសុខភាពបរិស្ថានទៅតាមស្ថានភាពជាក់ស្តែងដើម្បីបំពេញគោលនយោបាយ និងបទប្បញ្ញត្តិឱ្យបានពេញលេញ<br>-មានសមត្ថភាពគ្រប់គ្រង និងប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងគោលបំណងសម្រេចបាននូវលទ្ធផលល្អក្នុងការផ្តល់សេវា<br>-មានសមត្ថភាពក្នុងការកំណត់នូវបញ្ហារបស់អ្នកប្រើប្រាស់សេវាដើម្បីបញ្ជូនទៅកាន់សេវាផ្សេងទៀតដែលត្រឹមត្រូវនិងសមស្របទាំងក្នុងនិងក្រៅអង្គភាព |

| | |
|---|---|
| | -ចេះបង្កើតផែនការស្តីពីការអប់រំ និងការលើកកម្ពស់សុខភាពដោយកំណត់យុទ្ធសាស្ត្រដើម្បីសម្រេចលទ្ធផលរំពឹងទុក<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រនិងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានសមត្ថភាពចូលរួមសហការជាមួយសហសេវិក និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌ និយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាពនិងជំនាញ<br>-មានបទពិសោធពាក់ព័ន្ធនឹងការងារនៅក្នុងស្ថាប័នរដ្ឋ និងឯកជន<br>-មានសមត្ថភាពចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាសម្ព័ន្ធសុខាភិបាល និងលើកកម្ពស់សុខុមាលភាពសាធារណជន<br>-មានចំណេះដឹងនិងជំនាញផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារៈ<br>- គោរពក្រមសីលធម៌វិជ្ជាជីវៈ និងបទដ្ឋានព្យាបាលដោយចលនា<br>- គោរពនូវការស្នើសុំឬការផ្តល់យោបល់របស់អ្នកប្រើប្រាស់សេវា ក្រុមគ្រួសារ ឬអ្នកកំដរ<br>- គោរពវិន័យនិងទំនួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈ ភាពជាម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈនិងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

**៣៣- ការពិពណ៌នាមុខតំណែងមន្ត្រីបច្ចេកទេសព្យាបាលដោយចលនា** (លេខកូដ : PHE033)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | មន្ត្រីបច្ចេកទេសព្យាបាលដោយចលនា |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- ធ្វើការវាយតម្លៃរកបញ្ហាគ្លីនិក "តាមរយៈការវាយតម្លៃបែបសម្ភាសន៍ និងការវាយតម្លៃបែបវាស់វែងលើរាងកាយ" អ្នកជំងឺឱ្យបានច្បាស់លាស់និងគ្រប់ជ្រុងជ្រោយលើអាការៈនិងស្ថានភាពសុខភាពរបស់អ្នកប្រើប្រាស់សេវា ឬស្ថានភាពរបស់អ្នកជំងឺលើសុខភាពផ្លូវកាយ ផ្លូវចិត្ត សង្គម ជាពិសេសទាក់ទងនឹងចល័តភាព ចលនា និងសមត្ថភាពមុខងារប្រចាំថ្ងៃ
- ធ្វើការវិភាគបញ្ហាសាមញ្ញទូទៅនិងផ្តល់រោគវិនិច្ឆ័យតាមរយៈលទ្ធផលនៃការវាយតម្លៃ និងផ្តល់នូវលទ្ធផលនៃភាពប្រសើរឡើងរបស់អ្នកជំងឺតាមរយៈការផ្តល់ការព្យាបាលដោយចលនា
- បង្កើតផែនការនៃការព្យាបាលដោយចលនាប្រកបដោយប្រសិទ្ធភាព ដោយមានគោលបំណងរយៈ ពេលខ្លី គោលបំណងរយៈពេលវែង យុទ្ធសាស្ត្រនិងបច្ចេកទេសនៃការព្យាបាលអនុលោមតាមបទដ្ឋានព្យាបាលដោយចលនា
- ផ្តល់ការព្យាបាលដោយចលនាប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងឯករាជ្យដល់អ្នកជំងឺ ឬអ្នកប្រើប្រាស់សេវាទៅតាមផែនការដែលបានកំណត់ (ការព្យាបាលរួមបញ្ចូលទាំងម៉ាស៊ីនព្យាបាល ឧបករណ៍បច្ចេកវិទ្យា ឧបករណ៍ជំនួយ និងសម្ភារៈសុខាភិបាលដែលទាក់ទងនឹងការព្យាបាលដោយចលនា)
- ផ្តល់ដំបូន្មាន អប់រំលើលំហាត់ និងបច្ចេកទេសដល់អ្នកប្រើប្រាស់សេវា ឬអ្នកកំដរដើម្បីធ្វើលំហាត់ដោយខ្លួនឯងនៅផ្ទះ
- ធ្វើការវាយតម្លៃលើប្រសិទ្ធភាព និងវឌ្ឍនភាពនៃលទ្ធផលការព្យាបាល (រួមទាំងការវាយតម្លៃក្រោយការព្យាបាលភ្លាមៗ)
- កត់ត្រានូវព័ត៌មាននៃការព្យាបាលក្នុងឯកសាររបស់អ្នកជំងឺ ដើម្បីងាយស្រួលក្នុងការតាមដាននូវវឌ្ឍនភាព និងលទ្ធផលនៃការព្យាបាលដោយចលនា

-អនុវត្តការងារប្រកបដោយសីលធម៌ ត្រូវផ្តល់សេវាដែលសមស្របជាក់លាក់ដោយរក្សា ការបង្ការការគោរព សេចក្តីថ្លៃថ្នូរ សិទ្ធិ តម្លៃ ជំនឿ ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ និងសាសនារបស់អ្នកប្រើប្រាស់សេវា

-ចែករំលែកវឌ្ឍនភាពនៃការព្យាបាលដោយចលនា ដល់ក្រុមពហុជំនាញវិជ្ជាជីវៈសុខាភិបាល ដែលពាក់ព័ន្ធនឹងអ្នកជំងឺ ឬអ្នកប្រើប្រាស់សេវាក្នុងគោលបំណង ជំរុញភាពប្រសើរឡើងរបស់អ្នកប្រើប្រាស់សេវា

-ធ្វើការតាមដានដោយធ្វើការណាត់ជួបដើម្បីពិនិត្យលើវឌ្ឍនភាពរបស់អ្នកប្រើប្រាស់សេវា និងការផ្តល់អន្តរាគមន៍បន្ត

-ធ្វើការបញ្ជូនអ្នកប្រើប្រាស់សេវាទៅរកសេវាសុខភាពដែលពាក់ព័ន្ធ ដូចជា សេវាសម្ព័ន្ធសុខាភិបាល សេវាស្តារលទ្ធភាពពលកម្ម ឬឧបករណ៍ជំនួយជាដើម ឬក៏បញ្ចេញអ្នកប្រើប្រាស់សេវាត្រឡប់ទៅផ្ទះទៅតាមភាពប្រសើរឡើងនៃអាការៈរបស់អ្នកជំងឺ ឬអ្នកប្រើប្រាស់សេវា

-ចែករំលែកបទពិសោធនិងចំណេះដឹងដល់គ្រូពេទ្យព្យាបាលដោយចលនាបរិញ្ញាបត្ររង និស្សិតព្យាបាលដោយចលនា និងវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធក្នុងគោលបំណង អភិវឌ្ឍវិជ្ជាជីវៈបណ្តុះបណ្តាលបន្ត និងផ្សព្វផ្សាយវិជ្ជាជីវៈព្យាបាលដោយចលនាក្នុងវិស័យសុខាភិបាល

-ធានានូវការទទួលខុសត្រូវលើផ្តល់សេវាព្យាបាលដោយចលនាដល់អ្នកប្រើប្រាស់សេវាដែលមកទទួលសេវាព្យាបាលដោយចលនាប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព

-ចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ឬសន្និបាតនានាដើម្បីបង្កើនសមត្ថភាពលើវិជ្ជាជីវៈព្យាបាល ដោយចលនា ដើម្បីធានានូវគុណភាពនៃការផ្តល់សេវាព្យាបាលដោយចលនាលើអ្នកប្រើប្រាស់សេវា

-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

៦- គុណវុឌ្ឍិសម្រាប់មុខតំណែង( គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង )

៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ( ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន )

| | |
|---|---|
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្ររងព្យាបាលដោយចលនា |
| | ជំនាញឯកទេស៖ ព្យាបាលដោយចលនា |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |

| | |
|---|---|
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានក្រមសីលធម៌ ចេះផ្តល់សេវាដែលសមស្របជាក់លាក់ដោយរក្សាការបង្ការ ការគោរព សេចក្តីថ្លៃថ្នូរ សិទ្ធិ តម្លៃ ជំនឿ ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ និងសាសនារបស់អ្នកប្រើប្រាស់សេវា<br>-មានសមត្ថភាពក្នុងការវាយតម្លៃ វិភាគលើបញ្ហាគ្លីនិក ធ្វើផែនការព្យាបាលនិងផ្តល់សេវាវិជ្ជាជីវៈព្យាបាលដោយចលនាទៅតាមបញ្ហាគ្លីនិកលើអ្នកប្រើប្រាស់សេវាដែលបានរកឃើញដោយគ្មានការអន្តរាគមន៍ពីអ្នកវិជ្ជាជីវៈវេជ្ជសាស្ត្រដទៃទៀយ<br>-មានលទ្ធភាពលើកកម្ពស់គុណភាពនៃការអនុវត្ត ការផ្តល់សេវាជាប្រចាំដោយគោរពគោលការណ៍គ្រឹះ និងបទដ្ឋានជាតិប្រកបដោយគុណភាពជូនសាធារណជន<br>-មានសមត្ថភាពទំនាក់ទំនងល្អជាមួយអ្នកប្រើប្រាស់សេវា ក្រុមគ្រួសារ និងមន្ត្រីសុខាភិបាលដទៃទៀត ប្រកបដោយប្រសិទ្ធភាព និងកិច្ចសហប្រតិបត្តិការ ដើម្បីជាជំនួយក្នុងការផ្តល់សេវាជូនសាធារណជន<br>-មានសមត្ថភាពក្នុងការកំណត់នូវបញ្ហារបស់អ្នកប្រើប្រាស់សេវាដើម្បីបញ្ជូនទៅរកសេវាផ្សេងទៀត ដែលត្រឹមត្រូវ និងសមស្របទាំងក្នុងនិងក្រៅអង្គភាព<br>-ចេះបង្កើតផែនការស្តីពីការអប់រំនិងការលើកកម្ពស់សុខភាពដោយកំណត់យុទ្ធសាស្ត្រដើម្បីសម្រេចលទ្ធផលរំពឹងទុក<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រនិងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានសមត្ថភាពចូលរួមសហការជាមួយសហសេវិក និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌ និយាមវិជ្ជាជីវៈ ដែនកំណត់វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងការងារអង្គភាពនិងជំនាញ<br>-មានបទពិសោធពាក់ព័ន្ធនឹងការងារនៅក្នុងស្ថាប័នរដ្ឋនិងឯកជន<br>-មានសមត្ថភាពចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាសម្ព័ន្ធសុខាភិបាល និងលើកកម្ពស់សុខុមាលភាពសាធារណជន<br>-មានចំណេះដឹងនិងជំនាញផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |

| | |
|---|---|
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទំនួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្ដីភាព មនសិការវិជ្ជាជីវៈនិងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

**៣៤- ការពិពណ៌នាមុខតំណែងបណ្ឌិតមន្ទីរពិសោធន៍(លេខកូដ : PHE034)**

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | បណ្ឌិតមន្ទីរពិសោធន៍ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- ដឹកនាំនិងគ្រប់គ្រងមន្ទីរពិសោធន៍
- កំណត់ប្រយោគបញ្ហាសម្រាប់ស្រាវជ្រាវ និងវិធីសាស្ត្រសម្រាប់ការស្រាវជ្រាវ
- ដឹកនាំ និង គ្រប់គ្រងការស្រាវជ្រាវឱ្យសមស្របទៅតាមបរិបទរបស់ប្រទេស
- ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានឱ្យបានសមស្របក្នុងការគ្រប់គ្រងទិន្នន័យ វិភាគ និងបង្ហាញលទ្ធផល
- សំយោគព័ត៌មានទាក់ទងនឹងការស្រាវជ្រាវ និងការអនុវត្តចេញពីប្រភពច្រើន ហើយវិភាគនិងវាយតម្លៃរបកគំហើញរបស់ខ្លួននិងរបស់អ្នកដទៃដោយការពិចារណាល្អិតល្អន់ និងបោះពុម្ពផ្សាយរបកគំហើញនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រជាតិនិងអន្តរជាតិ
- រៀបចំនិងដឹកនាំប្រព័ន្ធតាមដានជំងឺឆ្លង
- បង្កើតយុទ្ធសាស្ត្រពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ ឬកសាងសមត្ថភាពស្រាវជ្រាវសម្រាប់អង្គភាព
- សរសេរគម្រោងស្រាវជ្រាវសម្រាប់ដាក់ស្នើសុំមូលនិធិ
- បង្កើតគោលនយោបាយសុខាភិបាលដែលទាក់ទងនឹងជំនាញមន្ទីរពិសោធន៍ដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រ
- ចូលរួមរៀបចំកម្មវិធីសិក្សានិងបង្រៀនដល់និស្សិតនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- ចូលរួមសកម្មភាពដឹកនាំនិងបង្រៀនដល់កម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សាក្នុងមូលដ្ឋានសុខាភិបាលដែលខ្លួនកំពុងបម្រើការងារ
- រៀបចំប្រព័ន្ធមន្ទីរពិសោធន៍ដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រនិងស្ថានភាពរបស់ប្រទេស
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

| | |
|---|---|
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ សញ្ញាបត្របណ្ឌិតមន្ទីរពិសោធន៍ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ ជំនាញវីរុសសាស្ត្រ មីក្រូសាស្ត្រ ជំនាញគ្រប់គ្រងមន្ទីរពិសោធន៍ ឬជំនាញទាក់ទងនឹងការងារក្នុងមន្ទីរពិសោធន៍ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬភាសាបារាំង ឬភាសាផ្សេងទៀត បានយ៉ាងស្ទាត់ជំនាញ<br>-មានសមត្ថភាពចូលរួមសហការជាមួយសហសេវិក និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹងគោលនយោបាយសុខាភិបាល ក្រមសីលធម៌សុខភាពសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាពនិងជំនាញ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>-គោរពវិន័យ និងទំនួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>-មិនរើសអើងនិងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

## ៣៥- ការពិពណ៌នាមុខតំណែងមន្ត្រីជំនាញមន្ទីរពិសោធន៍ជាន់ខ្ពស់(លេខកូដ : PHE035)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | មន្ត្រីជំនាញមន្ទីរពិសោធន៍ជាន់ខ្ពស់ |
| ២- ឈ្មោះអង្គភាព | **(ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី)** |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | **(ត្រូវបំពេញដោយអង្គភាព)** |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ **(ត្រូវបំពេញដោយអង្គភាព)** |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- បង្កើតនិងគ្រប់គ្រងប្រព័ន្ធចាំបាច់ក្នុងមន្ទីរពិសោធន៍ ដូចជាប្រព័ន្ធធានាគុណភាព
- គ្រប់គ្រងប្រព័ន្ធព័ត៌មានមន្ទីរពិសោធន៍និងប្រើប្រាស់ទិន្នន័យមន្ទីរពិសោធន៍សម្រាប់គាំទ្រការសម្រេចចិត្ត
- បង្កើតគោលនយោបាយគុណភាព និងនីតិវិធីសម្រាប់ដំណើរការមន្ទីរពិសោធន៍
- វាយតម្លៃអនុលោមភាពមន្ទីរពិសោធន៍ស្របតាមស្តង់ដាបច្ចេកទេសដើម្បីធានាគុណភាព ភាពទាន់ពេលវេលា និងមានទំនុកចិត្តឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន
- វាយតំលៃប្រសិទ្ធភាពការងាររបស់មន្ទីរពិសោធន៍
- រៀបចំលំហូរដំណើរការការងារមន្ទីរពិសោធន៍ស្របតាមការទទួលស្គាល់គុណភាពកម្រិតជាតិនិងអន្តរជាតិ
- រៀបចំបង្កើតប្រព័ន្ធជីវសុវត្ថិភាព និងជីវសន្តិសុខដើម្បីគ្រប់គ្រងហានិភ័យ និងការពារការចម្លងរោគចូលបរិស្ថាននិងសហគមន៍
- រៀបចំនិងដឹកនាំការសិក្សាស្រាវជ្រាវ ការវិភាគទិន្នន័យនៃការអង្កេតតាមដានការផ្ទុះជំងឺ គោរពតាមបទប្បញ្ញត្តិដើម្បីលើកកម្ពស់សុខុមាលភាពប្រជាជន និងគោលការណ៍ណែនាំប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ
- ចូលរួមរៀបចំកម្មវិធីសិក្សានិងបង្រៀនដល់និស្សិតនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- ចូលរួមសកម្មភាពដឹកនាំនិងបង្រៀនដល់កម្មសិក្សាការី ឬនិស្សិតធ្វើកម្មសិក្សាក្នុងមូលដ្ឋានសុខាភិបាលដែលខ្លួនកំពុងបម្រើការងារ
- ចូលរួមរៀបចំប្រព័ន្ធអង្កេតតាមដានជំងឺឆ្លង
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណៈសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
|---|---|
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រជាន់ខ្ពស់ជំនាញមន្ទីរពិសោធន៍ ឬបរិញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ បច្ចេកទេសមន្ទីរពិសោធន៍ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬភាសាបារាំង ឬភាសាផ្សេង ទៀតបានយ៉ាងស្ទាត់ជំនាញ<br>-មានសមត្ថភាពចូលរួមសហការជាមួយសហសេវិក និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹងគោលនយោបាយសុខាភិបាលនិង ក្រមសីលធម៌សុខភាពសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាព និងជំនាញ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>-គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>-មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

**៣៦- ការពិពណ៌នាមុខតំណែងមន្ត្រីជំនាញមន្ទីរពិសោធន៍(លេខកូដ : PHE036)**

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | មន្ត្រីជំនាញមន្ទីរពិសោធន៍ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- អនុវត្តបច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រចាប់ពីការប្រមូលសំណាក ការវេចខ្ចប់ ការដឹកជញ្ជូន ឬបញ្ជូនសំណាក ការវិភាគតេស្ត និងរាយការណ៍ឬការបកស្រាយលទ្ធផល
- អនុវត្តការធ្វើតេស្តមន្ទីរពិសោធន៍វេជ្ជសាស្ត្រលើផ្នែកលោហិតសាស្ត្រ ជីវគីមីសាស្ត្រ សរីរវិទ្យា/ភាពស៊ាំវិទ្យាមីក្រូជីវសាស្ត្រ កោសិកាពោគវិទ្យា និងការប្រើប្រាស់ទំនើបកម្មនៃបច្ចេកវិទ្យាថ្មី(ឧ .Flow Cytometry និង Molecular) ស្របតាមដំណាក់កាលវិភាគតេស្ត(មុនពេល ក្នុងពេល និងក្រោយពេលវិភាគ)
- មានភាពជាអ្នកដឹកនាំក្នុងការប្រាស្រ័យទាក់ទង ត្រិះរិះពិចារណា និងដោះស្រាយបញ្ហានៅមន្ទីរពិសោធន៍
- បង្កើតនិងអនុវត្តគោលនយោបាយគុណភាព និងនីតិវិធីសម្រាប់ដំណើរការមន្ទីរពិសោធន៍កម្រិតថ្នាក់មូលដ្ឋានដើម្បីកំណត់គោលដៅច្បាស់លាស់ និងធានាបាននូវស្តង់ដានៃការអនុវត្ត
- វាយតម្លៃផ្ទៀងផ្ទាត់លទ្ធផលវិភាគស្របតាមស្តង់ដាបច្ចេកទេសដើម្បីធានាគុណភាពភាពទាន់ពេលវេលានិងមានទំនុកចិត្តឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន
- កំណត់លំហូរដំណើរការការងារមន្ទីរពិសោធន៍ស្របតាមការទទួលស្គាល់គុណភាពកម្រិតជាតិ និងអន្តរជាតិ
- អនុវត្តជីវសុវត្ថិភាពនិងជីវសន្តិសុខកម្រិតមូលដ្ឋានស្របតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលដើម្បីគ្រប់គ្រងហានិភ័យ និងការពារការចម្លងរោគចូលបរិស្ថាននិងសហគមន៍
- អនុវត្តការសិក្សាស្រាវជ្រាវកម្រិតមូលដ្ឋាន ការវិភាគទិន្នន័យនៃការអង្កេតតាមដានការផ្ទុះជំងឺ គោរពតាមបទប្បញ្ញត្តិដើម្បីលើកកម្ពស់សុខុមាលភាពប្រជាជន និងគោលការណ៍ណែនាំប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

<table>
<tr><td colspan="2">៦- គុណវុឌ្ឍិសម្រាប់មុខតំណែង( គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង )</td></tr>
<tr><td colspan="2">៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ( ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន )</td></tr>
<tr><td rowspan="2">៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ</td><td>កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្របច្ចេកទេសមន្ទីរពិសោធន៍ ឬបរិញ្ញាបត្រសមមូល</td></tr>
<tr><td>ជំនាញឯកទេស៖ បច្ចេកទេសមន្ទីរពិសោធន៍</td></tr>
<tr><td>៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង</td><td>តាមការតម្រូវរបស់អង្គភាព</td></tr>
<tr><td rowspan="2">៦.៤. សមត្ថភាពបំពេញការងារ( អាចបំពេញបន្ថែមដោយអង្គភាព )</td><td>ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានសមត្ថភាពចូលរួមសហការជាមួយសហសេវិក និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹងគោលនយោបាយសុខាភិបាល និងក្រមសីលធម៌សុខភាពសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាពនិងជំនាញ<br>-មានសមត្ថភាពវិភាគស្ថានភាព SWOT ដើម្បីបង្កើតចក្ខុវិស័យនិងបេសកកម្មសម្រាប់មន្ទីរពិសោធន៍<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានចំណេះដឹងនិងជំនាញផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។</td></tr>
<tr><td>ឥរិយាបថបំពេញការងារ៖<br>-គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>-មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។</td></tr>
</table>

**៣៧- ការពិពណ៌នាមុខតំណែងមន្ត្រីបច្ចេកទេសមន្ទីរពិសោធន៍(លេខកូដ : PHE037)**

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | មន្ត្រីបច្ចេកទេសមន្ទីរពិសោធន៍ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ<br>-អនុវត្តបច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រាប់ទាំងការប្រមូលសំណាក វេចខ្ចប់ ដឹកជញ្ជូន ឬបញ្ជូនសំណាក ការវិភាគតេស្ត និងរាយការណ៍ ឬការបកស្រាយលទ្ធផល<br>-អនុវត្តន៍តាមគោលការណ៍របស់ប្រព័ន្ធគ្រប់គ្រងគុណភាពមន្ទីរពិសោធន៍<br>-អនុវត្តន៍វិធានជីវសុវត្ថិភាព និងជីវសន្តិសុខមន្ទីរពិសោធន៍អនុលោមតាមគោលការណ៍ណែនាំជាតិ និងអន្តរជាតិ<br>-អនុវត្តការធ្វើតេស្តមន្ទីរពិសោធន៍វេជ្ជសាស្ត្រ ផ្នែកលោហិតសាស្ត្រ ជីវគីមីសាស្ត្រ សរីរវិទ្យា/ភាពស៊ាំវិទ្យាមីក្រូជីវសាស្ត្រស្របតាមដំណាក់កាលវិភាគតេស្ត មុនពេល ក្នុងពេលនិងក្រោយពេលវិភាគ<br>-អនុវត្តការផ្តល់សេវាមន្ទីរពិសោធន៍វេជ្ជសាស្ត្រអនុលោមតាមច្បាប់ បទប្បញ្ញត្តិ ក្រមសីលធម៌វិជ្ជាជីវៈ ប្រកបដោយគណនេយ្យភាព ការគោរពសិទ្ធ ជំនឿសាសនា និងសមភាពយេនឌ័រ<br>-អនុវត្តន៍ភាពជាអ្នកដឹកនាំ ការប្រាស្រ័យទាក់ទង ការត្រិះរិះពិចារណា និង ការដោះស្រាយបញ្ហាដោយផ្អែកលើភស្តុតាងជាក់លាក់<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណៈសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រៈ បរិញ្ញាបត្ររងមន្ទីរពិសោធន៍ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេសៈ មន្ទីរពិសោធន៍ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |

| | | |
|---|---|
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានសមត្ថភាពចូលរួមសហការជាមួយសហសេវិក និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹងគោលនយោបាយសុខាភិបាល ក្រមសីលធម៌សុខភាពសាធារណៈ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងការងារអង្គភាពនិងជំនាញ<br>-មានសមត្ថភាពវិភាគស្ថានភាព SWOT ដើម្បីបង្កើតចក្ខុវិស័យ និងបេសកកម្មសម្រាប់មន្ទីរពិសោធន៍<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានចំណេះដឹងនិងជំនាញផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>-គោរពវិន័យ និងទំនួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>-មិនរើសអើង ទំនៀមទម្លាប់ ជំនឿ សាសនា និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និង សមធម៌សង្គម។ |

## ៣៨- ការពិពណ៌នាមុខតំណែងមន្ត្រីជំនាញវិទ្យុសាស្ត្រ (លេខកូដ : PHE038)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | មន្ត្រីជំនាញវិទ្យុសាស្ត្រ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- ត្រួតពិនិត្យ វាយតម្លៃ និងបញ្ចូលកម្មវិធីសម្រាប់ដំណើរការរបស់ម៉ាស៊ីនថត X-Ray, Mammography, Fluoroscopy , Sonography, CT Scan, MRI , Interventional Radiography, Nuclear medicine machine…
- ប្រមូលទិន្នន័យ ពិនិត្យប័ណ្ណវិភាគ និងផ្ទៀងផ្ទាត់ឯកសារអ្នកជំងឺ រួមទាំងបញ្ហាសុខភាពអ្នកជំងឺដោយប៉ាន់ប្រមាណស្ថានភាពសុខភាពផ្លូវកាយ និងផ្លូវចិត្តដោយគិតចាប់ពេលទទួលអ្នកជំងឺឱ្យចូលផ្នែកវិទ្យុសាស្ត្រ និងពេលចាប់ផ្តើមថតយករូបភាពវេជ្ជសាស្ត្រ និងជួយការងារលើការព្យាបាល
- វិភាគនិងបកស្រាយព័ត៌មានដែលទាក់ទងទៅនឹងហានិភ័យដោយកាំរស្មី និងសារធាតុវិទ្យុសកម្ម
- ប្រកាន់ខ្ជាប់ការគោរព ការពារឯកជនភាព សេចក្តីថ្លៃថ្នូរ សិទ្ធិ តម្លៃ ជំនឿ ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ និងសាសនារបស់អ្នកជំងឺ ក្រុមគ្រួសារ និងអ្នករួមការងារ
- ធានាដល់ការត្រួតពិនិត្យ ការបង្ការ ការទប់ស្កាត់ការចម្លងរោគ និងការរីករាលដាលនៃជំងឺឆ្លងនានា
- ប្រើប្រាស់វិធីសាស្ត្រនៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព
- ពន្យល់និងណែនាំដល់អ្នកជំងឺនិងក្រុមគ្រួសារអំពីដំណើរការនិងរបៀបថតឆ្លុះ ព្រមទាំងបញ្ហាដែលអាចកើតមានក្នុងអំឡុងពេលថតឆ្លុះ
- សហការជាមួយអ្នកវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធក្នុងការផ្តល់ឱសថ ឬសារធាតុនានាសម្រាប់ជាជំនួយដល់លទ្ធផលនៃការថតឆ្លុះច្បាស់លាស់
- រៀបចំអ្នកជំងឺថតឱ្យបានត្រឹមត្រូវតាមបច្ចេកទេស និងបច្ចេកវិទ្យា
- ប្រើប្រាស់បច្ចេកទេស ផ្ទេរ លើកដាក់ និងបញ្ជូនអ្នកជំងឺ ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព
- ប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាគ្លីនិកសមស្របដូចជា ម៉ាស៊ីនថត X-Ray, Mammography, Fluoroscopy , Sonography, CT Scan, MRI , Interventional Radiography, Nuclear medicine machine ដើម្បីកំណត់រករូបភាពវេជ្ជសាស្ត្រជាក់លាក់ដើម្បីផ្តល់ឱ្យការធ្វើរោគវិនិច្ឆ័យ ឬបញ្ហារបស់អ្នកជំងឺកាន់តែសុក្រឹត និងជួយព្យាបាលជំងឺដោយកាំរស្មីនិងវិទ្យុ

-ពន្យល់និងធ្វើឱ្យប្រសើរឡើងចំពោះភាពលំបាក និងភាពមិនប្រក្រតីក្នុងការផ្តិតយករូបភាពវេជ្ជសាស្ត្រពីអ្នកជំងឺ និងធ្វើរបាយការណ៍ឱ្យបានសមស្រប
-វាយតម្លៃគុណភាពនិងបកប្រែរូបភាពវេជ្ជសាស្ត្រដែលសង្ស័យថាពាក់ព័ន្ធនឹងជំងឺ
-បញ្ជូនរូបភាពទៅគ្រូពេទ្យបកប្រែរូបភាព
-ត្រួតពិនិត្យនិងវាយតម្លៃអំពីដំណើរនិងលទ្ធផលថតឆ្លុះ និងធ្វើរបាយការណ៍
-បន្តការសិក្សា ឬបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ខ្លួនដើម្បីរក្សា និងអភិវឌ្ឍសមត្ថភាពរបស់ខ្លួនជាប្រចាំ
-ដឹកនាំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងចែករំលែកបទពិសោធវឌ្ឍនភាពវិជ្ជាជីវៈដល់សហសេវិក និងក្រុមពហុជំនាញវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធនឹងអ្នកជំងឺ ឬអ្នកប្រើប្រាស់សេវាក្នុងគោលបំណងជំរុញភាពប្រសើរឡើងរបស់អ្នកប្រើប្រាស់សេវា
-ធានានូវការទទួលខុសត្រូវលើការផ្តល់សេវាថតឆ្លុះដល់អ្នកប្រើប្រាស់សេវាប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពលើវិជ្ជាជីវៈរបស់ខ្លួន
-ដឹកនាំក្រុមការងារ និងគ្រប់គ្រងធនធានឱ្យបានសមស្របក្នុងបំណងសម្រេចលទ្ធផលល្អនៃការថតយករូបភាពវេជ្ជសាស្ត្រសមស្រប ត្រឹមត្រូវ ច្បាស់លាស់ ដើម្បីជួយដល់ការធ្វើរោគវិនិច្ឆ័យការថែទាំអ្នកជំងឺ និងការព្យាបាលដោយកាំរស្មីប្រកបដោយស័ក្តិសិទ្ធិភាព
-វាយតម្លៃលទ្ធផល ប្រសិទ្ធផលនិងប្រសិទ្ធភាពការងារ ព្រមទាំងរកវិធីធ្វើឱ្យប្រសើរឡើង
-ធ្វើផែនការសម្រាប់ប្រតិបត្តិការងារប្រចាំឆ្នាំសម្រាប់ក្រុមការងារ និងអង្គភាព
-ប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវដោយប្រើប្រាស់ភស្តុតាងនៃការសិក្សាស្រាវជ្រាវ
-ប្រើប្រាស់លទ្ធផលនៃការស្រាវជ្រាវដើម្បីធានាឱ្យប្រសើរឡើងដល់ផ្នែកវិទ្យុសាស្ត្រ
-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។

៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណៈសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង)

៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន)

| | |
|---|---|
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្របច្ចេកទេសវិទ្យុសាស្ត្រ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ បច្ចេកទេសវិទ្យុសាស្ត្រ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |

| | |
| --- | --- |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពធានាបាននូវសុវត្ថិភាពវិទ្យុសាស្ត្រនិងវិទ្យុសកម្មដល់បុគ្គល អ្នកជំងឺ ក្រុមគ្រួសារ សហសេវិក នៅទីកន្លែងបម្រើការងារ និងសហគមន៍<br>-មានសមត្ថភាពចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាសុខាភិបាលនិងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ<br>-មានគំនិតផ្តួចផ្តើមនិងច្នៃប្រឌិត<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រនិងឧបករណ៍អេឡិចត្រូនិកឌីជីថលសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានសមត្ថភាពទំនាក់ទំនងជាមួយអ្នកជំងឺ ក្រុមគ្រួសារ សហសេវិក ថ្នាក់ដឹកនាំអង្គភាពទាំងក្នុងនិងក្រៅកន្លែងការងារដោយប្រើប្រាស់បច្ចេកទេស មធ្យោបាយ សមស្របប្រកបដោយប្រសិទ្ធភាព<br>-មានសមត្ថភាពត្រួតពិនិត្យ វាយតម្លៃការចម្លងរោគ និងរៀបចំវិធានការសម្រាប់ការបង្ការការចម្លងរោគផ្សេងៗ<br>-មានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាឌីជីថលអេឡិចត្រូនិកនានាសមស្របសម្រាប់ដំណើរការនៃការថតឆ្លុះ និងទំនាក់ទំនង<br>-មានសមត្ថភាពរៀបចំស្ថានភាពនិងថែទាំអ្នកជំងឺក្នុងអំឡុងពេលថតឆ្លុះដោយ X-Ray, Mammography, Fluoroscopy, Sonography, CT Scan, MRI, Interventional Radiology និងព្យាបាល Radiotherapy, Medicine nuclear<br>-មានសមត្ថភាពប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាគ្លីនិកសមស្របដូចជា ម៉ាស៊ីនថត X-Ray, Mammography, Fluoroscopy, Sonography, CT Scan, MRI, Interventional Radiography, Nuclear medicine machine ដើម្បីកំណត់រករូបភាពវេជ្ជសាស្ត្រជាក់លាក់ដើម្បីផ្តល់ឱ្យការធ្វើរោគវិនិច្ឆ័យ ឬបញ្ហារបស់អ្នកជំងឺកាន់តែសុក្រឹត និងជួយព្យាបាលជំងឺដោយកាំរស្មីនិងវិទ្យុ |

| | |
|---|---|
| | -មានសមត្ថភាពបកប្រែរូបភាពដែលសង្ស័យថាមានពាក់ព័ន្ធទៅនឹងជំងឺនិងធានាគុណភាព រូបភាពវេជ្ជសាស្ត្រត្រឹមត្រូវ និងបញ្ជូនទៅគ្រូពេទ្យបកប្រែរូបភាព<br>-មានសមត្ថភាពត្រួតពិនិត្យនិងអនុវត្តវិជ្ជាជីវៈស្របទៅតាមច្បាប់ គោលការណ៍ដែលបានចែង និងប្រកាន់ខ្ជាប់ក្រមសីលធម៌ដោយផ្តល់ការគោរព ការពារឯកជនភាព ការរក្សាការសម្ងាត់វិជ្ជាជីវៈ សេចក្តីថ្លៃថ្នូរ សិទ្ធិ តម្លៃ ជំនឿ ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ និងសាសនារបស់អ្នកជំងឺ ក្រុមគ្រួសារ និងអ្នករួមការងារ<br>-មានសមត្ថភាពដឹកនាំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងចែករំលែកបទពិសោធ វឌ្ឍនភាព វិជ្ជាជីវៈដល់សហសេវិក និងក្រុមពហុជំនាញវិជ្ជាជីវៈ<br>-មានសមត្ថភាពអនុវត្តការដឹកនាំនិងគ្រប់គ្រងផ្នែកវិទ្យុសាស្ត្រនៅតាមអង្គភាព និងស្ថាប័ននានា<br>-មានសមត្ថភាពគ្រប់គ្រងបរិក្ខារ និងម៉ាស៊ីននានាដែលប្រើប្រាស់សម្រាប់ដំណើរការថតឆ្លុះ<br>-មានសមត្ថភាពចងក្រងនិងផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ<br>-មានសមត្ថភាពផ្តល់នូវធាតុចូលសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាវិទ្យុសាស្ត្រ<br>-មានសមត្ថភាពចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាសុខាភិបាល និងលើកកម្ពស់សុខុមាលភាពសាធារណជន<br>មានចំណេះដឹងនិងជំនាញផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារៈ<br>-គោរពវិន័យ និងទំនួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>-មិនរើសអើង ទំនៀមទម្លាប់ ជំនឿ សាសនា និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

**៣៩- ការពិពណ៌នាមុខតំណែងមន្ត្រីបច្ចេកទេសវិទ្យុសាស្ត្រ** ( **លេខកូដ** : PHE039)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | មន្ត្រីបច្ចេកទេសវិទ្យុសាស្ត្រ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- រៀបចំនិងត្រួតពិនិត្យពីដំណើរការរបស់ម៉ាស៊ីនថត X-Ray, Sonography, CT Scan, និង MRI
- ប្រមូលទិន្នន័យ ពិនិត្យប័ណ្ណវិភាគ និងផ្ទៀងផ្ទាត់ឯកសារអ្នកជំងឺ រួមទាំងបញ្ហាសុខភាពអ្នកជំងឺដោយប៉ាន់ប្រមាណស្ថានភាពសុខភាពផ្លូវកាយ និងផ្លូវចិត្ត ដោយគិតចាប់ពេលទទួលអ្នកជំងឺឱ្យចូលផ្នែកវិទ្យុសាស្ត្រនិងពេលចាប់ផ្តើមថតយករូបភាពវេជ្ជសាស្ត្រ និងជួយការងារលើការព្យាបាល
- ប្រមូលនិងពន្យល់ព័តមានដែលទាក់ទងទៅនឹងហានិភ័យដោយកាំរស្មី និងសារជាតុវិទ្យុសកម្ម
- ប្រកាន់ខ្ជាប់សុចរិតភាព គណនេយ្យភាព ការគោរព ការពារឯកជនភាព រក្សាការសម្ងាត់វិជ្ជាជីវៈ ការគោរពសេចក្តីថ្លៃថ្នូរ សិទ្ធិ តម្លៃ ជំនឿ ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ និងសាសនារបស់អ្នកជំងឺ ក្រុមគ្រួសារ និងអ្នករួមការងារ
- ធានាដល់ការត្រួតពិនិត្យ ការបង្ការ ការទប់ស្កាត់ការចម្លងរោគ និងការរីករាលដាលនៃជំងឺឆ្លងនានា
- ប្រើប្រាស់វិធីសាស្ត្រនៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព
- ពន្យល់និងណែនាំដល់អ្នកជំងឺ និងក្រុមគ្រួសារអំពីដំណើរការនិងរបៀបថតឆ្លុះ ព្រមទាំងបញ្ហាដែលអាចកើតមានក្នុងអំឡុងពេលថតឆ្លុះ
- ចូលរួមក្នុងការផ្តល់ឱសថឬសារជាតុនានាសម្រាប់ជាជំនួយដល់លទ្ធផលនៃការថតឆ្លុះច្បាស់លាស់
- រៀបចំអ្នកជំងឺនិងថតឱ្យបានត្រឹមត្រូវតាមបច្ចេកទេស និងបច្ចេកវិទ្យា
- ប្រើប្រាស់បច្ចេកទេស ផ្ទេរ លើកដាក់ និងបញ្ជូនអ្នកជំងឺប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព
- ប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាគ្លីនិកសមស្របដើម្បីកំណត់រករូបភាពវេជ្ជសាស្ត្រជាកលាក់ដើម្បីផ្តល់ឱ្យការធ្វើរោគវិនិច្ឆ័យ ឬបញ្ហារបស់អ្នកជំងឺកាន់តែសុក្រឹត និងជួយព្យាបាលជម្ងឺដោយកាំរស្មីនិងវិទ្យុ
- រកឱ្យឃើញនូវភាពលំបាកនិងភាពមិនប្រក្រតីក្នុងការផ្តិតយករូបភាពវេជ្ជសាស្ត្រពីអ្នកជំងឺ និងធ្វើរបាយការណ៍ឱ្យបានសមស្រប

| |
|---|
| -ពិនិត្យនិងវាយតម្លៃគុណភាពរូបភាពវេជ្ជសាស្ត្រ<br>-បញ្ជូនរូបភាពទៅគ្រូពេទ្យបកប្រែរូបភាព<br>-ធ្វើរបាយការណ៍អំពីដំណើរនិងលទ្ធផលការងារ<br>-បន្តការសិក្សា ឬបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ខ្លួនដើម្បីរក្សា និងអភិវឌ្ឍសមត្ថភាពរបស់ខ្លួនជាប្រចាំ<br>-ចែករំលែកបទពិសោធ និងវឌ្ឍនភាពវិជ្ជាជីវៈដល់សហសេវិក និងក្រុមពហុជំនាញវិជ្ជាជីវៈសុខាភិបាល ដែលពាក់ព័ន្ធនឹងអ្នកជំងឺ ឬអ្នកប្រើប្រាស់សេវាក្នុងគោលបំណងជំរុញភាពប្រសើរឡើងរបស់អ្នកប្រើប្រាស់សេវា<br>-ធានានូវការទទួលខុសត្រូវលើការផ្តល់សេវាថតឆ្លុះដល់អ្នកប្រើប្រាស់សេវាប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពលើវិជ្ជាជីវៈរបស់ខ្លួន<br>-ប្រើប្រាស់ធនធានឱ្យបានសមស្របក្នុងបំណងសម្រេចលទ្ធផលល្អនៃការថតយករូបភាពវេជ្ជសាស្ត្រសមស្រប ត្រឹមត្រូវ និងច្បាស់លាស់ដើម្បីជួយដល់ការធ្វើរោគវិនិច្ឆ័យ ការថែទាំអ្នកជំងឺ និងការព្យាបាលដោយកាំរស្មីប្រកបដោយសក្តិសិទ្ធិភាព<br>-ធ្វើផែនការសម្រាប់ប្រតិបត្តិការងារជាប្រចាំ រួមទាំងវេនប្រចាំការ<br>-ចូលរួមសកម្មភាពស្រាវជ្រាវដោយប្រើប្រាស់ភស្តុតាងនៃការសិក្សាស្រាវជ្រាវ<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) |

| | |
|---|---|
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្ររងបច្ចេកទេសវិទ្យុសាស្ត្រ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ បច្ចេកទេសវិទ្យុសាស្ត្រ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពធានាបាននូវសុវត្ថិភាពវិទ្យុសាស្ត្រនិងវិទ្យុសកម្មដល់បុគ្គល អ្នកជំងឺ ក្រុមគ្រួសារ សហសេវិក នៅទីកន្លែងបម្រើការងារ និងសហគមន៍ |

| | |
|---|---|
| | -មានសមត្ថភាពទំនាក់ទំនងជាមួយអ្នកជំងឺ ក្រុមគ្រួសារ សហសេវិក ថ្នាក់ដឹកនាំអង្គភាពទាំងក្នុងនិងក្រៅកន្លែងការងារដោយប្រើប្រាស់បច្ចេកទេស មធ្យោបាយសមស្របប្រកបដោយប្រសិទ្ធភាព<br>-មានសមត្ថភាពអនុវត្តវិធានការ ការត្រួតពិនិត្យ និងការបង្ការការចម្លងរោគផ្សេងៗ<br>-មានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងអេឡិចត្រូនិកនានាសមស្របសម្រាប់ដំណើរការនៃការថតឆ្លុះ និងទំនាក់ទំនង<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-មានគំនិតផ្តួចផ្តើមនិងច្នៃប្រឌិត<br>-ចេះប្រើប្រាស់កុំព្យូទ័រនិងឧបករណ៍អេឡិចត្រូនិក ឌីជីថលសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-រៀបចំស្ថានភាព និងថែទាំអ្នកជំងឺក្នុងអំឡុងពេលថតឆ្លុះដោយ X-Ray, Mammography, Fluoroscopy, Sonography, CT Scan, MRI, Interventional Radiology និងព្យាបាល Radiotherapy, Medicine nuclear<br>-ចេះប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាគ្លីនិកសមស្របដូចជា X-Ray, Mammography ដើម្បីកំណត់រករូបភាពវេជ្ជសាស្ត្រជាក់លាក់ផ្តល់ឱ្យការធ្វើរោគវិនិច្ឆ័យ ឬបញ្ហារបស់អ្នកជំងឺកាន់តែសុក្រឹត និងជួយព្យាបាលជំងឺដោយកាំរស្មីនិងវិទ្យុ<br>-មានសមត្ថភាពធានាគុណភាពរូបភាពវេជ្ជសាស្ត្រត្រឹមត្រូវ និងបញ្ជូនទៅគ្រូពេទ្យបកប្រែរូបភាព<br>-មានសមត្ថភាពអនុវត្តវិជ្ជាជីវៈស្របទៅតាមច្បាប់ គោលការណ៍ដែលបានចែង និងប្រកាន់ខ្ជាប់ក្រមសីលធម៌ដោយផ្តល់ការគោរព ការពារឯកជនភាព ការរក្សាការសម្ងាត់វិជ្ជាជីវៈ សេចក្តីថ្លៃថ្នូរ សិទ្ធិ តម្លៃ ជំនឿ ប្រពៃណីវប្បធម៌ ទំនៀមទម្លាប់ និងសាសនារបស់អ្នកជំងឺ ក្រុមគ្រួសារ និងអ្នករួមការងារ<br>-មានសមត្ថភាពចែករំលែកបទពិសោធន៍ វឌ្ឍនភាពវិជ្ជាជីវៈដល់សហសេវិក និងក្រុមពហុជំនាញវិជ្ជាជីវៈ<br>-មានសមត្ថភាពចូលរួមការគ្រប់គ្រងបរិក្ខារ និងម៉ាស៊ីននានាដែលប្រើប្រាស់សម្រាប់ដំណើរការថតឆ្លុះ<br>-មានសមត្ថភាពរៀបចំនិងប្រមូលភស្តុតាងស្រាវជ្រាវដើម្បីបញ្ចូលពត៌មាននៃការសិក្សាស្រាវជ្រាវ<br>-មានសមត្ថភាពចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាសុខាភិបាល និងលើកកម្ពស់សុខុមាលភាពសាធារណជន<br>-មានចំណេះដឹងនិងជំនាញផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |

| | |
|---|---|
| | ឥរិយាបថបំពេញការងារៈ<br>-គោរពវិន័យ និងទំនួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>-មិនរើសអើង ទំនៀមទម្លាប់ ជំនឿ សាសនា និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និង សមធម៌សង្គម។ |

## ៤០- ការពិពណ៌នាមុខតំណែងវិស្វករឧបករណ៍ជីវៈវេជ្ជសាស្ត្រ (លេខកូដ : PHE040)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | វិស្វករឧបករណ៍ជីវៈវេជ្ជសាស្ត្រ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖ (ត្រូវបំពេញដោយអង្គភាព) |
| ៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖<br>-បណ្តុះបណ្តាល ដឹកនាំ និងអនុវត្តជាមួយអ្នកបច្ចេកទេសឧបករណ៍ជីវៈវេជ្ជសាស្ត្រអំពីបច្ចេកទេសនៃការងារឧបករណ៍ជីវៈវេជ្ជសាស្ត្រឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសក្នុងការដំឡើង ការធ្វើតេស្តការប្រើប្រាស់ ការគ្រប់គ្រង ការថែទាំបង្ការ ជួសជុល ត្រួតពិនិត្យគុណភាព និងសុវត្ថិភាពឧបករណ៍បរិក្ខារជីវៈវេជ្ជសាស្ត្រ<br>-រៀបចំទិន្នន័យនៃការគ្រប់គ្រង ថែទាំបង្ការ ជួសជុល ត្រួតពិនិត្យគុណភាព និងសុវត្ថិភាពនៃឧបករណ៍បរិក្ខារជីវៈវេជ្ជសាស្ត្រជាប្រចាំ<br>-លើកផែនការការងារ និងថវិកាសម្រាប់ដំណើរការងារឧបករណ៍ជីវៈវេជ្ជសាស្ត្រ(ផែនការថែទាំបង្ការគ្រឿងបន្លាស់ ការបណ្តុះបណ្តាលបន្ត ឧបករណ៍សម្រាប់ធ្វើតេស្តទំនើបកម្មរោងជាង...)<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រ ឬសញ្ញាបត្រវិស្វករ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ ឧបករណ៍ជីវៈវេជ្ជសាស្ត្រ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញឯកទេសតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា |

| | |
|---|---|
| | -មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រនិងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងៗទៀត បានយ៉ាងស្ទាត់ជំនាញ<br>-មានសមត្ថភាពចូលរួមសហការជាមួយក្រុមការងារ និងអ្នកពាក់ព័ន្ធក្រៅអង្គភាព<br>-យល់ដឹងនិងប្រតិបត្តិច្បាប់ ក្រមសីលធម៌សុខភាពសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការងារអង្គភាពនិងជំនាញ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានចំណេះដឹងនិងជំនាញឯកទេសផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង និងមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

## ៤១- ការពិពណ៌នាមុខតំណែងមន្ត្រីបច្ចេកទេសឧបករណ៍ជីវៈវេជ្ជសាស្ត្រ (លេខកូដ : PHE041)

<table>
<tr><td>១- ឈ្មោះមុខតំណែង</td><td>មន្ត្រីបច្ចេកទេសឧបករណ៍ជីវៈវេជ្ជសាស្ត្រ</td></tr>
<tr><td>២- ឈ្មោះអង្គភាព</td><td>(ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី)</td></tr>
<tr><td>៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់</td><td>(ត្រូវបំពេញដោយអង្គភាព)</td></tr>
<tr><td>៤- គណនេយ្យភាព</td><td>រាយការណ៍ជូន៖ (ត្រូវបំពេញដោយអង្គភាព)</td></tr>
<tr><td colspan="2">៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖<br>-ដំឡើងនិងធ្វើតេស្តឧបករណ៍បរិក្ខារជីវៈវេជ្ជសាស្ត្រ<br>-បណ្តុះបណ្តាលអ្នកប្រើប្រាស់ឱ្យចេះប្រើប្រាស់និងថែទាំឧបករណ៍បរិក្ខារជីវៈវេជ្ជសាស្ត្រឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសក្នុងកម្រិតអ្នកប្រើប្រាស់<br>-គ្រប់គ្រង ថែទាំបង្ការ និង ជួសជុលឧបករណ៍បរិក្ខារជីវៈវេជ្ជសាស្ត្រ<br>-ត្រួតពិនិត្យគុណភាព និងសុវត្ថិភាពឧបករណ៍បរិក្ខារជីវៈវេជ្ជសាស្ត្រ<br>-រៀបចំទិន្នន័យនៃការគ្រប់គ្រង ថែទាំបង្ការ ជួសជុល ត្រួតពិនិត្យគុណភាព និងសុវត្ថិភាពនៃឧបករណ៍ បរិក្ខារជីវៈវេជ្ជសាស្ត្រជាប្រចាំ<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។</td></tr>
<tr><td colspan="2">៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណៈសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង)</td></tr>
<tr><td colspan="2">៦.១. ក្របខ័ណ្ឌ ឋានន្តរស័ក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន)</td></tr>
<tr><td rowspan="2">៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ</td><td>កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្ររងឧបករណ៍ជីវៈវេជ្ជសាស្ត្រ ឬសញ្ញាបត្រសមមូល</td></tr>
<tr><td>ជំនាញឯកទេស៖ ឧបករណ៍ជីវៈវេជ្ជសាស្ត្រ</td></tr>
<tr><td>៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង</td><td>តាមការតម្រូវរបស់អង្គភាព</td></tr>
</table>

| | |
|---|---|
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សា<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រនិងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានចំណេះដឹងភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងទៀត អាចប្រើប្រាស់បាន<br>-យល់ដឹងគោលនយោបាយយុទ្ធសាស្ត្រសុខាភិបាល និងក្រមសីលធម៌ វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងការងារអង្គភាពនិង ជំនាញ<br>-មានការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ<br>-មានចំណេះដឹងនិងជំនាញផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>- មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>- មិនរើសអើង មានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ |

## ៤២- ការពិពណ៌នាមុខតំណែងមន្ត្រីជំនាញរូបវិទ្យាវេជ្ជសាស្ត្រ (លេខកូដ : PHE042)

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | មន្ត្រីជំនាញរូបវិទ្យាវេជ្ជសាស្ត្រ |
| ២- ឈ្មោះអង្គភាព | (ត្រូវបំពេញដោយអង្គភាពជ្រើសរើសមន្ត្រី) |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | (ត្រូវបំពេញដោយអង្គភាព) |
| ៤- គណនេយ្យភាព | ពាយការណ៍ជូនៈ (ត្រូវបំពេញដោយអង្គភាព) |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែងៈ

- គណនាវិមាត្រ ជាពិសេសកម្រាស់នៃបន្ទប់ព្យាបាលកាំរស្មីដើម្បីធានាឱ្យបាននូវសុវត្ថិភាពអំឡុងពេលប្រើប្រាស់កាំរស្មី
- សិក្សានិងផ្តល់យោបល់ទាក់ទងរចនាសម្ព័ន្ធ (Configurations) នៃម៉ាស៊ីននិងបរិធានទាំងអស់នៅក្នុងផ្នែកព្យាបាលដោយកាំរស្មី និងវេជ្ជសាស្ត្រនុយក្លេអ៊ែរមុននឹងធ្វើការបញ្ជាទិញ
- ធ្វើតេស្តទទួលយក ប្រមូល និងបញ្ចូលទិន្នន័យរូបវិទ្យាវេជ្ជសាស្ត្រសម្រាប់ដំណើរការម៉ាស៊ីនគូសប្លង់បញ្ចាំងកាំរស្មី (CT-Simulator) ប្រព័ន្ធសិក្សាប្លង់ព្យាបាល (TPS) ម៉ាស៊ីនព្យាបាលជំងឺមហារីកដោយកាំរស្មី (Linear Accelerator) ម៉ាស៊ីនស្ពំជំងឺមហារីកដោយកាំរស្មី (Brachytherapy) និងម៉ាស៊ីនថតរូបភាពវេជ្ជសាស្ត្រនុយក្លេអ៊ែរ (SPECT-CT, PET-CT…)
- វិធានវាស់កម្រិតកាំរស្មី (Beam Output Calibnration) ត្រួតពិនិត្យ និងធានាគុណភាព (QA and QC) ផ្ទៀងផ្ទាត់ប៉ារ៉ាម៉ែត្រមេកានិច ប៉ារ៉ាម៉ែត្ររូបវិទ្យាវេជ្ជសាស្ត្ររបស់ម៉ាស៊ីនគូសប្លង់បញ្ចាំងកាំរស្មី (CT-Simulator) ប្រព័ន្ធសិក្សាប្លង់ព្យាបាល (TPS) ម៉ាស៊ីនព្យាបាលជំងឺមហារីកដោយកាំរស្មី (Linear Accelerator) ម៉ាស៊ីនស្ពំជំងឺមហារីកដោយកាំរស្មី (Brachytherapy) ម៉ាស៊ីនថតរូបភាពវេជ្ជសាស្ត្រនុយក្លេអ៊ែរ (SPECT-CT, PET-CT…) និងម៉ាស៊ីនថតឆ្លុះកាំរស្មីអ៊ិក្សដូចជា X-Ray, Mammography, Fluoroscopy, C-Arm, CT Scan, Angiography ជាប្រចាំនិងរាល់ពេលមានការជួសជុល ឬផ្លាស់ប្តូរគ្រឿងបន្លាស់
- ធ្វើតេស្តទទួលនិងពិនិត្យវាយតម្លៃនូវសុវត្ថិភាពនិងសុក្រិតភាពនៃកម្រិតសកម្មភាពវិទ្យុសកម្មដែលប្រើប្រាស់ក្នុងការស្ពំជំងឺមហារីកដោយកាំរស្មី (Brachytherapy) និងឧបករណ៍ជំនួយព្រមទាំងបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធសិក្សាប្លង់ព្យាបាល
- ធ្វើតេស្តទទួល ប្រមូល និងបញ្ចូលទិន្នន័យក្នុងការប្រើប្រាស់ ព្រមទាំងត្រួតពិនិត្យ វាយតម្លៃ និងតាមដាននូវគុណភាពនិង សុពលភាពរបស់ឧបករណ៍ត្រួតពិនិត្យគុណភាពនៃម៉ាស៊ីនកាំរស្មី
- សិក្សាកម្រិតកាំរស្មី និងផ្តល់សុពលភាពប្លង់ព្យាបាល ដោយសហការជាមួយក្រុមការងារជំនាញពាក់ព័ន្ធ (Radiation oncologist, Dosimetrist, Radiation technologist)

- អនុវត្តនិងបង្កើនប្រសិទ្ធភាពនៃនីតិវិធីវេជ្ជសាស្ត្រសម្រាប់ការវិនិច្ឆ័យ និងការព្យាបាលជំងឺមហារីកដោយប្រើប្រាស់សារធាតុវិទ្យុសកម្ម
- គ្រប់គ្រងការប្រើប្រាស់ប្រភពវិទ្យុសកម្មទាំងអស់ក្នុងវិស័យវេជ្ជសាស្ត្រដោយធានាឱ្យមានសុវត្ថិភាពក្នុងការប្រើប្រាស់ និងការគ្រប់គ្រងសំណល់វិទ្យុសកម្មឱ្យបានត្រឹមត្រូវស្របតាមស្តង់ដាអន្តរជាតិ
- អភិវឌ្ឍនិងបង្កើនប្រសិទ្ធភាពបច្ចេកទេសថតរូបភាពវេជ្ជសាស្ត្រនុយក្លេអ៊ែរ
- ធានាការផ្តល់សេវាកម្មវេជ្ជសាស្ត្រនុយក្លេអ៊ែរដែលមានសុវត្ថិភាព និងគុណភាពខ្ពស់តាមជំនាញវិទ្យាសាស្ត្រ និងបទពិសោធជាក់ស្តែង
- វិធានវាស់កម្រិតកាំរស្មីសម្រាប់បុគ្គលិកពាក់ព័ន្ធម្នាក់ៗ (Personal dosimeter) ដោយអនុលោមតាមនិយាមសាកល ICRP 60 និងទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ (IAEA)
- អនុវត្តគោលការណ៍សុវត្ថិភាពកាំរស្មីដោយវាស់ការលេចជ្រាប ឬសាយភាយចេញនៃកាំរស្មីជាប្រចាំ និងចងក្រងឯកសារនានាសម្រាប់ប្រើប្រាស់ក្នុងផ្នែកព្យាបាលដោយកាំរស្មី
- វិភាគនិងបកស្រាយពត៌មានដែលទាក់ទងទៅនឹងហានិភ័យដោយកាំរស្មី និងសារធាតុវិទ្យុសកម្ម
- ប្រកាន់ខ្ជាប់ការគោរព ការពារឯកជនភាព សេចក្តីថ្លៃថ្នូរ សិទ្ធិ តម្លៃ ជំនឿ ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ និងសាសនារបស់អ្នកជំងឺ ក្រុមគ្រួសារ និងអ្នករួមការងារ
- ធានាដល់ការត្រួតពិនិត្យ ការបង្ការ ការទប់ស្កាត់ការចម្លងរោគ និងការរីករាលដាលនៃជំងឺឆ្លងនានា
- ប្រើប្រាស់វិធីសាស្ត្រនៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព
- ពន្យល់និងណែនាំដល់អ្នកជំងឺ និងក្រុមគ្រួសារអំពីដំណើរការនិងរបៀបព្យាបាល ព្រមទាំងបញ្ហាដែលអាចកើតមានក្នុងអំឡុងពេលព្យាបាល
- ចូលរួមរៀបចំអ្នកជំងឺ និងបញ្ចាំងកាំរស្មីលើកទី១ឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌបច្ចេកទេស
- ស្វែងរកប្រភពបញ្ហានិងដោះស្រាយមុនឈានទៅដល់ការសុំជំនួយពីវិស្វករជីវវេជ្ជសាស្ត្រ ករណីម៉ាស៊ីនព្យាបាលដោយកាំរស្មីមានបញ្ហាអាក់អួល
- ត្រួតពិនិត្យនិងវាយតម្លៃអំពីដំណើរការ និងលទ្ធផលព្យាបាល
- បន្តការសិក្សា ឬបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ខ្លួនដើម្បីរក្សា និងអភិវឌ្ឍសមត្ថភាពរបស់ខ្លួនជាប្រចាំ
- ដឹកនាំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងចែករំលែកបទពិសោធវឌ្ឍនភាពវិជ្ជាជីវៈដល់សហសេវិក និងក្រុមពហុជំនាញវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធនឹងអ្នកជំងឺ ឬអ្នកប្រើប្រាស់សេវាក្នុងគោលបំណងជំរុញភាពប្រសើរឡើងរបស់អ្នកប្រើប្រាស់សេវា
- ទទួលខុសត្រូវលើវិធីសាស្ត្រព្យាបាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពលើវិជ្ជាជីវៈរបស់ខ្លួន
- ដឹកនាំក្រុមការងារនិងគ្រប់គ្រងធនធានឱ្យបានសមស្របក្នុងគោលបំណងសម្រេចលទ្ធផលល្អនៃការព្យាបាលដោយកាំរស្មីប្រកបដោយស័ក្តិសិទ្ធិភាព

| | |
|---|---|
| -វាយតម្លៃលទ្ធផល ប្រសិទ្ធផល និងប្រសិទ្ធភាពការងារ ព្រមទាំងរកវិធីធ្វើឱ្យប្រសើរឡើង<br>-ធ្វើផែនការសម្រាប់ប្រតិបត្តិការងារប្រចាំឆ្នាំសម្រាប់ក្រុមការងារ និងអង្គភាព<br>-ប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវដោយប្រើប្រាស់កស្តុតាងនៃការសិក្សាស្រាវជ្រាវ<br>-ប្រើប្រាស់លទ្ធផលនៃការស្រាវជ្រាវដើម្បីជានាឱ្យប្រសើរឡើង<br>-បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការកំណត់របស់អង្គភាព។ | |
| ៦- គុណវុឌ្ឍិសម្រាប់មុខតំណែង(គុណសម្បត្តិស័ក្តិសម/លក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង) | |
| ៦.១. ក្របខ័ណ្ឌ ឋានន្តរសក្តិ(ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន) | |
| ៦.២. ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រជាន់ខ្ពស់រូបវិទ្យាវេជ្ជសាស្ត្រ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ រូបវិទ្យាវេជ្ជសាស្ត្រ |
| ៦.៣. បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | តាមការតម្រូវរបស់អង្គភាព |
| ៦.៤. សមត្ថភាពបំពេញការងារ(អាចបំពេញបន្ថែមដោយអង្គភាព) | ចំណេះដឹងនិងជំនាញ៖<br>-មានចំណេះដឹងជំនាញតាមវិជ្ជាជីវៈសុខាភិបាលដែលបានសិក្សានិងក្រោយពីឆ្លងកាត់វគ្គបណ្តុះបណ្តាលនានា<br>-មានសមត្ថភាពធានាបាននូវសុវត្ថិភាពកាំរស្មី និងវិទ្យុសកម្មដល់បុគ្គលិក អ្នកជំងឺ ក្រុមគ្រួសារ សហសេវិក នៅទីកន្លែងបម្រើការងារ និងសហគមន៍<br>-មានសមត្ថភាពចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាសុខាភិបាល និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ<br>-មានគំនិតផ្តួចផ្តើមនិងច្នៃប្រឌិត<br>-មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រនិងឧបករណ៍អេឡិចត្រូនិកសម្រាប់ការប្រាស្រ័យទាក់ទងនានា<br>-មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស ឬបារាំង ឬភាសាផ្សេងៗទៀត បានយ៉ាងស្ទាត់ជំនាញ<br>-មានសមត្ថភាពទំនាក់ទំនងជាមួយអ្នកជំងឺ ក្រុមគ្រួសារ សហសេវិក ថ្នាក់ដឹកនាំអង្គភាពទាំងក្នុងនិងក្រៅកន្លែងការងារដោយប្រើប្រាស់បច្ចេកទេស និងមធ្យោបាយ សមស្របប្រកបដោយប្រសិទ្ធភាព |

| | |
|---|---|
| | -មានសមត្ថភាពត្រួតពិនិត្យ វាយតម្លៃការចម្លងរោគ រៀបចំវិធានការនិងបង្ការការចម្លងរោគផ្សេងៗ<br>-មានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាឌីជីថល អេឡិចត្រូនិកនានាសមស្របសម្រាប់ដំណើរការនៃការព្យាបាល និងទំនាក់ទំនង<br>-មានសមត្ថភាពត្រួតពិនិត្យនិងអនុវត្តវិជ្ជាជីវៈស្របទៅតាមច្បាប់ គោលការណ៍ ដែលបានចែង និងប្រកាន់ខ្ជាប់ក្រមសីលធម៌ដោយផ្តល់ ការគោរព ការពារឯកជនភាព ការរក្សាការសម្ងាត់វិជ្ជាជីវៈ សេចក្តីថ្លៃថ្នូរ សិទ្ធិ តម្លៃ ជំនឿ ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ និងសាសនា របស់អ្នកជំងឺ ក្រុមគ្រួសារ និងអ្នករួមការងារ<br>-មានសមត្ថភាពដឹកនាំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងចែករំលែកបទពិសោធវឌ្ឍនភាព វិជ្ជាជីវៈដល់សហសេវិក និងក្រុមពហុជំនាញវិជ្ជាជីវៈ<br>-មានសមត្ថភាពគ្រប់គ្រងបរិក្ខារ ម៉ាស៊ីននានា ដែលប្រើប្រាស់សម្រាប់ដំណើរការព្យាបាល<br>-មានសមត្ថភាពចងក្រង និងផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ<br>-មានសមត្ថភាពផ្តល់នូវធាតុចូលសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាព្យាបាលដោយកាំរស្មី និងវេជ្ជសាស្ត្រនុយក្លេអ៊ែរ<br>-មានសមត្ថភាពចូលរួមជាមួយសហគមន៍ក្នុងការផ្តល់សេវាសុខាភិបាល និងលើកកម្ពស់សុខុមាលភាពសាធារណជន<br>-មានចំណេះដឹងនិងជំនាញផ្សេងៗទៀត តាមតម្រូវការរបស់អង្គភាព។ |
| | ឥរិយាបថបំពេញការងារៈ<br>-គោរពវិន័យ និងទំនួលខុសត្រូវក្នុងការបំពេញការងារ<br>-មានឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ<br>-មានឆន្ទៈជួយគាំទ្រ និងចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>-មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ<br>-មិនរើសអើង ទំនៀមទម្លាប់ ជំនឿ សាសនា និងមានឆន្ទៈលើកកម្ពស់ស[illegible]បន្ទ និងសមធម៌សង្គម។ |